ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Aug-2012, 14:57
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៨៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

កញ្ញា ណាតាចា វីសែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉ាចាម តុន (TCW-564) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ចៃាម តុន ហៅ តី តួន** (TWC-564)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ផ្តើមពី៖.....................................................ទំព័រ ២
សួរដោយលោក សុន អរុណ ផ្តើមពី៖.....................................................ទំព័រ ២៣
សួរដោយលោក អេនឌ្រូ អ៊ីនូហ្សី ផ្តើមពី៖.....................................................ទំព័រ ៤៣
សួរដោយលោក ម៉ៃខល កាណាវាស ផ្តើមពី៖.....................................................ទំព័រ ៦៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះ មានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការ សម្រាប់រយៈពេលពេញមួយថ្ងៃ នៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

[០៩:០២:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយគាត់សុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

លោកវេជ្ជបណ្ឌិត វ៉ាន់ ម៉ិច ដែលទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅមន្ទីរឃុំឃាំង នៃ អ.វ.ត.ក បានពិនិត្យឃើញថា លោក អៀង សារី គាត់មានជំងឺបេះដូង ហើយនៅព្រឹកនេះគាត់មានអាការៈហត់ខ្លាំងនៅពេលធ្វើចលនា ឈឺចង្កេះមិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា លោក អៀង សារី គួរតែត្រូវបានអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយនៅក្រោមសាលសវនាការនេះ។

អង្គជំនុំជម្រះយល់ឃើញថា នាពេលនេះ លោក អៀង សារី មានបញ្ហាសុខភាពតែគាត់អាចលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោត-ទស្សន៍ និងអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ ជាមួយនឹងក្រុមមេធាវីរបស់គាត់បាន។

[០៩:០៥:១១]

អង្គជំនុំជម្រះសម្រេចយល់ព្រម តាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី សុំលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់កិច្ចដំណើរការសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់លោក អៀង សារី តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់អំឡុងពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

ហើយជាកិច្ចបន្ត មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកចៅក្រម ហ្ស៊ង់ម៉ាក!

[០៩:០៥:០៣]

**ចៅក្រម ហ្ស៊ង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ ជម្រាបសួរលោកសាក្សី។

**តាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្ស៊ង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោក ដើម្បីបំភ្លឺទៅលើចម្លើយដែលលោកបានឆ្លើយរួចមកហើយ ហើយដែលបានឆ្លើយមកបានយ៉ាងច្រើនរួចមកហើយ។ ជាដំបូងខ្ញុំចង់ត្រឡប់មកនិយាយអំពីរយៈពេលដែលលោករស់នៅក្នុងព្រៃតស៊ូ។ គឺរយៈពេលមុនពេលដួលរលំនៃទីក្រុងភ្នំពេញ ហើយដែលនៅពេលនោះលោកនៅជិត ប៉ុល ពត ហើយនិងមេដឹកនាំខ្មែរក្រហមផ្សេងៗទៀត។ ប្រសិនបើខ្ញុំយល់ច្បាស់នោះ លោកបានឆ្លើយថា លោកបានជួបលោក ខៀវ សំផន ជាលើកដំបូងនៅឆ្នាំ៦១ សូមទោស

ឆ្នាំ៧១។ តើត្រឹមត្រូវដែរឬទេ ថាលោកជួប ខៀវ សំផន ជាលើកដំបូងបំផុតនោះគឺនៅឆ្នាំ១៩៧១?

**លោក វ៉ាចាម តុន៖**

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** តើលោកមាននឹកឃើញអំពីកាលៈទេសៈ ដែលលោកជួប ខៀវ សំផន ទេ? តើជួបក្នុងលក្ខខណ្ឌបែបណាដែរ?

[០៩:០៦:៣៥]

**ឆ៖** ជួបគាត់ដំបូង គឺគាត់ធ្វើដំណើរមកពីខាងៗ កន្លែងគាត់ស្នាក់នៅ។ គាត់ដើរមក ដើរមកកន្លែង ហៅថាកន្លែងផ្ទះបាយខាងយោធា ដាំបាយហូប។ ជួបគាត់ គាត់ សុខសប្បាយៗ អ៊ីចឹង។ ហើយគាត់សួរខ្ញុំថា "សុខសប្បាយទេ?" ខ្ញុំថា "សុខសប្បាយដែរ"។

**ស៖** ក្រោយពីការជួបគួរសមគ្នានេះ តើលោកមានពិភាក្សាជាមួយអ៊ំណាមួយអំពីតួនាទីរបស់ ខៀវ សំផន ដែរឬទេ? តើលោកដឹងទេថា លោក ខៀវ សំផន ជាសមាជិកក្រុមដែលជារាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានោះ?

**ឆ៖** ខ្ញុំអត់បានដឹងល្អិតទេ គឺថាខ្ញុំដឹងតួនាទីរបស់គាត់ គឺខ្ញុំស្តាប់វិទ្យុៗ។

**ស៖** តើលោកដឹងដោយផ្ទាល់ ឬក៏លោកគ្រាន់តែឮទេ ថាលោក ខៀវ សំផន គាត់មានតួនាទីនៅក្នុងកងទ័ពប្រជាជនរំដោះជាតិកម្ពុជា? តើលោកដឹងទេថា គាត់មានតួនាទីអ្វីដែរនៅក្នុងកងទ័ពនេះ?

**ឆ៖** ខ្ញុំដឹងតួនាទីគាត់ន៉ែ ច្បាស់ដែល -- គឺក្រោយៗដែលខ្ញុំថា បានជួបគាត់ ហើយគាត់ណែនាំ -- នៅផ្ទះរបស់គាត់ ហើយគាត់ពេលខ្លះគាត់ធ្វើការជាមួយអ៊ំ ប៉ុល ពត, អ៊ំ នួន ជា ហើយពេលខ្លះគាត់នៅនឹងផ្ទះគាត់ គាត់អង្គុយសរសេរ។ ឯតួនាទីគាត់ល្អិតហ្នឹង គឺថាខ្ញុំមិនបានចូលរួមប្រជុំប្រកាសជាឱឡារិក អង្កាល់ហ្នឹងនៅក្នុងព្រៃហ្នឹង អត់ទេ គឺខ្ញុំស្តាប់តាមវិទ្យុទេ។

[០៩:១០:០៧]

**ស៖** ពាក់ព័ន្ធទៅនឹងកងទ័ព គឺខ្ញុំចង់សំដៅលើកងទ័ពបដិវត្តន៍ ឬក៏កងទ័ពប្រជាជនរំដោះជាតិកម្ពុជា តើលោកដឹងទេថា អ្នកណាជាប្រមុខ ជាមេបញ្ជាការកងទ័ពនេះ?

**ឆ៖** ខ្ញុំឃើញ បើឃើញជា ៗរូបភាពជាក់ស្តែង ហើយឃើញអង្កាល់នោះអ៊ំ អៀង សារី គាត់មកធ្វើការនៅមន្ទីរ អង្កាល់ហ្នឹងមន្ទីរពួកខ្ញុំនៅកន្លែងមន្ទីរ គេហៅមន្ទីរក-៧ នៅធ្វើស្រែនោះ គាត់ប្រាប់ថា ខាងកងកម្លាំង -- អង្កាល់នោះមិនទាន់និយាយថាកងទ័ពអីទេ គេគ្រាន់តែថាកងចល័ត អង្កាល់នុ៎ង

គេនិយាយថាកងចល័ត គឺថាអង្គាល់ណោះឈ្មោះគាត់ ហៅថាឈ្មោះ ហៅ បងខាំ។ បងខាំ ទទួលខុសត្រូវខាងផ្នែកកងចល័តហ្នឹង។ ខ្ញុំដឹង -- ដំបូងគេខ្ញុំដឹងអ៊ីចឹង។ អាហ្នឹងគឺថានៅរតនគិរី។ អាហ្នឹង ចុង៧០ -- ៦៨ ហើយ។

**ស៖** យើងនឹងទៅឲ្យលឿនបន្តិច ព្រោះថាខ្ញុំមិនចាប់អារម្មណ៍ពីឆ្នាំ៧៨ទេ។ ខ្ញុំចង់ដឹងអំពីហេតុការណ៍ដែលកើតឡើង ក្រោយពីការផ្តួលរំលំសម្តេចនរោត្តមសីហនុ នៅពេលនោះតើមានៗបញ្ជាការរួមមួយសម្រាប់បញ្ជាកងទ័ព ឬក៏ថាមានទ័ពដែលត្រូវបានបញ្ជាទៅតាមភូមិភាគនីមួយៗ តើមានទីបញ្ជាការធំមួយដែរឬទេ ឬក៏មានទីបញ្ជាការតូចៗនៅតាមភូមិភាគនីមួយៗ?

[០៩:១៣:១២]

**ឆ៖** បើក្រោយពីរដ្ឋប្រហារ អង្គាល់រដ្ឋប្រហារហ្នឹងគឺថាខ្ញុំនៅមន្ទីរមួយ មន្ទីរមួយហ្នឹង ដែលខ្ញុំថា មន្ទីរពួកខ្ញុំហ្នឹងគឺថាធ្វើស្រែ ៗ។ ហើយកម្លាំង ដូចថាកម្លាំងកងទ័ព អង្គាល់ហ្នឹងគេមិននិយាយថាកងទ័ព គេថាកងចល័ត ឃើញកម្លាំងកងចល័តហ្នឹងគេមក នៅក្នុង៣០០នាក់ហ្នឹង គេ -- គាត់មកម្តង ១៥០នាក់ មកជួយៗស្ទូងស្រែ មកសម្រាកផង មកជួយស្ទូងស្រែហ្នឹង អ៊ីចឹង។ អង្គាល់ហ្នឹង បើនិយាយវា ៗវែងឆ្ងាយដែរ គឺថា សភាពការណ៍ផ្លូវដែលមកពីបរកែវមកអណ្តូងមាស ក៏អង្គាល់ហ្នឹងយើងថាខ្មាំង គឺថាខ្មាំងវាធ្វើសកម្មភាពដែរ ថាៗវារាតត្បាតដែរ។ ហើយផ្លូវមួយទៀតមកពីបរកែវ ទៅអូរយ៉ាដាវនោះ គេហៅផ្លូវ១៩ហ្នឹងថា ខ្មាំងរាតត្បាតដែរ ឃើញវារាតត្បាតដែរ។ ដល់អ៊ីចឹងកម្លាំងហ្នឹងគឺថា កម្លាំងចល័តនេះឃើញកម្លាំងហ្នឹងគេទទួលខុសត្រូវតាមផ្លូវទាំងពីរហ្នឹងឯង។ ព្រោះស្រែពួកខ្ញុំគឺនៅចន្លោះកណ្តាល។ ចន្លោះផ្លូវអណ្តូងមាស ហើយនិងផ្លូវ១៩ ព្រោះស្រែពួកខ្ញុំនៅកណ្តាល។ អាហ្នឹងគឺ ពេលហ្នឹងខ្ញុំមិនដឹងថាមេបញ្ជាការខាងលើពីណាៗទេ។ ព្រោះអត់ទាន់ឃើញឧទ្ទេសនាមអ្នកណាទេ។ ប៉ុន្តែកងចល័តនេះ ឃើញកម្លាំងនេះ វាមាននៅប្រមូលផ្តុំ ហើយមកធ្វើការស្ទូងស្រែពួកខ្ញុំហ្នឹង គឺនៅពេលហ្នឹងគឺឃើញអ៊ីចឹង។

[០៩:១៥:៣០]

**ស៖** ខ្ញុំសូមទៅឲ្យលឿនបន្តិច។ តើស្ថានភាពមានការផ្លាស់ប្តូរទេនៅពេលដែលមានវៀតណាមចាកចេញនៅឆ្នាំ៧៣ តើស្ថានការណ៍យ៉ាងម៉េចដែរ? មានផ្លាស់ប្តូរទេ មានផ្លាស់ប្តូរតួនាទីមេភូមិភាគ ឬក៏មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាហ្នឹងមានការផ្លាស់ប្តូរសមាសភាពដែរឬទេ ក្រោយពេលដែលវៀតណាមចាកចេញនៅឆ្នាំ៧៣ នោះ?

**ឆ៖** ឆ្នាំ៧៣ គឺថា ៧៣ នេះ មន្ទីរជាមូលដ្ឋានគឺនៅមន្ទីរស-៧១ ដដែល។ ប៉ុន្តែមន្ទីរចល័ត ដូចខ្ញុំបានរៀបរាប់ពីខាងដើមហ្នឹង គឺក្នុងដឹកនាំ ដូចអត់មានអីប្រែប្រួលអីទេ។ តាមភូមិភាគ ខ្ញុំក្តាប់អត់បានទេ ព្រោះខ្ញុំមិនទាន់ទៅណាទេកាលហ្នឹង គឺថាខ្ញុំតាមភូមិភាគ មិនទាន់នៃ--

[០៩:១៦:៥៧]

**ស៖** លោក ភី ភួន លោកបាននិយាយអំពីកិច្ចប្រជុំជាច្រើនរវាងអ៊ំៗ មានដូចជា ប៉ុល ពត, ខៀវ សំផន, នួន ជា, អៀង សារី ហើយនិងមេដឹកនាំផ្សេងៗទៀត។ តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេ ថានៅសម័យនោះ គឺលោកដឹងដោយផ្ទាល់អំពីកិច្ចប្រជុំទាំងអស់នោះ ឬក៏លោកគ្រាន់តែដឹងឮ មានន័យថា គឺមានអ្នកផ្សេងប្រាប់លោក មិនមែនលោកដឹងដោយផ្ទាល់ទេ។ តើលោកដឹង ឬក៏មានគេប្រាប់?

**ឆ៖** ក្នុងឆ្នាំ៧៣នេះ គឺថាកន្លែងខ្លះខ្ញុំដឹងដោយផ្ទាល់ខ្លួនឯង។ ខ្ញុំនិយាយនេះ ខ្ញុំនិយាយថាខ្ញុំបានទៅផ្ទាល់ខ្លួនឯងទេ។ ដែលខ្ញុំមិនបាន -- កន្លែងណាខ្ញុំមិនបានទៅនោះ ក៏អត់មានពីណានិយាយប្រាប់ខ្ញុំដែរទេ គឺថាខ្ញុំដឹងដោយខ្លួនឯងកន្លែងដែលខ្ញុំបានទៅ។

**ស៖** ចំពោះកិច្ចប្រជុំដែលថាលោកជាសាក្សីដោយផ្ទាល់ភ្នែក ដែលលោកឃើញផ្ទាល់នេះ តើលោកមានបានឃើញអំពីស្ថានភាពមួយដែលថានៅក្នុងកិច្ចប្រជុំនោះមានការខ្វែងគំនិតគ្នា ឬក៏ការមិនយល់ស្របគ្នារវាងអ៊ំៗ ដូចជា ប៉ុល ពត, ខៀវ សំផន ឬក៏រវាង ខៀវ សំផន, នួន ជា ឬក៏ នួន ជា និង អៀង សារី។ តើលោកមានចាំទេថា មានស្ថានភាពដែលអ៊ំៗទាំងអស់ហ្នឹង គាត់មានការពិភាក្សាគ្នា ហើយមានបញ្ហាខ្វែងគំនិតគ្នា ឬក៏ពួកគាត់តែងតែឯកភាពគ្នាទាំងស្រុង អត់ដែលមានបញ្ហាអីខ្វែងគំនិតគ្នាអីទេ?

[០៩:១៩:១៥]

**ឆ៖** តាំងពីគាត់ ខ្ញុំបានស្គាល់គាត់មក ហូរហែមក គឺថាមិនដែលអីគាត់ទំនាស់ទាស់ទែងគ្នាអត់មានទេ គឺថានៅក្នុងព្រៃហ្នឹង គឺថាសាមគ្គីគ្នា ល្អកល្អិន គឺថាអត់មានទេ អត់មានអីនេះទេ។ ព្រោះក្នុងឆ្នាំ៧៣នេះ ជាឆ្នាំមួយ ដែលដូចខ្ញុំបានបញ្ជាក់កាលមុន ខ្ញុំថាឆ្នាំ៧២ ខ្ញុំធ្វើដំណើរជាមួយគាត់ មកជាមួយអ៊ំ នួន ជា មកសំឡូត។ អាហ្នឹង អាហ្នឹងមួយដំណើរហ្នឹងវាវែងដែរ។

ប៉ុន្តែតែមុនហ្នឹងក្នុងឆ្នាំ៧១ហ្នឹង ខ្ញុំបានបញ្ជាក់ហើយថា មួយគឺបើកវគ្គទូទាំងប្រទេស នេះមួយកន្លែង ហើយរួចហ្នឹងហើយបានទៅធ្វើសន្និបាតនៅត្រពាំងព្រៃចន្លោះត្រពាំងទឹមហ្នឹង។ អាហ្នឹងគឺកន្លែងដែលខ្ញុំបញ្ជាក់អ៊ីចឹង។ មិនមែនខ្ញុំទៅនៅអង្គុយយាមតែរាល់តែថ្ងៃ មិនមានទេ គឺថាវាមានៗកន្លែងខ្លះមាន

វត្ថុមានរបស់ខ្ញុំ កន្លែងខ្លះក៏មានអ្នកវត្តមានក្នុងអង្គភាពនៅផ្សេងៗអ៊ីចឹងទៅ។ ដែលខ្ញុំរៀបរាប់ប្រាប់ហើយដែលខ្ញុំចូលរួមហ្នឹងគឺថា ពេលដែលខ្ញុំចូលរួម បានខ្ញុំដឹង បើពេលណាខ្ញុំអត់ចូលរួម ខ្ញុំអត់ដឹងទេ។ អ៊ីចឹងបានថា ដែលប្រជុំប-៥ហ្នឹង ខ្ញុំយាម ខ្ញុំប្រាប់ថាខ្ញុំយាម។ កាលប្រជុំវិហារព្រះកែវហ្នឹង ខ្ញុំថាខ្ញុំយាម ហើយខ្ញុំយាម ខ្ញុំដឹង អាហ្នឹងខ្ញុំប្រាប់តែកន្លែងណាដែលខ្ញុំដឹងទេ។ ខ្ញុំមិនមែនដឹងគ្រប់អង្គប្រជុំ គ្រប់នេះទាំងអស់ទេ ដឹងដោយចន្លោះៗអ៊ីចឹង។ កុំឲ្យលោកយល់ច្រឡំចំណុចនេះ អត់ទេ។

[០៩:២១:២១]

**ស៖** តើលោកដឹងទេថាមានមធ្យោបាយដែលអាចឲ្យផ្លាស់ប្តូរលិខិតឆ្លើយឆ្លងគ្នា រវាងអ្នកដែលនៅជាមួយកម្លាំងនៅក្នុងប្រទេស ហើយនិងឥស្សរជនដែលនៅក្រៅប្រទេស? តើមានមធ្យោបាយអីសម្រាប់ឲ្យពួកគាត់ទាក់ទងគ្នា ដែលគេប្រើប្រាស់នៅពេលនោះសម្រាប់ ឧទាហរណ៍ដូចជាទាក់ទងលោក អៀង សារី នៅពេលគាត់នៅចិន ឬក៏មធ្យោបាយដែលលោក អៀង សារី គាត់ប្រើប្រាស់ដើម្បីទាក់ទងមកបុគ្គលដែលនៅក្នុងប្រទេសកម្ពុជានោះ?

**ឆ៖** ការឆ្លើយឆ្លងបែបហ្នឹង ខ្ញុំឃើញថា មានៗ ព្រោះយើងមានអី? គឺថាយើងមានទូរ -- គេហៅទូរលេខ១៥វ៉ាត់, ទូរលេខ២វ៉ាត់ ថាវាមាន ដូច្នេះមានការទាក់ទង។ ទាក់ទងខាងក្រៅក៏មាន ទាក់ទង -- ៧៣ហើយ គឺទាក់ទងពីភូមិភាគមួយទៅភូមិភាគមួយក៏មានដែរ គេមានៗហើយអាហ្នឹង។ ព្រោះអ្នកធ្វើការយើងដឹងថា វាមានការទាក់ទងអ៊ីចឹងបានវាមានអ្នកធ្វើការក្នុងដំណើរមួយៗ វាមានអ៊ីចឹង។

**ស៖** ការទាក់ទងគ្នានេះ គឺថាភាគច្រើនធ្វើឡើងដោយ -- តាមរយៈទូរលេខ តើមែនទេលោក?

**ឆ៖** បាទ តាមរយៈទូរលេខបាទ។

**ស៖** ខ្ញុំគិតថា ដើម្បីរៀបចំដំណើរទស្សនកិច្ចរបស់សម្តេច សីហនុ នៅឆ្នាំ៧៣ នោះគឺមានការផ្លាស់ប្តូរទូរលេខគ្នាយ៉ាងច្រើន។ តើលោកមានចូលរួមនៅក្នុងការរៀបចំដំណើររបស់សម្តេចសីហនុ ទេនៅពេលនោះ?

[០៩:២៣:៥៧]

**ឆ៖** ខ្ញុំបានទៅ ពេលសម្តេចឪមកទស្សនកិច្ចតំបន់រំដោះឆ្នាំ៧៣។ ៧៣ហ្នឹង ខ្ញុំទៅចូលរួម ទៅទទួលតាំងពីស្រុក គេហៅថាស្រុកសៀមប៉ាងឯណោះ ខេត្តរតនគិរីឯណោះ។ តាំងពីនុ៎ងមករហូតមកដល់សៀមរាបរហូតដល់ជូនទៅវិញ។ ខ្ញុំបានចូលរួមក្នុងនុ៎ង។ ខ្ញុំបានចូលរួមហ្នឹង គឺថាខ្ញុំការពារផ្ទាល់ផងសម្តេចឪនេះ ខ្ញុំការពារផ្ទាល់នៅកៀកជាមួយគាត់ហ្នឹង គឺការពារផ្ទាល់តែម្តង។

[០៩:២៤:៥២]

**ស៖** តើលោកធ្លាប់ឮអំពីសមាជជាតិពិសេសកម្ពុជា ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៤, ២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ក្រោមអធិបតីភាពរបស់លោក ខៀវ សំផន ដែរឬទេ? តើលោកធ្លាប់ឮអំពីសមាជជាតិពិសេសនៅខែកុម្ភៈ ឆ្នាំ៧៥ ដែលមានលោក ខៀវ សំផន ជាប្រធានដែរឬទេ ក្នុងឋានៈគាត់ជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា?

**ឆ៖** ឮប្រកាសតាមវិទ្យុហ្នឹង ខ្ញុំឮ ខ្ញុំស្ដាប់ ប៉ុន្តែកន្លែងគាត់ប្រកាសហ្នឹង ខ្ញុំអត់បានដឹងទេ។ ខ្ញុំបានស្ដាប់តាមវិទ្យុដែរ។

**ស៖** នៅពេលដែលលោកឮគេប្រកាសនោះ តើលោកមានដឹងអំពីបញ្ជីនៃមហាជនក្បត់ទាំងប្រាំពីរនាក់ដែរឬទេ?

[០៩:២៦:១១]

**ឆ៖** ខ្ញុំមិនបានចាប់អារម្មណ៍រឿងអ្នកក្បត់ប្រាំពីរនាក់អីទេ។ អត់ ខ្ញុំអត់បានចាប់អារម្មណ៍ផង។

**ស៖** ក្រោយពីការដួលរំលំទីក្រុងភ្នំពេញ តើមេដឹកនាំមានធ្វើសេចក្ដីប្រកាសនៅតាមវិទ្យុអីទេ នៅក្រោយពីភ្នំពេញដួលរលំនោះ?

**ឆ៖** វិទ្យុបានប្រកាសតើ! គឺថាគ្រប់មុខព្រួញគឺថាម៉ោងប្រាំបួនកន្លះព្រឹកបានរំដោះទីក្រុងភ្នំពេញ ១៧ មេសា ៧៥ហ្នឹង ប្រកាសតាមវិទ្យុនៅឮតើ ជួបជុំគ្នានៅកណ្ដាលទីក្រុងភ្នំពេញហ្នឹង។ មានវិទ្យុប្រកាសដែរតើ។

**ស៖** តើគេប្រកាសហ្នឹង គឺប្រកាសទៅឲ្យអ្នកណាស្ដាប់ ហើយអ្នកណាជាអ្នកប្រកាសនុ៎ង?

[០៩:២៧:៥៥]

**ឆ៖** គេប្រកាសហ្នឹង គឺថា ចេញសេចក្ដីប្រកាសហ្នឹងគឺប្រកាសឲ្យជាតិទាំងមូលស្ដាប់ អន្តរ-ជាតិទៀតក៏ស្ដាប់។ អង្កាល់នុ៎ង មានវិទ្យុរបស់ខ្លួនដែរតើ មានវិទ្យុប្រកាសដែរ។ ដែលផ្នែកកងទ័ពគឺ អ៊ំ ខៀវ សំផន ហ្នឹងហើយ គាត់អ្នកប្រកាសនុ៎ង ក្នុងគាត់ឧបនាយករដ្ឋ គាត់ជាមេបញ្ជាការក្នុងរណសិរ្សរួបរួមជាតិកម្ពុជាពេលនុ៎ង។

**ស៖** តើលោកមានធ្លាប់ឮអំពីសមាជជាតិពិសេសរបស់តំណាងអង្គការមហាជនកម្ពុជា កម្លាំងទ័ពទាំងបីផ្នែក ព្រះសង្ឃ ហើយនិងរណសិរ្សរួបរួមជាតិកម្ពុជា គឺថាជាសមាជដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៥, ២៦, ២៧ ខែកក្កដា ឆ្នាំ១៩៧៥ ក្រោមអធិបតីភាពរបស់លោក ខៀវ សំផន លោកធ្លាប់ឮអំពី

សមាជជាតិពិសេសនេះទេ?

[០៩:២៩:៣៧]

**ឆៈ** ខ្ញុំឮៗតាមវិទ្យុហ្នឹង គឺឮសេចក្តីប្រកាសរបស់គាត់តាមវិទ្យុហ្នឹង គឺៗឮ។

**សៈ** តើលោកមានចាំអីខ្លះទេពីការ -- ពីសមាជនេះ? ប្រសិនបើលោកមិនចាំទេ មិនអីទេ។

**ឆៈ** ខ្ញុំអត់បានចាំទេ។

**សៈ** សម្រាប់ជាប្រតិចារឹកនោះ ខ្ញុំគិត -- ខ្ញុំសូមបញ្ជាក់ថា នេះគឺជាសមាជិកជាតិពិសេសកម្ពុជា ដែលបានប្រព្រឹត្តនៅថ្ងៃទី២៤, ២៥ ខែកុម្ភៈ ឆ្នាំ៧៥ ក្រោយអធិបតីភាពរបស់លោក ខៀវ សំផន គឺមាននៅក្នុងឯកសារលេខ D108/43/3 ហើយចំពោះសេចក្តីប្រកាសនៅក្នុងវិទ្យុ ក្រោយពីការដួលរំលំទីក្រុងភ្នំពេញនោះ គឺនៅក្នុងឯកសារលេខ D359/1/1.37 ហើយនិង ឬក៏ជាឯកសារ E3/18។ ឥឡូវនេះ ខ្ញុំចង់និយាយលម្អិតបន្តិច អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ លោកបានឆ្លើយកាលពីប៉ុន្មានថ្ងៃមកនេះហើយថា ការជម្លៀសនេះ គឺត្រូវបានលើកឡើងនៅក្នុងកិច្ចប្រជុំជាច្រើន។ ជាពិសេស លោកបាននិយាយអំពីកិច្ចប្រជុំដ៏ធំមួយ ដែលបានប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ៧៤ ហើយដែលជាកិច្ចប្រជុំរបស់គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ហើយនៅក្នុងកិច្ចប្រជុំនោះដែរ លោកបានលើកឡើងថា មានវត្តមានរបស់លោក អៀង សារី ផងដែរ។ តើលោកអាចបញ្ជាក់បានទេ ថានៅក្នុងប្រជុំនៅក្នុងព្រៃឆ្នាំ៧៤នេះ គេបានលើកឡើងអំពីបទពិសោធន៍ នៃការជម្លៀសប្រជាជននៅតំបន់រំដោះ? ខ្ញុំចង់សំដៅទៅដល់ឧដុង្គ, ស្គន់, ស្ទឹងត្រែង, ក្រចេះ, បាណាម ឬក៏ក្រុងផ្សេងៗទៀត។ តើលោករក្សាចម្លើយនេះ ឬក៏លោកអាចមានអ្វីត្រូវបញ្ជាក់បន្ថែម?

[០៩:៣២:២៩]

**ឆៈ** ខ្ញុំអត់មានអីឆ្លើយទៀតទេ ដូចខ្ញុំបានរៀបរាប់បន្តបន្ទាប់មក អត់មាន -- វែកញែកអីទៀតចំណុចនេះ។

**សៈ** នៅពេលដែលលោកនិយាយថា យើងបាននិយាយអំពីបទពិសោធន៍នៃការជម្លៀសពីទីក្រុងទាំងអស់នេះ។ ខ្ញុំសន្មតថា លោកចង់និយាយថា វាជាន័យវិជ្ជមាន គឺបានន័យថា ការជម្លៀសទាំងអស់នេះ មានឥទ្ធពលវិជ្ជមានទៅលើផ្នែកផែនការយោធា ហើយនិងផ្នែកផែនការបដិវត្តន៍។ តើលោកអាចបញ្ជាក់បំភ្លឺបន្តិចបានទេ ទាក់ទងទៅនឹងផលប៉ះពាល់វិជ្ជមាននេះ?

**ឆ៖** ចំណុចនេះ ដូចខ្ញុំបានបញ្ជាក់បន្តបន្ទាប់ហើយថា ខ្ញុំដឹងតែ ខ្ញុំគ្រាន់តែថាពាក្យ ជម្លៀស តែមួយមាត់ហ្នឹងទេ ដែលខ្ញុំដឹង។ ពេលដែលគាត់ជាមតិហ្នឹង នៅមន្ទីរ ប-៥។ ខ្ញុំដឹងតែម្តងហ្នឹង អាហ្នឹង។ ឯវត្ថុមានផ្សេងៗទៀត អត់ដឹងទេ។ អត់បានដឹងល្អិតទេ។ ដឹងតែម្តងហ្នឹង។

[០៩:៣៤:១៣]

**ស៖** នៅពេលដែលគេស្តាប់ចម្លើយលោកនៅថ្ងៃព្រហស្បតិ៍មុននេះ លោកបានលើកឡើងផងដែរថា អំពីវគ្គសិក្សា ឬក៏វគ្គបណ្តុះបណ្តាល ដែលប្រហែលជាក្រោយអធិបតីភាពរបស់ ប៉ុល ពត, នួន ជា ឬក៏ ខៀវ សំផន។ គឺនៅក្នុងប្រតិចារឹក ឬក៏ពង្រាងប្រតិចារឹក ថ្ងៃព្រហស្បតិ៍ ២៦ កក្កដា នៅម៉ោង ១១:០៤ នាទី លោកបាននិយាយដូច្នេះ "ខ្ញុំបានដឹងរឿងនេះ ដោយបទឧទ្ទេសនាមរបស់គាត់នៅក្នុងវគ្គរៀនសូត្រ។ ប៉ុល ពត, នួន ជា ឬ ខៀវ សំផន បានធ្វើបទបង្ហាញទាំងអស់នេះ គឺជាបទពិសោធន៍ដែលគាត់បានដកស្រង់យក ហើយយើងបានយកប្រយោជន៍ពីបទពិសោធន៍វិជ្ជមានរបស់គាត់នេះ ដើម្បីរំដោះទីក្រុងភ្នំពេញ គឺតាមរបៀបនេះហើយ ដែលខ្ញុំបានសិក្សា"។ តើលោកអាចបញ្ជាក់ ជាបឋមថា អ្នកទាំងបីនាក់នេះ ខ្ញុំមិនដឹងថា មានតែម្នាក់ ឬក៏បែងចែកដាច់ពីគ្នាទេ ថាតើអ្នកទាំងបីនាក់នេះ ពិតជាបានធ្វើបទបង្ហាញពីបទពិសោធន៍ល្អរបស់គាត់ ទាក់ទងនឹងការជម្លៀសមនុស្សចេញពីទីក្រុង?

[០៩:៣៥:៤៧]

**ឆ៖** ចំណុចនេះ ដូចខ្ញុំបញ្ជាក់ជូនហួរហែមកថា គឺគាត់ទាំងបីនាក់នេះ ជាអចិន្ត្រៃយ៍គឺថា មុនរំដោះភ្នំពេញ បើថានៅក្នុងមន្ទីរគាត់នៅជាអចិន្ត្រៃយ៍តែបីនាក់។ ដល់ក្រោយរំដោះភ្នំពេញហើយ ជាអចិន្ត្រៃយ៍គាត់នៅតែបីនាក់ដែរ គឺអ៊ីចឹង។ ខ្ញុំថា ខ្ញុំអត់មានអីត្រូវវែកញែកអីទៀតទេចំណុចនេះ ខ្ញុំថា ខ្ញុំបានបញ្ជាក់បន្តបន្ទាប់ហើយ វាច្រំដែលៗ ដូចអត់មានអីក្រៅពីហ្នឹងទៀតទេ។

**ស៖** បាទ សូមបំភ្លឺមួយលោកសាក្សី។ កិច្ចប្រជុំបណ្តុះបណ្តាល ឬក៏វគ្គសិក្សាដែលលោកបាននិយាយនេះ តើវាប្រព្រឹត្តទៅនៅពេលមុនដណ្តើមបានភ្នំពេញ ឬក៏ពេលក្រោយដណ្តើមបានភ្នំពេញហើយ ឬក៏ទាំងមុន ហើយនិងក្រោយពេលដណ្តើមបានទីក្រុងភ្នំពេញ?

[០៩:៣៧:១១]

**ឆ៖** មុនរំដោះភ្នំពេញ ខ្ញុំបានបញ្ជាក់ថា ដើមខែមេសា ចន្លោះហ្នឹងៗដើមខែមេសាហ្នឹង មុនរំដោះភ្នំពេញ។ ក្រោយរំដោះភ្នំពេញនេះ ខ្ញុំបញ្ជាក់ថា នៅវិហារព្រះកែវ ខ្ញុំដឹងតែអាពីរហ្នឹងទេ ពីរហ្នឹងទេ ហើយខ្ញុំបានរៀបរាប់ -- ប៉ុន្មានថ្ងៃនេះខ្ញុំបានរៀបរាប់ហើយអស់ហើយចំណុចនេះ។ ល្អិតជាងហ្នឹងទៀត

ខ្ញុំអត់មានអីនឹងឆ្លើយ បើថាមិនជាក់ស្តែង ខ្ញុំមិនដឹងជាឆ្លើយយ៉ាងម៉េចទេ។ ខ្ញុំដឹង ខ្ញុំបានឮបានដឹង ខ្ញុំ -- ដឹងប៉ុន្មាន ខ្ញុំឆ្លើយប៉ុណ្ណឹង។

**ស៖** បាទ ដូច្នេះលោកសាក្សី លោកពិតជាបាននិយាយអំពីកិច្ចប្រជុំធំមួយ ឬក៏សំខាន់មួយ ដែលប្រព្រឹត្តទៅនៅប-៥ នៅដើមខែមេសា ឆ្នាំ១៩៧៥ តើការប្រជុំរៀនសូត្រ ដែលលោកបានប្រជុំរៀបរាប់ដែរនោះ ខុសពីកិច្ចប្រជុំនៅដើមខែមេសា ឆ្នាំ៧៥ នោះ ឬក៏យ៉ាងម៉េច? ហើយកើតមុន ឬក៏កើតក្រោយ?

**ឆ៖** សំណួរលោកនេះ ខ្ញុំអត់យល់ទេ។ ខ្ញុំអត់យល់ ដូចខ្ញុំបានបញ្ជាក់បន្តបន្ទាប់ហ្នឹងគឺថា អត់យល់ទៀតទេ ត្រឡប់ត្រឡិនពេក គឺខ្ញុំអត់យល់ទេ។

[០៩:៣៨:៥៩]

**ស៖** លោកសាក្សី លោកបានពន្យល់យ៉ាងលម្អិត ហើយយ៉ាងយូរអំពីរបៀបកិច្ចប្រជុំនៅដើមខែមេសា ឆ្នាំ១៩៧៥ ហើយលោកក៏បានរៀបរាប់ផងដែរ អំពីវគ្គរៀនសូត្រ ឬក៏វគ្គបណ្តុះបណ្តាល។ តើនេះជារឿងពីរខុសគ្នា ឬក៏ដូចគ្នាទេកិច្ចប្រជុំនេះ? តើអាកិច្ចប្រជុំរៀនសូត្រហ្នឹងខុសគ្នា ពីប្រជុំខែមេសាហ្នឹង តើអាកិច្ចប្រជុំរៀនសូត្រតូចៗហ្នឹង កើតមុនកិច្ចប្រជុំខែមេសាហ្នឹង ឬក៏កើតក្រោយកិច្ចប្រជុំខែមេសា?

**ឆ៖** ចលនាទាំងមូល រំដោះប្រទេសទាំងមូល។ លោកទៅឆ្ងល់អាអីចឹងៗ រឿងគេប្រជុំល្អិតហ្នឹង គេមានគេប្រជុំល្អិតល្អន់ហ្នឹង ប្រជុំហ្នឹងហើយ សម្រាប់ជាតិគេ សម្រាប់ប្រជាជនគេ។ តើលោកចង់ដឹងអីទៀតចំណុចហ្នឹង បើគេប្រាប់បន្តបន្ទាប់ហើយ។

**ប្រធានអង្គជំនុំ៖**

លោកសាក្សីរៀបចំសម្រួលអារម្មណ៍របស់លោកឲ្យបានស្រួល ហើយក្នុងករណីដែលសាក្សីបញ្ជាដែល -- អ្វីដែលសាក្សីមិនដឹង គឺសាក្សីអាចឆ្លើយថាមិនដឹងទេបញ្ហាទ៎ុង។ លោកមិនគប្បីប្រើអាកប្បកិរិយាដូចអម្បាញ់មិញនេះទេ គឺអាចឆ្លើយតប ហើយនិងមិនឆ្លើយតបក្នុងករណីដែលលោកមិនបានដឹង។ ហើយលោកបានឆ្លើយច្បាស់លាស់ហើយថា អ្វីដែលលោកដឹងផ្ទាល់ ទើបលោកយកមកនិយាយ។ ហើយអ្វីដែលមិនដឹងទេ ផ្ទាល់ទេ គឺលោកមិនបាននិយាយទេ ដូចហេតុការណ៍នៃកិច្ចប្រជុំផ្សេងៗ ដែលមាន គឺមានច្រើន តែលោកលើកតែប៉ុន្មានប្រជុំ ដោយសារកិច្ចប្រជុំទាំងនោះ គឺលោកបានដឹងដោយផ្ទាល់។

[០៩:៤១:២១]

សូមអញ្ជើញលោកចៅក្រម! សូមលោកចៅក្រមសម្រួលនូវសំណួរ ដែលជាងាយ ជាការងាយ ពីព្រោះកម្រិតសំណួរអាចឆ្លងកាត់ការបកប្រែទៀត ការស្តាប់ពិតជាលំបាកមែន។ បើគិតជាភាសាខ្មែរ ហ្នឹង គឺពិបាកយល់នូវខ្លឹមសារនៃសំណួររបស់លោកដែរ។ អ៊ីចឹងសម្រួលសំណួរ ដើម្បីឱ្យភាពសាមញ្ញ ខ្លីៗទៅ ដើម្បីងាយឆ្លើយតប។ ស្តាប់យល់ ទើបអាចឆ្លើយតបបាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំព្យាយាមសួរខ្លីៗ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បាទ ដើម្បីសម្រួលសំណួរខ្ញុំអម្បាញ់មិញ លោកសាក្សីមុនពេលដណ្តើមបានទីក្រុងភ្នំពេញ តើលោកជាសាក្សីពីកិច្ចប្រជុំជាច្រើន ដែលនៅក្នុងកិច្ចប្រជុំទាំងអស់នោះ ប៉ុល ពត ឬក៏ នួន ជា ឬក៏ ខៀវ សំផន បានធ្វើបទបង្ហាញអំពីបទពិសោធន៍ការជម្លៀសទីក្រុងរបស់ខ្លួន។

[០៩:៤២:៤០]

**លោក រ៉ាចាម តុន៖**

**ឆ៖** ចំណុចនេះ ខ្ញុំអត់បានអត្ថាធិប្បាយទៀតទេ ខ្ញុំសូមថាអត់ឆ្លើយទេ។ ឆ្លើយទៀតនាំតែទាស់សម្តីគ្នាទៀតហើយ។ ខ្ញុំអត់បានឆ្លើយទេ។

**ស៖** ខ្ញុំមិនចង់ឱ្យលោកនិយាយផ្ទុញខ្លួនឯងនោះទេ ប៉ុន្តែខ្ញុំគ្រាន់តែលោកបំភ្លឺរឿងរ៉ាវតែប៉ុណ្ណោះ។ អ្វីដែលច្បាស់លាស់នោះ គឺយើងបាននិយាយយ៉ាងយូរអំពីកិច្ចប្រជុំដែលកើតមានឡើងនៅដើមខែមេសា ឆ្នាំ១៩៧៥ ហើយលោកក៏បាននិយាយផងដែរ អំពីកិច្ចប្រជុំផ្សេងទៀត។ ដូច្នេះហេតុអ្វីក៏លោកខ្លាចនិយាយទៅ ជាន់កែងខ្លួនឯង។ ខ្ញុំមិនយល់ -- ខ្ញុំគ្រាន់តែចង់យល់ថា តើលោកចង់យោងទៅលើកិច្ចប្រជុំមួយណាតែប៉ុណ្ណោះទេ?

**ឆ៖** អម្បាញ់មិញខ្ញុំបានឆ្លើយប្រាប់ហើយ ខ្ញុំថាប្រជុំនៅប-៥ ដើមខែមេសា បានពិភាក្សាពីរឿងជម្លៀសប្រជាជន។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ ដល់លោកសួរល្អិតទៀត ខ្ញុំថាខ្ញុំអត់មានអីនិយាយទៀត ចំណុចហ្នឹងគឺថា ខ្ញុំដឹងតែត្រួសៗប៉ុណ្ណឹងទេ។ ហើយប្រជុំបន្តបន្ទាប់ទៀត គេប្រជុំជាវគ្គរៀនសូត្រ ខ្ញុំប្រាប់ហើយ។ តែរៀនសូត្រហ្នឹង គឺថាពាក្យថា "រៀនសូត្រ" ហ្នឹងគឺរៀនៗទស្សនៈសភាពការណ៍ ឧទ្ទេសនាមទស្សនៈសភាពការណ៍ពិភពលោក ឧទ្ទេសនាមទស្សនៈសភាពការណ៍ក្នុងប្រទេស អាហ្នឹង ហើយការងារកសាងបក្ស ហ្នឹង។ ហើយបានធ្វើជីវទស្សនៈបដិវត្តន៍ ហើយបាននេះហើយ បានលើកទិសវិធានការ

តទៅទៀត កែលម្អតទៅទៀត។ នេះខ្ញុំចង់ជម្រាបលោកគឺថា ព្រោះខ្ញុំស្តាប់សំណួរលោកសួរហ្នឹង គឺថា ដដែលៗៗ។ ដែលខ្ញុំឆ្លើយហើយហ្នឹង ដដែលទៀត។ ឆ្លើយហើយ នៅដដែលទៀត។ ខ្ញុំមិនដឹងជាឆ្លើយថាម៉េច។

[០៩:៤៥:៣២]

**ស៖** បាទ ឥឡូវយើងសូមត្រឡប់មកនិយាយអំពីកិច្ចប្រជុំដើមខែមេសា ឆ្នាំ១៩៧៥ វិញ។ បើសិនជាខ្ញុំយល់មិនច្រឡំទេអំពីការប្រព្រឹត្តទៅនៃកិច្ចប្រជុំនេះ ថាកិច្ចប្រជុំនេះទាក់ទងទៅនឹងអ្នកដឹកនាំសំខាន់ៗនៃបក្សកុម្មុយនីស្តកម្ពុជា ហើយក៏ទាក់ទងផងដែរអំពីថ្នាក់ដឹកនាំភូមិភាគ ហើយថែមទាំងមេកងពលផងដែរ។ តើលោកអាចបញ្ជាក់អំពីការខ្លឹមសារនៃកិច្ចប្រជុំនោះបានទេ ថាមានអ៊ីចឹងមែន?

**ឆ៖** ថ្ងៃមុននេះខ្ញុំបញ្ជាក់អ៊ីចឹងហើយតើ! ខ្ញុំបានបញ្ជាក់ហើយ ចំណុចហ្នឹងបានជាខ្ញុំ ខ្ញុំមិនចង់និយាយសាដើមដដែលៗហ្នឹង។ ថ្ងៃមុនសួរបញ្ជាក់ចុះបញ្ជាក់ឡើងហ្នឹង ខ្ញុំក៏ -- ឲ្យឆ្លើយដដែល។ ឥឡូវថ្ងៃនេះ សួរដដែលហ្នឹងទៀត។ ខ្ញុំយល់ឃើញតែដដែលទេ។ ព្រោះថ្ងៃមុនបាននិយាយហើយ មិនដឹងនិយាយអីទៀតថ្ងៃនេះ។

[០៩:៤៦:៥៨]

**ស៖** បាទ ជួនកាលហ្នឹងយើងត្រូវការព័ត៌មានលម្អិត ពីព្រោះថាយើងមានការបកប្រែជាបីភាសា សំណៅបីភាសា អ៊ីចឹងវាអាចមានភាពខុសគ្នារវាងភាសាអង់គ្លេស ភាសាបារាំង ភាសាខ្មែរ។ លោកហាក់ដូចជាបាននិយាយថា ប្រជុំនេះបានចាប់ផ្តើមឡើងដោយបទបង្ហាញអំពីបទពិសោធន៍របស់ម្នាក់ៗទាក់ទងនឹងការជម្លៀសមនុស្សចេញពីទីក្រុង។ ហើយបន្ទាប់មកទៀតលោកបានប្រាប់ថានៅក្នុងកិច្ចប្រជុំនេះមានៗផែនដីមួយដែលគេបិទបង្ហាញ ហើយលោកក៏បានបង្ហាញដែរថា មានរូបតារាងពណ៌ខ្មៅមួយ -- រូបពណ៌ខ្មៅមួយ ដែលមានការកត់ -- ក្តារខៀន មានក្តារខៀនពណ៌ខ្មៅ។ តើលោកអាចបញ្ជាក់ថា កិច្ចប្រជុំនេះប្រព្រឹត្តទៅយ៉ាងដូច្នេះមែន គឺថាចាប់ផ្តើមដោយមានការបង្ហាញពីបទពិសោធន៍ជម្លៀស ហើយបន្ទាប់មានការពិភាក្សាគ្នាអំពីផែនទី ហើយនិងការពិភាក្សាអំពីការចង្អុលបង្ហាញដែលមានគូសបញ្ជាក់នៅលើក្តារខៀនពណ៌ខ្មៅ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនអ៊ីចឹងហើយ មានអីទៀតទេ។

**ស៖** ផែនទីនុ៎ង តើជាផែនទីប្រទេសកម្ពុជា ឬក៏ផែនទីទីក្រុងភ្នំពេញ ឬក៏គេគូសផែនទីទីក្រុងភ្នំពេញនៅលើក្តារខៀននុ៎ង?

[០៩:៤៨:៥១]

**ឆ៖** មិនមានជាផែនទីទេ គ្រាន់ថា មានក្តារខៀន គឺគូសវាស គឺថាមុខព្រួញណាទៅជម្លៀសចេញទៅតាម តាមមុខព្រួញណាៗ គ្រាន់តែគូសវាសក្នុងក្តារហ្នឹង។ ក្តារខៀនដើម្បីអ្នកស្តាប់ហ្នឹងវាឆាប់យល់។ ឲ្យឆាប់យល់ មិនមែនជាផែនទីកម្ពុជាអីទេ។ គ្រាន់តែគូសវាសនឹងក្តារខៀនហ្នឹង។ អ៊ីចឹងទេ។

**ស៖** តើមានការបញ្ជាផ្នែកយោធាទៅអ្នកចូលរួមថាត្រូវមានកម្លាំងឈានមុខណា ហើយនិងកងពលណាត្រូវចូលមកទីក្រុងភ្នំពេញនៅកន្លែងណា ហើយដើម្បីធានាខុសត្រូវនៅផ្នែកណាមួយ តំបន់ណាមួយ តើមានទិសដៅយុទ្ធសាស្ត្រដែលបានកំណត់ដែរឬទេចំពោះកម្លាំងយោធាទាំងអស់នេះ?

**ឆ៖** ជាគោលការណ៍ គឺថាវាមានៗ កំណត់មុខសញ្ញាមួយៗនោះ។ មុខសញ្ញាតាមភូមិភាគហ្នឹងក៏វាមាន មុខសញ្ញាកងពលមួយៗហ្នឹង ក៏លម្អិតក្នុងហ្នឹងក៏វាមានៗ។ បានទៅដល់ទិសដៅហ្នឹង បានគេហៅថា រំដោះទីក្រុងភ្នំពេញទាំងស្រុងហើយអ៊ីចឹង។

**ស៖** តើលោកចាំអំពីទីតាំងនៃកងពលផ្សេងៗនៅពេលនោះទេ។ តើមានកងពលណាខ្លះដែលចូលរួមក្នុងការដណ្តើមទីក្រុងភ្នំពេញ ហើយមានផ្នែកខ្លះ -- មានមុខព្រួញណាខ្លះដែលប្រគល់ឲ្យកងពលនីមួយៗនោះ?

**ឆ៖** ខ្ញុំមិនចាំល្អិតទេ ពីនុំងមកដល់ឥឡូវវាសាមសិបប្លាយឆ្នាំទៅហើយ អត់ចាំទេ។ ល្អិត គឺអត់ចាំទេ។ រាប់ជាភូមិភាគទៅ អាហ្នឹងវាងាយជាង ភូមិភាគ។ ព្រោះវ៉ៃរំដោះទីក្រុងភ្នំពេញ វាគ្រប់កម្លាំងគ្រប់ភូមិភាគទាំងអស់ដែលចូលមក បានរំដោះទាំងស្រុងហ្នឹងបាទ។

[០៩:៥២:១៧]

**ស៖** ខ្ញុំសន្មតថាការបែងចែកមុខព្រួញនៅភ្នំពេញហ្នឹង គឺថាមានកំណត់តាមភូមិភាគ តាមកងពល។ ឧទាហរណ៍លោកនិយាយថា យោធារបស់ កុយ ធួន ហ្នឹងទទួលបន្ទុកផ្លូវណាមួយ។ ហើយតើកងពលផ្សេងទៀតនុំងមានទទួលខុសត្រូវលើផ្លូវផ្សេងទៀតទេ? តើលោកចាំពីបញ្ហាទាំងអស់នេះទេ ឬក៏លោកភ្លេចអស់ហើយ អំពីព័ត៌មានលម្អិតផ្នែកយោធានេះ?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ វាយូរឆ្នាំពេកហើយ មិនបានគិតអាហ្នឹងផង។

**ស៖** តើនៅក្នុងកិច្ចប្រជុំនេះ ឬក៏កិច្ចប្រជុំផ្សេងទៀត មានការនិយាយអំពីការភ័យខ្លាច ការទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញដែរឬទេ? មានហានិភ័យបែបនេះ?

**ឆ៖** មានលើកពីបញ្ហានេះ គេលើកគឺថា វាអាចកន្លែងខ្លះ វាអាចប្រើកប៉ាល់ហោះ ណេះយើង

ត្រូវប្រយ័ត្ន។ ហើយជាក់ស្តែង វាប្រើជាក់ស្តែង យើងឃើញហើយ។ នៅកំពង់សោម វាប្រើ។ នៅសៀមរាប វាប្រើ។ អាហ្នឹងឃើញជាក់ស្តែងអ៊ីចឹង។

[០៩:៥៤:១៩]

**ស៖** បើគេនិយាយអំពីការទម្លាក់គ្រប់បែកនៅសៀមរាប ហើយនិងនៅកំពង់សោមនេះ តើៗគេមាននិយាយអំពីគ្រោះថ្នាក់ក្នុងការទម្លាក់គ្រប់បែកនៅទីក្រុងភ្នំពេញដែរឬទេ នៅពេលដែលដណ្តើមបានទីក្រុងភ្នំពេញ?

បើសិនជាលោកមិនចាំទេ លោកនិយាយថា "លោកមិនចាំ"។ គ្មានបញ្ហាអ្វីទេ ខ្ញុំមិនចង់ដាក់ឲ្យលោកស្ថិតនៅក្នុងស្ថានភាពលំបាកទេលោក។

**ឆ៖** ខ្ញុំអត់ចាំទេ។

**ស៖** តើលោកបានឮនិយាយ -- មានគេឲ្យបញ្ជា -- ចេញបញ្ជាថា សូមឲ្យផ្សព្វផ្សាយសារដល់ប្រជាជន ហើយនិងប្រើមធ្យោបាយដូចជាប្រើមីក្រូប្រកាស។ តើវិធានការនេះត្រូវគេបានពិភាក្សាដែរឬទេ? តើលោកអាច -- ដែលឮគេនិយាយពីបញ្ហានេះនៅក្នុងកិច្ចប្រជុំខែមេសាហ្នឹង ឬក៏កិច្ចប្រជុំផ្សេងទៀតដែរឬទេ?

**ឆ៖** អត់មានទេ អត់មានដឹងទេ។

**ស៖** តើលោកបានឮគេឲ្យ -- គេចេញបញ្ជាទាក់ទងទៅនឹងការពន្យល់ដែលត្រូវពន្យល់ទៅប្រជាជនដែលគេត្រូវជម្លៀសចេញ? តើលោកមានបានឮទេ? តើគេមានបានប្រាប់ពួកគាត់ថា ត្រូវប្រាប់ទៅអ្នកដែលជម្លៀសចេញនោះ ប្រាប់គាត់ថា គេនឹងអាចមកវិញ គឺថារយៈពេលខ្លីត្រឡប់មកផ្ទះរបស់គេវិញ តើមានការចេញបញ្ជាបែបហ្នឹងដែរឬទេ?

[០៩:៥៦:៣៥]

**ឆ៖** ខ្ញុំអត់ដឹងទេៗ។ អត់បានដឹងរឿងគេបញ្ជារឿងអ៊ីចឹងៗ អត់បានដឹងទេ។

**ស៖** តើមានការចេញបញ្ជា--

**លោក ម៉ែខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! សូមអញ្ជើញលោកមេធាវី! ម៉េចហើយ?

**លោក ម៉ែខល កាណាវាស៖**

សូមអភ័យទោសលោកប្រធាន លោក លោកស្រីចៅក្រម ហើយមានភាសាខ្មែរដែលសាក្សីនិយាយ ហើយមិនបានបកប្រែ ក្រោយពីគាត់បានឆ្លើយ គាត់បានធ្វើមតិមួយចំនួនហើយៗមិនមានការបកប្រែទៅជាអង់គ្លេសទេ ពេលដែលសាក្សីគាត់រអ៊ូនិយាយបន្ថែមនោះ។ អ៊ីចឹងសូមមេត្តាឲ្យមានការបកប្រែបាទ។

[០៩:៥៧:៣៥]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី តើលោកអាចនិយាយចម្លើយរបស់លោកអម្បាញ់មិញដែរឬទេ ចម្លើយទៅសំណួរអម្បាញ់មិញនេះ លោកអាចនិយាយម្តងទៀតបានទេ?

**លោក វ៉ាចាម គុន៖**

**ឆ៖** អម្បាញ់មិញ ខ្ញុំថាខ្ញុំអត់បានដឹងទេ រឿងៗល្អិតនោះ ខ្ញុំអត់បានដឹងទេ។

**ស៖** លោកសាក្សី តើលោកមានបានឮគេចេញបញ្ជាទាក់ទងនឹងរយៈពេលដែលគេកំណត់ឲ្យប្រជាជនចេញពីលំនៅដ្ឋានរបស់ខ្លួន? ឬក៏គេមិនមានកំណត់ពេលវេលាឲ្យទេ ត្រូវចេញភ្លាមតែម្តង ឬក៏គេទុកពេលឲ្យប៉ុន្មានម៉ោង ឬក៏ពេលវេលាយូរអ៊ីចឹងទៅ តើលោកមានបានឮទេ?

[០៩:៥៨:៤៣]

**ឆ៖** ខ្ញុំអត់បានឮអ៊ីចឹងផង អត់បានឮទេ។

**ស៖** ខ្ញុំសូមត្រឡប់មកនិយាយពីចំណុចមួយដែលថាមិនមានភាពស្រពេចស្រពិលជា -- នៅក្នុងប្រតិចារឹកភាសាបារាំងគឺៗ បញ្ហារយៈពេលជម្លៀសប្រជាជនចេញពីក្រុង។ តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេថា តើរយៈពេលមួយសប្តាហ៍ដែលលោកបានប្រាប់នេះនៅក្នុងចម្លើយរបស់លោកមុននោះ គឺរយៈពេលមួយសប្តាហ៍នេះគឺជារយៈពេលដែលត្រូវប្រតិបត្តិការជម្លៀស ឬក៏រយៈពេលនេះជារយៈពេលដែលថាក្នុងរយៈពេលមួយសប្តាហ៍នេះ ប្រជាជននឹងអនុញ្ញាតឲ្យត្រឡប់មកក្នុងក្រុងវិញ? លំនៅដ្ឋានវិញ?

ប្រហែលជាសំណួរខ្ញុំមានលក្ខណៈស្មុគស្មាញបន្តិច។ ប្រសិនជាលោកចង់ឲ្យខ្ញុំចោទសំណួរនេះឡើងវិញ ខ្ញុំអាចចោទសំណួរឡើងវិញបាន។

[១០:០០:០១]

និយាយឲ្យច្បាស់ជាងនេះ គឺថាវានិយាយអំពីរយៈពេលមួយសប្តាហ៍ តើរយៈពេលមួយសប្តាហ៍នេះ ជារយៈពេលសម្រាប់ឲ្យប្រជាជនចេញពីទីក្រុងភ្នំពេញទាំងអស់ ឬក៏ជារយៈពេលដែលថា នៅចុងមួយសប្តាហ៍នេះប្រជាជនអាចត្រឡប់មកទីក្រុងភ្នំពេញវិញបាន?

**ឆ៖** ត្រង់ចំណុចហ្នឹងគឺថា ផែនការគេថាជម្លៀសចេញពីទីក្រុងភ្នំពេញហ្នឹង គឺរយៈមួយអាទិត្យឲ្យអស់ពីទីក្រុងភ្នំពេញ។ អារឿងត្រឡប់មកវិញអត់ដឹងទេ។ អត់បានកំណត់ទេ ប៉ុន្តែចេញឲ្យអស់ហ្នឹងគេកំណត់ មួយអាទិត្យឲ្យអស់។ បើមិនអស់បន្តបន្ទាប់ទៀតទៅ។

**ស៖** បាទ សូមអរគុណលោកសាក្សីដែលបានធ្វើការបំភ្លឺដ៏សំខាន់នេះ។ បន្ទាប់មកទៀតលោកបាននិយាយអំពីការចូលមកដល់ទីក្រុងភ្នំពេញរបស់លោក ដោយមានអមដំណើរពីលោក សុន សេន លោកបាននិយាយអំពីកន្លែងនៅក្បែរពោធិ៍ចិនតុង តើលោកដឹងថានៅពោធិ៍ចិនតុងនុ៎ងមានកងកម្លាំងណាដែរទេ ដែលឈរជើងនៅទីនោះ? តើកងពលណា ហើយអ្នកណាជាអ្នកបញ្ជាកងពលនេះ?

[១០:០២:០៥]

**ឆ៖** ចំណុចហ្នឹង គឺថា សុន សេន ហើយនិងតាម៉ុក ចំណុចហ្នឹង។

**ស៖** តើមានមេកងពលផ្សេងទៀតដែរឬទេ?

**ឆ៖** ផ្សេងទៀតមាន តែខ្ញុំអត់បានចាំ។

**ស៖** បន្ទាប់មកទៀតលោកបាននិយាយថា លោកបានទៅស្តាត តើមានមូលហេតុជាក់លាក់ណាមួយទេ ដើម្បីទៅស្តាតនោះ? តើស្តាតនេះជាកន្លែងជំនួបគ្នា កន្លែងណាត់ជួបគ្នា ឬក៏ជាកន្លែងយុទ្ធសាស្ត្រណាមួយ ឬក៏យ៉ាងណា?

**ឆ៖** ទៅកន្លែងស្តាតហ្នឹង គឺថាយើងមកតាមផ្លូវលេខ៤។ មកតាមផ្លូវលេខ៤ត្រង់ចន្លោះអង្កាល់ហ្នឹងគេហៅថា នៅចន្លោះក្រសួងការពារជាតិរាល់ថ្ងៃ ហើយនិងចន្លោះទីស្តីការគណៈរដ្ឋមន្ត្រីរាល់ថ្ងៃ ត្រង់ហ្នឹងវាមានផ្លូវមួយចូលស្តាត ចូលទៅមើលកន្លែងហ្នឹងឃើញកន្ទុំរុយនៅនុ៎ងពីរគ្រឿងឃើញកន្ទុំរុយនៅហ្នឹង។ គេចូលទៅមើលកន្លែងចំណុចដែលសំខាន់ៗនៅទីក្រុងភ្នំពេញ ដូចថា ចំណុចស្តាត វាជាចំណុចគោលដៅមួយដែលក្នុងជាតិ និងអន្តរជាតិក៏គេចាប់អារម្មណ៍ដែរ បើថាកម្លាំងទៅដល់នុ៎ង អន្តរជាតិក៏គេចាប់អារម្មណ៍។ ក្នុងជាតិ គេដែលជាអ្នកទៅឃើញកន្លែងហ្នឹងក៏គេចាប់អារម្មណ៍។ ហ្នឹងចំណុចមួយ។

[១០:០៤:៤៤]

ចំណុចមួយទៀត គឺថាចំណុចមុខវាំង។ ចំណុចមួយទៀត គឺផ្លូវមុនីវង្សហ្នឹងចាក់ទៅ គេហៅថាស្ពានមុនីវង្ស ចេញពីស្ពានមុនីវង្សហ្នឹងមកវិមានឯករាជ្យ។ ចេញពីវិមានឯករាជ្យមក គឺមក គេហៅថាវត្តភ្នំ។ ចេញពីវត្តភ្នំមក វាមានអូតែល កាលជំនាន់បារាំង គេហៅស្អីទេ ខ្ញុំមិនស្គាល់ទេ។ ប៉ុន្តែជំនាន់ពួកខ្ញុំ ច្រើនពួកខ្ញុំហៅ ផ្ទះលេខ២ ហ្នឹង ផ្ទះលេខ១ និងផ្ទះលេខ២ហ្នឹង បានចេញពីហ្នឹង បានចាក់ទៅស្ពានទូតបារាំង ក្បាលស្ពានជ្រោយចង្វារ។ ក្បាលស្ពានជ្រោយចង្វារកាលនុ៎ង វាដាច់ទៅហើយ អត់មានប្រើទេ។ ប៉ុន្តែដឹងថា ក្បែរស្ពាន -- គេទៅចំណុចៗ អ៊ីចឹង។ ចំណុចដែលត្រូវបង្ហាញឲ្យថ្នាក់លើថា យើងទៅដល់កន្លែងហ្នឹងមែន។ អាហ្នឹង ហើយកម្លាំងរបស់យើង គឺថាចំណុចដែលយើងបានកំណត់ហ្នឹង គឺឃើញថាវាទៅជួបជុំគ្នាទាំងអស់។ យើងទៅត្រង់ណា ក៏ឃើញកងទ័ពបដិវត្តន៍ៗហ្នឹង។ អ៊ីចឹង ចំណុចដែលទៅហ្នឹង គឺថាអ៊ីចឹង។ ពាក្យពេចន៍លោកសួរអំមិញថា ខ្ញុំ -- សុន សេន អមខ្ញុំ មិនមែនអ៊ីចឹង។ គាត់ថ្នាក់ខ្ពស់ណាស់ ខ្ញុំអ្នកទៅដោយសារគាត់ អ៊ីចេះ។ ខ្ញុំអ្នកទៅដោយសារគាត់ទេ ព្រោះគាត់មេខ្ញុំ មិនមែនគាត់មកអមខ្ញុំ គឺខ្ញុំទៅៗក្នុងឋានៈដែលខ្ញុំទៅការពារគាត់ដែរ អ៊ីចេះ។

[១០:០៦:៤២]

**ស៖** សូមអរគុណ ចំពោះការបញ្ជាក់អម្បាញ់មិញនេះ។ តើលោកអាចប្រាប់បានទេ អំពីថាទិសដៅយុទ្ធសាស្ត្រមួយៗនេះ គឺលោកបានជួបបុគ្គលណាមួយជាក់លាក់នៅតាមទិសដៅមួយៗ ហើយថាលោកជួបអ្នកណាខ្លះ? តើលោកមានឃើញកងកម្លាំងដែលមកនៅក្នុងទីក្រុងភ្នំពេញ មុនពេលទីក្រុងភ្នំពេញដួលរលំដែរឬទេ? ខ្ញុំគិតថា គេហៅកម្លាំងនេះ មាន -- គឺដូចជាមានពាក្យពិសេសណាមួយសម្រាប់ហៅកងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជាដែលនៅប្រចាំការនៅទីក្រុងភ្នំពេញ តើលោកមានទំនាក់ទំនងជាមួយនឹងកងទ័ព ឬក៏យើងហៅថា ជាភ្នាក់ងារក្រុងនេះដែរឬទេ?

**ឆ៖** គឺចំណុចនេះ ខ្ញុំអត់បានជួបទេ។ ខ្ញុំជួបដូចអ្នកដែលអ្នកស្គាល់ៗគ្នាខ្លះទេ។ ឧបមាថា ខាងកើតនេះ គឺ សោ ភឹម, មាន តាទុំ, មាន តាឃ្លួង, មាន តាលីន ពីបូព៌ាខាងកើត។ មកពីមុខកំពូលនេះ មកពីផ្លូវលេខ៥នេះ អាហ្នឹង គឺមាន កុយ ធួន, មាន កែ ពក, មាន ឌឿន ចំណុចហ្នឹងអ៊ីចឹង។ ឯកម្លាំងដែលបង្កប់នៅទីក្រុងភ្នំពេញ ខ្ញុំអត់ដឹងទេ អត់ដឹង។ ដឹងតែបងៗដែលធ្លាប់ជួបគ្នា ហើយទៅហ្នឹង គេនៅចំណុចដែលបានកំណត់ហ្នឹង គេនៅទាំងអស់។

**ស៖** លោកនិយាយអំពីស្ពាន ដែលនៅស្ពានជប៉ុន ហើយលោកក៏បាននិយាយអំពីស្ពានទូតបារាំងផងដែរ។ ខ្ញុំចង់ដឹងថា តើលោកមានធ្លាប់ឮបទបញ្ជាពាក់ព័ន្ធទៅនឹងបុគ្គលដែលមានឋានៈជាអ្នកការទូត

ឬក៏ជាអ្នកដែលភៀសខ្លួនទៅនៅក្នុងស្ថានទូត? ហើយនៅពេលដែលលោកទៅជិតដល់ស្ពានជប៉ុននោះ តើមានស្ថានភាពអ្វីដែរនៅស្ថានទូតបារាំងនោះ?

[១០:០៩:៣១]

**ឆ៖** បើនិយាយពីខ្ញុំវិញ ស្ពានជ្រោយចង្វារ ក្បាលស្ពានហ្នឹង ខ្ញុំក៏មិនស្គាល់ដែរ ព្រោះខ្ញុំមិនដែលទៅឃើញផង ហើយនិងកន្លែងស្ថានទូតបារាំង អត់ស្គាល់ដែរ។ ប៉ុន្តែ បង សុន សេន គាត់ឧទ្ទេសនាម គាត់ថា នេះគេហៅ ស្ថានទូតបារាំង ហើយគេបិទទ្វារឲ្យជិតឈឹង ផ្លូវចូលទៅអត់មានបើកទេ។ បិទទ្វារជិតតែម្តង។ ហើយកន្លែងក្បាលស្ពានហ្នឹង ឈរមើលត្រង់ហ្នឹងទៅ ឃើញថាស្ពានហ្នឹង វាដាច់មែន នេះក្បាលស្ពានដាច់។ ហើយទៅដល់ស្តាតហ្នឹងគាត់ថា នេះកន្លែងស្ពាន នេះកន្លែងៗ -- មកឃើញកប៉ាល់ហោះ និងកន្ទុំរុយហ្នឹងនៅហ្នឹងពីរគ្រឿង។ ទៅដល់វាំង គាត់ថា នេះវាំងមុខនេ៎ះ ទល់មុខទន្លេបួនមុខ គាត់ឧទ្ទេសនាមអ៊ីចឹង។ ហើយទៅដល់ស្ពានមុនីវង្ស គាត់ថានេះស្ពានមុនីវង្ស អានេះទន្លេបាសាក់ ហើយទៅខាងនោះគេហៅថា ទន្លេមេគង្គក្រោម។ គាត់ឧទ្ទេសនាម គឺស្តាប់គាត់ គាត់និយាយ ចំណុចៗអ៊ីចឹង។ ចូលពីលិចទៅ គឺថាត្រង់ព្រលានយន្តហោះពោធិ៍ចិនតុងហ្នឹង គាត់ថា នេះព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង អ៊ីចឹង។ នេះខ្ញុំចង់បញ្ជាក់ គាត់បញ្ជាក់ពេលហ្នឹង គឺអ៊ីចឹង។

[១០:១១:១៨]

**ស៖** ចំពោះស្ថានទូតបារាំង តើ សុន សេន ប្រាប់លោកថា ទ្វារត្រូវបានបិទទ្វារ ឬក៏មានការប្រាប់ថាត្រូវធ្វើយ៉ាងម៉េចៗដែរ ចំពោះស្ថានទូតនោះ?

**ឆ៖** ស្ថានទូតនោះអត់មានថា ធ្វើម៉េចៗ ប៉ុន្តែឃើញៗ តែផ្លូវដែលថា ពីថ្នល់ធំហ្នឹងចូលទៅខាងក្នុងឃើញមានគេបិទ គេទាញបិទទាំងអស់ទ្វារខាងនុ៎ង ឃើញអ៊ីចឹង។

**ស៖** តើអ្នកណាជាមេភូមិភាគ ឬក៏មេកងពលដែលទទួលបន្ទុកមុខព្រួញស្ថានទូតបារាំងនេះ?

**ឆ៖** កន្លែងហ្នឹងគឺ កុយ ធួន, កែ ពក ប៉ុណ្ណឹង។ ប៉ុន្តែកងពលគេមាននេ៎ះ ឈ្មោះ អឿន មួយ, ឈ្មោះ សី ពីរ, ហើយឈ្មោះ បេង បី។ បីនាក់ហ្នឹងកងពល។

**ស៖** តើលោកមានបានតាមមើលស្ថានភាព នៃការវិវត្តន៍នៅស្ថានទូតហ្នឹងដែរឬទេ? ឬក៏លោកអត់មានដឹងអីទេ ពីការវិវត្តន៍ក្រោយមកទៀតនោះ?

**ឆ៖** ការវិវត្តន៍ក្រោយៗអត់ដឹងទេ អត់បានតាមដាន អត់បានដឹងទេរឿងហ្នឹង។

**ស៖** ខ្ញុំនៅសល់សំណួរមួយចំនួនតូចទេ ខ្ញុំចង់ចូលទៅប្រធានបទផ្សេងទៀតឥឡូវនេះ។ លោក

បានឆ្លើយថា ភារកិច្ចដំបូងរបស់លោកក្រោយពីដួលរលំទីក្រុងភ្នំពេញនេះគឺ រៀបចំផ្ទះស្នាក់នៅសម្រាប់អ្នកដែលមកទស្សនកិច្ច -- បរទេសដែលមកទស្សនកិច្ចកម្ពុជា។ តើលោកនៅរក្សាចម្លើយនេះទេ?

[១០:១៣:៤១]

**ឆ៖** បាទ ខ្ញុំនៅរក្សាចម្លើយខ្ញុំដដែល។

**ស៖** តើលោកអាចប្រាប់បានទេថា តើគណៈប្រតិភូដំបូងបំផុត ដែលមកទស្សនកិច្ចកម្ពុជាហ្នឹងនៅពេលណា? ហើយជាគណៈប្រតិភូណាដែរ?

**ឆ៖** គណៈប្រតិភូនោះគឺ គណៈប្រតិភូមកពីប្រទេសចិន។ កាលហ្នឹង គឺថាលោកតា ស៊ិន ជាគាត់មក។ គាត់ហ្នឹងមកមុនគេ។

**ស៖** តើជាគណៈប្រតិភូសំខាន់ ដែលថាមានសមាជិកច្រើនដែរឬទេ នៅក្នុងគណៈប្រតិភូហ្នឹង?

[១០:១៤:៥៩]

**ឆ៖** មានសហការីរបស់គេច្រើនដែរតើ ដូចជាង១០នាក់ដែរ អង្កាល់នុ៎ង។

**ស៖** តើលោកធ្លាប់ឮអ៊ំៗពិភាក្សាគ្នាអំពីការយាងត្រឡប់របស់សម្ដេច នរោត្តម សីហនុ ដែរឬទេ? ប្រសិនបើលោកចាំថាមាននោះ តើគេនិយាយអ្វីខ្លះអំពីការយាងត្រឡប់មកវិញរបស់សម្ដេច សីហនុនេះ?

**ឆ៖** ខ្ញុំអត់បានដឹង គឺថាផែនការ ព្រះករុណាយាងមក ត្រឡប់មកកម្ពុជា។ ខ្ញុំអត់ដឹង អត់បានដឹងផែនការហ្នឹង អត់ដឹងទេ។ ប៉ុន្តែស្រាប់តែឃើញគាត់មក មកដល់តែម្ដង។ ជាផែនការដែលដាក់ឲ្យគាត់មកនេះ ខ្ញុំអត់ដឹង ខ្ញុំអត់បានទទួលទេផែនការនេះ ខ្ញុំអត់ដឹង ប៉ុណ្ណឹង។ ប៉ុន្តែគាត់មកអង្កាល់ហ្នឹងដូចជា--

**ស៖** កាលពីមុននោះក៏គេបានសួរពាក់ព័ន្ធទៅនឹងបឹងត្របែក។ ឥឡូវនេះខ្ញុំចង់ឲ្យលោកនិយាយអំពីមន្ទីរច្រាំងចំរេះវិញម្ដង។ ខ្ញុំគិតថា ប្រហែលជាខ្ញុំអានមិនសូវត្រូវទេភាសាខ្មែរនោះ ប៉ុន្តែខ្ញុំគិតថាយើងអាចដឹងហើយថា ខ្ញុំនិយាយអំពីអីនោះ។ តើច្រាំងចំរេះនេះជាកន្លែងដែលស្ថិតនៅក្រោមការក្ដាប់របស់លោកទេ ដែលថាលោកមានតួនាទីទទួលខុសត្រូវច្រាំងចំរេះនេះ?

[១០:១៧:១៣]

**ឆ៖** ច្រាំងចំរេះហ្នឹង ដំបូងគឺថារបស់មន្ទីរនែ៎ បង កុយ ធួន ទេ គាត់នៅហ្នឹង ជារបស់គាត់ទេ។ ដល់ក្រោយមកទៀតបានគេប្រគល់មកឲ្យប-១ ដែរអាហ្នឹង។

**ស៖** ហើយចុះនៅមន្ទីរប-១ តើអ្នកណាទទួលខុសត្រូវលើច្រាំងចំរេះ? តើលោកមែនទេ ដែលជាអ្នកទទួលខុសត្រូវច្រាំងចំរេះនេះ ទៅប-១នោះ?

**ឆ៖** ទទួលរួម គឺថាប-១ គឺថាខ្ញុំហ្នឹងហើយអ្នកទទួល។ ប៉ុន្តែអ្នកដែលប្រចាំការជាអចិន្ត្រៃយ៍នៅនៅច្រាំងចំរេះនេះ គឺឈ្មោះពូ សឹម ទេ ឈ្មោះពូ សឹម។

**ស៖** តើច្រាំងចំរេះមានតួនាទីអ្វីនៅក្នុងមន្ទីរប-១? តើជាកន្លែងដាំបន្លែបង្ការ ឬក៏ជាកន្លែងអប់រំ?

**ឆ៖** កន្លែងនេះ គឺថាន៎ែ វាមានកន្លែងន៎ែ កន្លែងចិញ្ចឹមត្រីផង កន្លែងចិញ្ចឹមមាន់ ចិញ្ចឹមទាផង ហើយវាមានដីស្រែបន្តិចដែរ មានដីស្រែ ហើយក៏មានដើមត្នោតប្រហែលជា៣០ដើម នៅកន្លែងហ្នឹង។

[១០:១៩:១៤]

**ស៖** តើជាសហករណ៍ធម្មតាទេ ឬក៏ជាកន្លែងមួយសម្រាប់អប់រំកែប្រែ?

**ឆ៖** កន្លែងហ្នឹងមិនមែនកន្លែងអប់រំកែប្រែអីទេ។ គឺថាបើថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ពីន៎ែ បុគ្គលិកខ្ញុំពីក្រសួងហ្នឹង គឺថាគេមកលេងកន្លែងហ្នឹង។ មកមើលត្រី មកមើលចិញ្ចឹមសត្វអីអ៊ីចឹងទៅ។ ហើយចង់មកហូបទឹកត្នោតលេងហ្នឹង ក៏មកហូបទឹកត្នោតអីអ៊ីចឹង។ ដូចអត់មានកន្លែងអប់រំទេកន្លែងហ្នឹង។ មិនមានអីធំដុំផង ខ្ទមរេករ៉ាកនៅហ្នឹង តែមួយខ្នង ហើយផ្ទះក្នុងទឹកហ្នឹងមួយ តែប៉ុណ្ណឹង។

**ស៖** តើអៀង សារី គាត់ធ្លាប់ទៅច្រាំងចំរេះហ្នឹងដែរឬទេ?

**ឆ៖** គាត់បានទៅដែរតើ! គាត់បានទៅ។ បង សួរ ហុង ក៏ទៅ ទៅទាំងអស់គ្នាហ្នឹង។

**ស៖** លោកបានឆ្លើយពាក់ព័ន្ធនឹងមុខងាររបស់លោកនៅ ប-១ គឺខ្ញុំសូមអាននៅក្នុងសំណៅជាភាសាបារាំង គឺថាលោកក្តាប់រួមលើសតិអារម្មណ៍ ហើយនិងគ្រប់គ្រងរដ្ឋបាលទៅលើបុគ្គលិកនៅប-១។ ខ្ញុំដូចជាភ្ញាក់ផ្អើលបន្តិច នៅពេលដែលយើងនិយាយអំពីការក្តោបក្តាប់សតិអារម្មណ៍របស់បុគ្គលិកហ្នឹង តើលោកពិតជាបាននិយាយអ៊ីចឹងមែនទេថា គ្រប់គ្រង ឬក៏ក្តោបក្តាប់លើសតិអារម្មណ៍របស់បុគ្គលិកនោះ?

**ឆ៖** ខ្ញុំបាននិយាយមែន និយាយថាក្តោបក្តាប់សតិអារម្មណ៍នោះ។ ព្រោះអាហ្នឹងសំខាន់ណាស់បុគ្គលិកក្នុងកិច្ចការងារមួយៗ។ យើងក្តាប់រួមៗគឺរួមទាំងអស់ក្នុងមន្ទីរហ្នឹង ប៉ុន្តែយើងត្រូវក្តាប់ទស្សនៈគោលជំហរ សតិអារម្មណ៍ និងចាត់តាំងរបស់គេដែរ។ អាហ្នឹងអ៊ីចឹង។ គឺថាគោលជំហរហ្នឹងយ៉ាងម៉េចក្នុងការរស់នៅហ្នឹង។ ទស្សនៈហ្នឹងមើលឃើញយ៉ាងម៉េច? សតិអារម្មណ៍ហ្នឹងជ្រះថ្លាដែរអត់? ចាត់តាំងហ្នឹងគឺថាកន្លែងគេរស់ -- គេឲ្យនៅកន្លែងហ្នឹង នៅបានឬអត់។ អាហ្នឹងគឺចាត់តាំងគឺដឹងឲ្យ

ច្បាស់លាស់អ៊ីចឹង។

[១០:២២:០៦]

**ស៖** បើសិនបើខ្ញុំយល់ច្បាស់នោះគឺថា ការក្តាប់សតិអារម្មណ៍នេះគឺមានន័យថា ត្រូវដឹងថាតើបុគ្គលិកហ្នឹងគាត់មានភាពសប្បាយរីករាយ ឬក៏មានសេចក្តីទោសមនស្ស ឬក៏គាត់ជាអ្នកបដិវត្តន៍ល្អ ឬក៏អាក្រក់ អ៊ីចឹងមែនទេ? ដែលគាត់មានសតិអារម្មណ៍ល្អ ឬក៏មិនល្អ? តើមានន័យថាម៉េចឲ្យច្បាស់ទៅថាក្តាប់សតិអារម្មណ៍នេះ ខ្ញុំដូចជាមិនសូវយល់សោះ?

**ឆ៖** ក្តាប់សតិអារម្មណ៍ដូចលោកបាននិយាយអម្បាញ់មិញនេះគឺថា សតិអារម្មណ៍ដែលគេល្អជាមួយបដិវត្តន៍ សតិអារម្មណ៍ណាដែលគេជ្រះថ្លាក្នុងការបំពេញភារកិច្ច គឺក្តាប់អ៊ីចឹងហ្នឹងហើយ។

**ស៖** ប្រសិនបើលោកកត់សម្គាល់ឃើញថាមានបុគ្គលិកមួយចំនួន ដែលគាត់ថាមិនមានសតិអារម្មណ៍ល្អ បំពេញការងារមិនល្អអីហ្នឹង តើមានអ្វីកើតឡើងចំពោះបុគ្គលិកទាំងអស់នេះ?

**ឆ៖** យើងៗមានមតិយើងបានបញ្ជាក់អ៊ីចឹងទៅ គឺថា មានអីបងប្អូនគេបំពេញភារកិច្ច គេសប្បាយរីករាយធម្មតា វាមិនមានបញ្ហាអីនឹងចោទឡើងទេ។ បើគេជ្រះស្រឡះហើយ ហើយបើគេពេញចិត្តនឹងបដិវត្តន៍ហើយ មិនស្អីទៀតទេ។ មិនអីទេ ចេះតែរស់នៅជាមួយបដិវត្តន៍ជារៀងរហូតអ៊ីចឹងទៅ។

[១០:២៤:០៣]

**ស៖** ខ្ញុំចង់សួរថា ប្រសិនបើមិនពេញចិត្តនោះ តើយ៉ាងម៉េច? មានហេតុអីកើតឡើងចំពោះបុគ្គលិកដែលថាមិនមានពេញចិត្តនោះ?

**ឆ៖** បើមិនពេញចិត្តគឺថា យើងប្រជុំតើ! ប្រជុំគេ ៗរាយការណ៍ហើយ បើថាមេក្រុមគេអ្នករាយការណ៍ ឧបមាថាគេរាយការណ៍ទៅបើថាវាល្អ។ បើថាវាមិនពេញចិត្តហ្នឹង គឺថាក្រុមក្នុងនុ៎ងគេមើលគ្នា គេជួយយោបល់គ្នាទៅ។ ជួយយោបល់ហ្នឹង ថ្ងៃៗណាមួយហ្នឹងសតិអារម្មណ៍មិនជ្រះស្រឡះ សតិអារម្មណ៍មិនសប្បាយចិត្ត សតិអារម្មណ៍ដែលមិននេះទេ។ គ្រាន់តែថា យើងប្រជុំដើម្បីកែលម្អ បើវាមានអ៊ីចឹងហ្នឹង គឺថ្ងៃក្រោយកុំឲ្យមានអ៊ីចឹងទៀត។ ថាកែលម្អវាទៅបើថាវាមិនល្អ បើល្អហើយ យើងជំរុញឲ្យវាល្អតទៅទៀត។ អ៊ីចឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណចំពោះចម្លើយនេះ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១០:២៥:២១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដល់ពេលសមល្មមនឹងសម្រាកដែរហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់ និងបង្កលក្ខណៈងាយស្រួលនូវកន្លែងសម្រាកដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់នៅបន្ទប់សម្រាប់រង់ចាំរបស់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបានកំណត់អម្បាញ់មិញនេះ គឺម៉ោងដប់មួយ ខ្វះដប់ប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៦ នាទី ដល់ម៉ោង ១០:៤៩ នាទី)*

[១០:៤៩:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីឲ្យលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី រ៉ាចាម តុន។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបផងដែរ ថាលោកព័ត៌មានអម្បាញ់មិញពីផ្នែក អាយ.ធី គឺមានបញ្ហាបច្ចេកទេសក្នុងការដែលមិនអាចដាក់បង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ឬក៏ទូរទស្សន៍នៅក្នុងអំឡុងពេលនេះទេ ដោយសារមានបញ្ហា ហើយអ្នកបច្ចេកទេសកំពុងតែជួសជុល។ ដូច្នេះ សូមភាគីដែលពាក់ព័ន្ធនឹងសិទ្ធិក្នុងការតាំងសំណួរសូមរៀបចំនូវការតាំងសំណួររបស់ខ្លួន ចំពោះលទ្ធភាពដែលអាចធ្វើទៅបាន គឺចៀសវាងនូវការបង្ហាញឯកសារ នៅលើអេក្រង់នាពេលដំបូងៗនេះ អាចទុកលទ្ធភាពនេះនៅពេលដែលរសៀលទៅ។ ខាងអ្នកបច្ចេកទេសអាចរៀបចំសម្រួលឲ្យបានល្អប្រសើរឡើងវិញបាន។

បាទ សូមអញ្ជើញ!

[១០:៥០:៤៣]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន និងសួស្តីលោក ភី ភួន សាក្សី។ ខ្ញុំឈ្មោះ សុន អរុណ ខ្ញុំមេធាវីការពារ -- សហមេធាវីការពារខាងខ្មែរឲ្យលោក នួន ជា។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនចង់ -- ដើម្បីសួរលោកនៅថ្ងៃនេះ។ លោក ភី ភួន លោកបានជម្រាបព្រះរាជអាជ្ញាកាលពីថ្ងៃ២៥ ខែ៧ ២០១២ ថាលោកបានឃើញទង់បដិវត្ត និងទង់យុវជន។ ខ្ញុំសួរថា លោកដែលបានឃើញច្បាស់លាស់ទេ ទង់បដិវត្តនុ៎ង លោកបានអានទេ ហើយលោកបានអានច្រើនក្បាលទេ?

[១០:៥១:៤២]

**លោក រ៉ាចាម គុន៖**

**ឆ៖** បានអាន ព្រោះអាហ្នឹងគឺថា ចែក។ កាលណាចែកយកមកអានៗមួយចប់ហ្នឹងក៏ទុកចោលទៅ។

**ស៖** លោក ខ្ញុំចង់ឲ្យលោកមានប្រសាសន៍ពីរឿងទង់បែបផែន និងភិនភាគទង់បដិវត្តនោះ តើទង់បដិវត្តនោះវាយ៉ាងម៉េច? មានជាសៀវភៅ ឬជាទស្សនាវដ្ដី ឬជាក្រដាសស្នាមឯកសារ ឯកសារក្រដាសស្នាម ហើយមានពណ៌អ្វី ហើយសរសេរដោយដៃ ឬក៏ដោយរ៉ៃដាកទីឡូ?

**ឆ៖** ក្នុងហ្នឹងគឺថា គេដាក់ថាទង់បដិវត្ត ទង់យុវជន។ អាហ្នឹងគេរៀបចំជាសៀវភៅ ហើយក្របហ្នឹងគេដាក់ថា ទង់បដិវត្ត ហើយទង់យុវជន អ៊ីចឹង។ គេគូសពណ៌ ខ្ញុំមិនចាំអស់ទេ ដូចជាពណ៌រាងទង់ហ្នឹងដូចថា រាងពណ៌ក្រហមហ្នឹងហើយ។ ពណ៌ក្រហមហ្នឹងជាមូលដ្ឋាន។

[១០:៥៣:៣៩]

**ស៖** ខ្ញុំអំមិញសួរមួយម៉ាត់បន្ថែម ប៉ុន្តែលោកមិនទាន់បានឆ្លើយថា ទង់នោះសរសេរដោយដៃ ឬក៏រ៉ៃដាកទីឡូ ឬក៏ជាអក្សរពុម្ព?

**ឆ៖** ខ្ញុំឃើញនៅនុ៎ងគឺថា ក្នុងក្របសៀវភៅហ្នឹង គឺខ្ញុំមិនដឹងថា គេសរសេរ -- គេគូសនឹងដៃ ឬគេគូសលើ -- មិនដឹងគេរៀបម៉េច ឃើញៗដូចជារូបរាង ដូចគេគូស។ ខ្ញុំមើលទៅដូចគេគូសច្រើនជាង។ នៅក្របសៀវភៅហ្នឹង គ្រប់សៀវភៅទាំងអស់គេដាក់ក្របហ្នឹង មានទង់បដិវត្តៗអ៊ីចឹង។

**ស៖** ចុះចំពោះអត្ថបទខាងក្នុងៗ ដែលលោកបានឆ្លើយថា លោកបានអានដែរ នុ៎ង លោកឃើញថាអក្សរនោះ អក្សរខាងក្នុងសៀវភៅនោះ គ្រប់ទំព័រទាំងអស់ហ្នឹងសរសេរដោយដៃ ឬក៏វ៉ៃពុម្ព?

**ឆ៖** គឺវ៉ៃពុម្ពគេអូសមក បានគេកាត់ជាកូនសៀវភៅអ៊ីចឹង។

**ស៖** លោកបានអានទង់បដិវត្ត និងទង់យុវជន ហ្នឹង នៅឆ្នាំណា?

[១០:៥៥:៣២]

**ឆ៖** ថ្ងៃមុននឹង ខ្ញុំបានបញ្ជាក់ថា ចាប់ពី គឺចាប់ពី៧៧ មិនដឹងជាដើម មិនដឹងពាក់កណ្តាលឆ្នាំទេ ៧៧ ហ្នឹង ចាប់ពីហ្នឹងខ្ញុំអាន វាមានរាល់ខែ ហើយវាចេញមកមាន យកមកចែកគ្រប់ក្រសួង។ អានខ្លឹមសារក្នុងហ្នឹង គឺថាៗ ចលនាៗគេហៅថា ចលនាជាក់ស្តែងក្នុងប្រទេស ឬមួយ គេនិយាយពីការកសាងបក្ស ពីការកសាង ល្អិតទៀតក៏មាន មានច្រើន ខ្ញុំចាំវាមិនអស់ទេ គឺថាគេនិយាយពីប្រតិភូនេះ ប្រតិភូនោះ ដែលមកទស្សនកិច្ចនៅកម្ពុជា ដែលគេចាប់អារម្មណ៍។ អាហ្នឹង គេចុះក្នុងហ្នឹង គឺអ៊ីចឹងដែរ។

**ស៖** សូមអរគុណ។ លោកបានដឹងទេ ថាសៀវភៅទង់បដិវត្ត និងទង់យុវជនហ្នឹង អ្នកណាជាអ្នកសរសេរ? អ្នកតុបតែងសៀវភៅហ្នឹង ឲ្យចេញជាទង់បដិវត្តនុ៎ង? មានបានដឹងឈ្មោះអ្នកសរសេរហ្នឹងទេ? អ្នករៀបចំហ្នឹងទេ?

[១០:៥៧:១២]

**ឆ៖** ខ្ញុំអត់បានដឹងទេ អ្នកដែលគាត់តែងនេះ។ ទង់បដិវត្ត ទង់យុវជន នេះ ជាបុគ្គល ខ្ញុំអត់បានដឹង អត់បានចាប់អារម្មណ៍ដឹងផង។

**ស៖** អរគុណ។ ពេលលោកឆ្លើយទៅព្រះរាជអាជ្ញា ថានៅក្រោយថ្ងៃ១៧ មីនា ឆ្នាំ១៩៧០ ខេត្តមួយចំនួននៅភ្លៀសានបានទូលាយ។ ពាក្យលោកបាននិយាយថា “បានទូលាយ” សូមលោកសាក្សីបញ្ជាក់បន្តិចថា ទូលាយ ហ្នឹង លោកចង់និយាយថាយ៉ាងម៉េច?

**ឆ៖** ពាក្យដែលថា នែ៎ ខ្ញុំ -- គាត់ជម្រាបថា គឺយើងរំដោះ គេហៅថា តំបន់រំដោះធំទូលាយ។ ធំទូលាយហ្នឹង ដូចខ្ញុំបានរៀបរាប់ហ្នឹង គឺគាត់ឧទ្ទេសនាម គឺថារំដោះយើងឥឡូវ រតនគិរីទាំងស្រុង មណ្ឌលគិរីទាំងស្រុង ក្រចេះទាំងស្រុង ហើយនិងព្រះវិហារទាំងស្រុងទៀត។ នេះបានថា តាមការឧទ្ទេសនាមរបស់អ៊ំ គាត់ថាតំបន់រំដោះយើងឥឡូវ គឺថាធំទូលាយៗតែម្តង តំបន់រំដោះ។ គឺអត់មានឧបសគ្គ គឺតំបន់ គេហៅថាមាន នែ៎ ខ្មាំងកាប់កាន់ទៀតទេ អាហ្នឹង គឺវាតំបន់រំដោះហ្នឹង គឺថា អ្នកបដិវត្ត

ពេញទំហឹងហើយអាហ្នឹង គឺអ៊ីចឹង។

[១០:៥៩:២០]

**សៈ** អរគុណ។ ពេលជាមួយគ្នានោះដែរ លោកបានបញ្ជាក់ជម្រាបតុលាការថា ពេលនោះមាន អាមេរិកាំងមកទម្លាក់គ្រាប់បែកខ្លាំងក្លាណាស់ តាមយន្តហោះ។ លោកដឹងទេ ថាហេតុអ្វីបានជា អាមេរិកាំងមកទម្លាក់គ្រាប់បែកអ៊ីចឹង។ ចុះមានទ័ពអាមេរិកាំងថ្មើជើងចូលមកលើដីខ្មែរដែរឬទេ? ព្រម ទាំងទ័ពវៀតណាមផង?

**ផៈ** ខ្ញុំបញ្ជាក់ចំណុចនេះគឺថា ចំណុចទីមួយនេះ ដែលវាទម្លាក់នៅឆ្នាំ៦២ៗ អាហ្នឹងខ្ញុំឃើញ។ ទម្លាក់ហ្នឹង គឺទម្លាក់នៅភូមិប្រជាជនយើងរស់នៅតែម្តង។ គេហៅភូមិញ៉ាង ហ្នឹង។ ឈ្មោះភូមិញ៉ាង អ៊ីចឹងតែម្តង ប៉ុន្តែឥឡូវគេដាក់ ឃុំញ៉ាង ការពិតភូមិហ្នឹងឥឡូវគឺ -- មិនដឹងយ៉ាងម៉េចទេគេថា ភូមិហ្នឹងគឺ វាចូលទៅក្នុងទឹកដីវៀតណាមអស់ហើយឥឡូវហ្នឹង។ ពីមុនថារបស់ខ្មែរ ដល់ឥឡូវអស់រលីងមួយជួរ ហ្នឹង ប្រាំពីរ ប្រាំបីភូមិ ហ្នឹងអស់រលីង។ និយាយតែផ្ទៃដីដែលយើងធ្លាប់បង្កបង្កើនផល យើងធ្លាប់រស់ នៅ ខ្ញុំចង់បញ្ជាក់អ៊ីចឹង។ អាហ្នឹងចំណុចទីមួយ។

[១១:០១:០៦]

ហើយចាប់ពីនុ៎ងមក គឺថា ៦៤ ក៏វាទម្លាក់, ៦៥ ក៏វាទម្លាក់, ៦៦ ក៏វាទម្លាក់, ៦៧ ក៏វាទម្លាក់, ៦៨ ក៏វាទម្លាក់, ៦៩ នេះវាតព្វាតខ្លាំងមែនទេតែម្តង។ ខ្ញុំចង់និយាយនេះ អត់មែនទឹកដីវៀតណាមទេ គឺចង់និយាយថា ក្នុងទឹកដីខេត្តរតនគិរីហ្នឹង។ មើល៍ ខ្ញុំរាប់ភូមិ៖ គេហៅភូមិឡោះ ហ្នឹង អស់រលីង, ភូមិ ញ៉ាងហ្នឹង អស់រលីង, ភូមិតាង៉ា ហ្នឹងអស់មួយចំហៀង, ភូមិអុន អស់មួយចំហៀង, ហៅភូមិមួយហ្នឹង អស់មួយចំហៀងដែរ។ អ៊ីចឹង បួនប្រាំភូមិហ្នឹង។ ហើយទម្លាក់ហ្នឹងមិនមែនន៎ែ ដល់ ៦៨-៦៩ ហ្នឹងទម្លាក់ ហ្នឹង។ ទម្លាក់សូម្បីតែកន្លែង ពួកខ្ញុំធ្វើស្រែហ្នឹង វាទម្លាក់ខ្លាំងណាស់ដែរ មិនដឹងជាវាមានកំហឹងពីអង្កាល់ ណាមក លេងលើកប៉ាល់ហោះមកទាំងហ្វូងៗតែម្តង អាស្លាបកាត់ក៏មាន អាសេ១៣០ ក៏មាន។ អាប្រតិកម្មក៏មានដែរ ទម្លាក់តាមភូមិហ្នឹង។ ហើយកាលនុ៎ង វាបាញ់គ្រាន់តែគោក្របី ងាប់ម៉្លេះ ងាប់ វាបាញ់ អស់ជាង ១.០០០ ឯណោះ។ មួយថ្ងៃវាបាញ់អស់ជាង ១.០០០ គោក្របីក្នុងវាលស្រែហ្នឹង។ ថា ម៉េចមិនដឹងបានវាទម្លាក់ហ្នឹង វាខឹងរឿងអី? អាហ្នឹងគឺយើងនេះដែរ មិនដឹងវាខឹងរឿងអីបានជាមក ទម្លាក់អីសម្បើមម្ល៉េះ។

[១១:០៣:១២]

ហើយចាប់ពី៦០-- ៦៤ ប្រជាជនអត់មានដែរប៉ាននៅភូមិទៀតទេ គឺនៅក្នុងព្រៃទាំងអស់។ ភូមិខាងនុំង គឺថានៅក្នុងព្រៃទាំងអស់ ព្រោះឃើញវាសាហាវៗពេក ឃើញតែពួកវាទម្លាក់សោះហើយ។ នេះសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** អរគុណ។ លោកមិញបានបញ្ជាក់ថា មិនដឹងហេតុអីទេ ចេះមកទម្លាក់អ៊ីចឹង។ ដល់ក្រោយមកទៀតតើលោកបានដឹងថា មានហេតុអីបានគេទម្លាក់ ក្រោយៗឆ្នាំក្រោយៗមកទៀត? ពេលទម្លាក់ថាមិនដឹងទៅចុះ ប៉ុន្តែក្រោយៗមានដឹងហេតុ ហេតុអីបានជាអាមេរិកាំង -- កាលហ្នឹងមិនទាន់មានរដ្ឋាភិបាល លន់ នល់ ទេ មានន័យថា យើងអត់ទាន់ឈ្លោះគ្នាជាមួយអាមេរិកាំងអីទេ។ ប៉ុន្តែដល់ហើយម៉េចក៏ទម្លាក់ មានដឹងទេ? ពេលក្រោយមក មានដឹងហេតុផលម៉េចបានគេទម្លាក់ទេ?

[១១:០៥:២១]

**ឆ៖** ក្រោយមកបានដឹង គឺថា វាទម្លាក់ហ្នឹង ទីមួយវាតាម គេហៅតាមយៀកកុង តាមគេហៅយៀកកុងៗហ្នឹង ហើយបន្តបន្ទាប់ទៀត ឃើញប្រជាជននៅមួយជួរព្រំដែននេះ ប្រជាជនវៀតណាមនេះ រត់មកភៀសខ្លួនមកទឹកដីយើង ទឹកដីប្រទេសកម្ពុជាយើង។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** អរគុណ។ ពេលដែលមុននឹងទម្លាក់គ្រាប់បែក ឬពេលដែលកំពុងទម្លាក់គ្រាប់បែក ឬក្រោយពេលបន្តិចនៃទម្លាក់គ្រាប់បែក មានកងទ័ពថ្មើរជើងអាមេរិកាំង ឬក៏ខាងកងទ័ពថ្មើរជើងវៀត-ណាមចូលមកទឹកដីខ្មែរទេ?

**ឆ៖** បើនិយាយឲ្យវាជាក់ស្តែងគឺថា កងទ័ពវៀតកុងនៅតាមភូមិដូចអត់មានទេ ដូចអត់មានសោះតែម្តង។ បើ -- ខ្ញុំបញ្ជាក់លើកមុន ខ្ញុំថាតាំងពី៦៣-៦៤ ហ្នឹងមានកងទ័ពវៀតណាមមកពីខាងជើងនេះ ដើម្បីទៅជួយវៃវៀតណាមខាងត្បូងហ្នឹង មានការឆ្លងកាត់។ ប៉ុន្តែឆ្លងកាត់នេះ សម្ងាត់ណាស់ៗ ព្រោះធ្វើៗផ្លូវក្នុងព្រៃឯណោះ កាត់ គឺកែនប្រជាជននៅជនជាតិហ្នឹងហើយ គឺធ្វើផ្លូវ។ ធ្វើផ្លូវដំបូង គឺផ្លូវកង់ អ៎!ផ្លូវដើរ។ ដល់ទក់យូរៗទៅ វាក្លាយជាផ្លូវកង់។ ផ្លូវកង់ហ្នឹង កាលហ្នឹងគឺថា កងទ័ពវៀតណាមហ្នឹង គេៗទិញអង្ករ សម្រាប់ដឹកអង្ករតាមផ្លូវហ្នឹងចិញ្ចឹមកងទ័ពគេ។ ឃើញអ៊ីចឹង។

[១១:០៦:៣៨]

**ស៖** អរគុណ។ ពេលដែលអាមេរិកាំងទម្លាក់គ្រាប់បែកចូលក្នុងដីខ្មែរ លោកអាចវាយតម្លៃបានថាទម្លាក់ចូលប៉ុន្មានគីឡូម៉ែត្រចូលដីខ្មែរទេ ខាងខេត្តរតនគិរី?

**ឆ៖** ម្តុំដែលខ្ញុំរស់នៅហ្នឹង គឺថាពីព្រំដែន ព្រោះវាទម្លាក់មកខាងត្បូងទន្លេៗសេសានទៀត។

ឆ្ងាយដែរ ប៉ុន្តែមិនដឹងប៉ុន្មានគីឡូទេ។ កន្លែងខ្លះ ខ្ញុំមើលផែនទីឥឡូវហ្នឹងទេ មើលផែនទីឥឡូវហ្នឹងកន្លែងពីព្រំដែនហ្នឹង កន្លែងខ្លះ១០គីឡូ កន្លែងខ្លះ១៥គីឡូ កន្លែងខ្លះ៣០គីឡូក៏មានដែរ។ ដល់វាទម្លាក់នៅបរកែវនុ៎ង ទម្លាក់នៅបានលុងទៀត វាឆ្ងាយដែរ ជ្រៅដែរ។

**ស៖** សូមអរគុណ។ សំណួរមួយទៀត លោកសាក្សីបានចូលបដិវត្តន៍ពីឆ្នាំ១៩៦៣ ពេលនោះលោកដឹងថាអ្នកបដិវត្តន៍ទាំងអស់ ដែលបានចូលនៅនុ៎ងទាំងលោកសាក្សីផង ហើយអ្នកដទៃទៀត មានកាន់អាវុធទេពេលនុ៎ង?

[១១:០៨:១៩]

**ឆ៖** ចូលធ្វើបដិវត្តន៍ដំបូង តាំងពីថា៦៣មក ៦៣, ៦៤, ៦៥, ៦៦, ៦៧។ ចុង ៦៧ ខ្ញុំៗបានកាន់កាំភ្លើង ខ្ញុំទ័លហើយ ខ្ញុំចង់និយាយថាខ្ញុំទ័លហើយ ខ្ញុំកាន់កាំភ្លើង។ មុនដំបូងកាន់អង់គៀវ៉ា បន្ទាប់មកទៀត កាន់គ្រង់ស៊ីស គេហៅថា អាគ្រង់ស៊ីស របស់បារាំងទាំងអស់។ ហើយបន្ទាប់មកទៀត ខ្ញុំបានខ្ញុំកាន់ការ៉ាប៊ីន។ ប៉ុន្តែ ខ្ញុំចង់បញ្ជាក់ថា ចូលដំបូងអត់មានកាំភ្លើងអីទេ។ ហើយចាប់ពីចុង៦៧ ដើម៦៨ នេះគឺថាមានកាំភ្លើងខ្លះ។ ដូចថាក្នុងអង្គភាពទ័ព អង្គភាពកងចល័តហ្នឹងគឺមានកាំភ្លើង។ ហើយបើនិយាយមន្ទីរៗពួកខ្ញុំ ដំបូងឡើយអត់មានកាំភ្លើងទេ។ ប៉ុន្តែ វៀតណាម វាធ្វើដំណើរពីនោះមក វាហេវវាហត់ វាចង់បានជ្រូក វាចង់បានឆ្កែ វាចង់បានចេកហូប។ ដល់យកៗហ្នឹងទៅដូរគ្រាប់កាំភ្លើង។ ដំបូងហ្នឹងដូរយកគ្រាប់កាំភ្លើង ហើយដល់យូរៗដូរកាំភ្លើង ដូរជាមួយកាំភ្លើងទៀត ជាមួយពួកអាយាមឃ្លាំងហ្នឹង។ អ៊ីចឹង ឃើញអ៊ីចឹង។ អ៊ីចឹងបានៗក្រោយៗមកចេះតែមានកាំភ្លើង កាន់តែច្រើនឡើងៗ មកត្រឹមរយៈដែលៗដូរហ្នឹង កាំភ្លើងច្រើន។

[១១:១០:២៧]

**ស៖** បើអ៊ីចឹងកាំភ្លើងដែលអ្នកបដិវត្តន៍ បានចូលកាន់ -- ចូលមុនដំបូងបានកាន់កាំភ្លើងហ្នឹង ឬក៏ក្រោយមកក៏ដោយ សុទ្ធតែកាំភ្លើងបានមកទិញពីវៀតណាម ឬក៏បានមកតាមរបៀបផ្សេងៗអ៊ីចឹងទេ?

**ឆ៖** បាទ ហើយដាក់ស្តែងក្នុងខេត្តរតនគិរី គឺចាប់ពី៦៨ហ្នឹង កាំភ្លើងគេហៅថា កាំភ្លើងកាត់ហ្នឹង យើងធ្វើខ្លួនយើង គឺថាបំពុស ចលនាធ្វើហ្នឹងក៏ធ្វើដែរ ធ្វើច្រើនដែរកាំភ្លើងកាត់ហ្នឹង ទិញបំពង់ទីបមកកាត់ធ្វើតែម្តង ធ្វើខ្លួនឯងដើម្បីអមជាមួយស្នា ធ្នូ អីហ្នឹង កាំភ្លើងកាត់មានដែរ មានធ្វើដែរ។

**ស៖** សូមអរគុណ។ កាលពីថ្ងៃ២៦ ខែ៧ នេះលោកសាក្សីបានឆ្លើយប្រាប់ព្រះរាជអាជ្ញាថា លោក សុន សេន ជាប្រធានភូមិភាគពិសេស។ សូមលោកបញ្ជាក់ម្តងទៀតមើល៍ ថាតើ សុន សេន

កាន់ភូមិភាគពិសេសអ៊ីចឹង ឬក៏អ្នកដទៃផ្សេងទៀត?

**ឆ៖** ស្តាប់ច្រឡំដឹង ថ្ងៃមុន ខ្ញុំមិនមែនថា សុន សេន ហ្នឹងប្រធានភូមិភាគពិសេស គឺអត់ទេ។ ប្រធានភូមិភាគពិសេសហ្នឹងគឺ វន វ៉េត ទេ។ សុន សេន ហ្នឹង តាំងពីមករតនគិរីហ្នឹង មែនទែនគាត់កាន់ទ័ពតែរហូតហ្នឹង កាន់ទ័ព។ នៅរតនគិរី គាត់កាន់កងចល័ត ដល់ចុះមកក្រោមឆ្នាំ៧០ ហើយហ្នឹងមកកាន់សមរភូមិកំពង់ធំនេះ ហ្នឹង សុន សេន។

[១១:១២:៣៦]

**ស៖** សូមអរគុណ។ លោកបានជម្រាបតុលាការថា នៅឆ្នាំ១៩៧២ លោកបានជូនដំណើរលោក នួន ជា ទៅសំឡូត ពេលនុ៎ង ពេលមុនជូនដំណើរហ្នឹង លោកនៅឯណា? ពីព្រោះអីលោកបានជម្រាបតុលាការថា លោកជាកងអង្គរក្ស និងនីរសាររបស់លោក ប៉ុល ពត ហើយម៉េចបានជាជូនលោក នួន ជា ទៅសំឡូតទៅវិញ?

**ឆ៖** ចំណុចនេះគឺថា អ៊ំ ប៉ុល ពត, អ៊ំ នួន ជា, អ៊ំ ខៀវ សំផន ពេលនោះនៅជាមួយគ្នាទេ។ នៅជាមួយគ្នាហ្នឹង គឺថាពួកខ្ញុំនៅហ្នឹង ពេលខ្លះខ្ញុំដើរជាមួយលោក អ៊ំ ប៉ុល ពត ពេលខ្លះខ្ញុំដើរជាមួយ អ៊ំ នួន ជា គឺបាន ដូចបានរៀបរាប់អង្កាល់ ៧២ បានដើរជាមួយគាត់មែន។

**ស៖** លោកនៅចាំបានទេថា ពេលដែលជូនលោក នួន ជា ទៅសំឡូតហ្នឹង លោកទៅជាបេសកកម្ម -- លោក នួន ជា ហ្នឹងទៅជាបេសកកម្មផ្លូវការ ឬក៏ទៅធ្វើអី?

**ឆ៖** ថ្ងៃមុនខ្ញុំបានបញ្ជាក់ជូនហើយថា គឺជូនដំណើរគាត់ហ្នឹង គឺជូនដំណើរគាត់ទៅធ្វើការ។ ធ្វើការនៅភូមិភាគបស្ចិមផង ធ្វើការនៅភូមិភាគតាមផ្លូវហ្នឹង ធ្វើការភូមិភាគនិរតីផង ហើយបានឆ្លងទៅដល់ធ្វើការនៅភូមិភាគពាយ័ព្យ ដល់សំឡូតហ្នឹងគឺ ភូមិភាគពាយ័ព្យអ៊ីចឹង។ ខ្ញុំបានរៀបរាប់ប្រាប់អ៊ីចឹង។

[១១:១៥:១០]

**ស៖** ខ្ញុំត្រឡប់ទៅក្រោយវិញបន្តិច ហើយសឹមទៅមុខទៀត ពេលដែលអាមេរិកាំងទម្លាក់គ្រាប់បែកនៅរតនគិរីយ៉ាងច្រើនសន្ធឹកសន្ធាប់ រាប់ច្រើនតោន ពេលហ្នឹងមានប្រជាជនត្រូវរបួសស្លាប់ច្រើនទេ បើតាមលោកបានបញ្ជាក់ខ្លះៗហើយ ប៉ុន្តែមិនទាន់អស់ លោកថា សត្វគោ សត្វក្របីអីហ្នឹងមានងាប់ច្រើន ហើយចំពោះជីវិតមនុស្សវិញ?

**ឆ៖** ចំពោះជីវិតមនុស្ស ដែលយើង -- កាលដែលយើងនៅក្នុងភូមិ ដែលវាទម្លាក់ឆ្នាំ៦២ ដែលយើងអត់ដឹងខ្លួន យើងនៅក្នុងភូមិ គ្រោះថ្នាក់តើ! ខ្ញុំមិនដឹងថា ដឹងស្លាប់ប៉ុន្មាន របួសប៉ុន្មានទេ ប៉ុន្តែមាន

ស្លាប់ ហើយមានរបួស។ ហើយព្រះករុណាយកកប៉ាល់ហោះមកព្យាបាលភ្នំពេញ ជាហើយត្រឡប់ទៅវិញ។ ដល់វាទម្លាក់ពី៦៩ហ្នឹង វាទម្លាក់ហូរហែមកហ្នឹងគឺថា ឲ្យតែ បើថាយើងនៅក្នុងភូមិគឺត្រូវហ្នឹងហើយ ប៉ុន្តែបើយើងៗជម្លៀស យើងនៅតែក្នុងព្រៃអត់ៗដែលមានគ្រោះថ្នាក់អីទេ គឺអត់ដែលមានគ្រោះថ្នាក់អីទេ គឺថា សត្វនោះដោយសារវាស៊ីស្មៅក្នុងវាលស្រែ ហើយឧបមាថាក្នុងស្រែរបស់ខ្ញុំ ពួកខ្ញុំធ្វើស្រែ ២៤ហិកតា។ ធ្វើ២៤ហិកតាទៅគឺថាដល់ពេលដែលច្រូតហើយអស់ហើយ គឺក្របី កន្លែងហ្នឹងគេនិយមដល់ហ្នឹងគេលែងហើយ។ ប្រមូលផលអស់ហើយ គេលែង ដល់លែងទៅក្របីវាមកស៊ី មកស៊ីពេលនុ៎ងគឺវាបាញ់ហ្នឹងងាប់តែសត្វមែន។ មនុស្សអត់អីទេមនុស្ស។ អាហ្នឹងវគ្គ១២។

[១១:១៧:១៩]

វគ្គទី៣នេះ វគ្គទី៣ក្នុងឆ្នាំ៧៣នេះ គេហៅនៅភូមិៗតាង៉ានោះ នៅភូមិតាង៉ាហ្នឹង គឺអស់មួយពូជតែម្តង អាហ្នឹង៣១នាក់ ទាំងប្រុស ទាំងស្រីហ្នឹង មួយរណ្តៅហ្នឹង វាចាក់បេចំហ្នឹងអស់៣១នាក់ ត្រូវជា បងប្អូនៗខ្ញុំដែរ។

**ស៖** សូមអរគុណ។ ពេលដែលអាមេរិកាំងទម្លាក់គ្រាប់បែកសន្ធឹកសន្ធាប់មកលើខេត្តរតនគិរីទម្លាក់រួចហើយ ទ័ពអាមេរិកាំងហ្នឹង ឬក៏ទ័ពវៀតណាមមាន -- ឬក៏ទ័ពដទៃណាផ្សេងទៀត បានមកធ្វើទីតាំងនៅទឹកដីខេត្តរតនគិរីទេ ឬក៏ទម្លាក់ហើយចេញទៅវិញអស់?

**ឆ៖** ចំណែកដែលវាទម្លាក់នោះហើយ វាទម្លាក់ហើយ ៗវាត្រឡប់ទៅវិញ។ មិនដឹងវាទៅឯណាទេ ប៉ុន្តែតាមដឹងអង្កាល់ហ្នឹងឮៗថា វាច្រើនតែចេញពីព្រៃនគរទម្លាក់ហ្នឹង ព្រោះមូលដ្ឋានអាមេរិកាំងនៅនុ៎ង ចេញពីនុ៎ង ឬមួយទៅពីតាប៉ាវនេះ ទៅពីប្រទេសថៃនេះក៏អាចចេញទៅនុ៎ងដែរ ថាអ៊ីចឹង។ មូលដ្ឋានសឹកវាអ៊ីចឹង។

[១១:១៩:០៥]

ដល់ឆ្នាំ៦៦ៗ ហ្នឹងវាបោះទីតាំងនៅចំណុច២គឺថា នៅភូមិ -- ខ្ញុំថាភូមិញ៉ាងអំមិញនុ៎ង អាហ្នឹងជាកម្លាំងអាមេរិកាំង គឺថាចុះតែម្តង កងទ័ពវាចុះៗនៅហ្នឹងតែម្តង។ ហើយមួយកន្លែងទៀតគឺនៅភូមិ ហៅនៅភូមិតាង៉ាហ្នឹង ភូមិតាង៉ា នៅនឹងវាលហ្នឹង។ វានៅ តែវានៅអត់បានយូរទេ វាចុះវាតត្បាតកន្លែងហ្នឹងនុ៎ង ព្រោះពេលហ្នឹង តាមខ្ញុំដឹងគឺថា ខាងកងទ័ពមិនមែននៅក្នុងដីយើងទេ កន្លែងហ្នឹងកងទ័ព។ ខាងវៀតណាមហ្នឹងគឺថា ពេលហ្នឹងតាមឮដំណឹងទេ មិនដឹងជាពិតមិនពិតទេ ខាងវៀតណាមហ្នឹងគេបាញ់ទម្លាក់កប៉ាល់ហោះប្រហែលជាប្រាំមួយគ្រឿង ដែលគេប្រាប់។ គេបាញ់ទម្លាក់បានប្រាំមួយគ្រឿងពេល

ហ្នឹង។ អ៊ីចឹង ពេលវាវាតត្បាតខ្លាំងហើយអាហ្នឹង។ វាវាតត្បាតតាំងពីវៀតណាមហើយ មកដល់ព្រំដែនយើង។ នៅៗជាអចិន្ត្រៃយ៍ពីរភូមិហ្នឹង។

**ស៖** អរគុណ។ តាំងពីលោកមកសវនាការច្រើនថ្ងៃមកហើយ ខ្ញុំតែងតែឮលោកមានជម្រាបទៅតុលាការថា លោកហៅ ប៉ុល ពត ថាបង -- ថាលោក ថាបងទី១ និងលោក នួន ជា បងទី២។ លោកយល់យ៉ាងម៉េចបានជាលោកហៅ នួន ជា ជាមួយនិង ប៉ុល ពត បងទី១, ទី២ អ៊ីចឹង? លោកឮគេថា ឬក៏លោកទម្លាប់ហៅអ៊ីចឹង ឬយ៉ាងម៉េច? អាហ្នឹងសូមជម្រាបតុលាការ?

[១១:២១:០២]

**ឆ៖** ខ្ញុំសូមបញ្ជាក់ ចំណុចនេះ គឺកាលដែលនៅៗ ក្នុងព្រៃ គឺអត់បានហៅអ៊ីចឹងទេ។ គឺកាលនុ៎ងហៅ បងអ៊ីចឹង។ ប៉ុន្តែចាប់ពីៗឆ្នាំ៧៤ ៗហ្នឹង ដូចខ្ញុំបញ្ជាក់អំមិញថា បានរំដោះនែ៎ ទីប្រជុំជនខុដុគ្គដល់ៗខ្ញុំមិនដឹងអាម៉េច ដល់ឮៗ ដល់ពេលបានរំដោះហ្នឹងហើយ ក៏ក្រោយមកថាឮគេ ឮបងប៉ង់ ទេគាត់ប្រាប់គាត់ថា "អ៊ំ ប៉ុល ពត ហ្នឹងដាក់ថា អ៊ំទី១។ អ៊ំ នួន ជា ដាក់ថា អ៊ំទី២"។ ក៏ហៅអ៊ីចឹងទៅ ក៏ហៅថាអ៊ំទី១ ហើយអ៊ំទី២ អ៊ីចឹងទៅ។ ជួនណាអត់ហៅឈ្មោះគាត់ទេ ហៅថាអ៊ំទី១ ហើយអ៊ំទី២។ ហៅអ៊ីចឹងទៅវាយើងមិនចង់ហៅឈ្មោះគាត់ផ្ទាល់ទេ។ គឺថា ខ្ញុំហៅថា អ៊ំទី១ ហើយនិងអ៊ំទី២ អ៊ីចឹងទៅ។

**ស៖** អរគុណ។ បើអ៊ីចឹងមានន័យថា ឈ្មោះបងទី១, ទី២ គឺឈ្មោះ ប៉ង់ អ្នកដាក់ទេអ៊ីចឹងណ៎ា?

**ឆ៖** ខ្ញុំមិនដឹងថា ប៉ង់ ដាក់។ ជួនណា ប៉ុន្តែ ប៉ង់ បានគាត់ទទួលខុសត្រូវជាមួយពួកខ្ញុំទៅ គាត់ប្រាប់អ៊ីចឹង។ ឮពីសម្ដីគាត់។ មិនដឹងជាគាត់អ្នកដាក់ ឬមួយអ៊ំៗហ្នឹង គាត់តាំងដាក់យ៉ាងម៉េច ក៏ខ្ញុំអត់ដឹងដែរចន្លោះហ្នឹង ខ្ញុំអត់ដឹងទេ។

[១១:២៣:២៩]

**ស៖** សូមអរគុណសាជាថ្មី។ តាំងពីពាក់កណ្ដាលឆ្នាំ១៩៧៣ លោកសាក្សីមានដឹងថា ទ័ពខ្មែរក្រហមវ៉ៃកំពង់ចាម វ៉ៃដល់ទីក្រុងកំពង់ចាមទេ។ លោកមានបានដឹងរឿងហ្នឹងទេ?

**ឆ៖** ខ្ញុំបានដឹងដែរតើ បានដឹងថាវ៉ៃ ព្រោះអង្គាល់ហ្នឹង ទិសធំដំបូង គឺថាវ៉ៃសម្រុក ចង់រំដោះខេត្តកំពង់ធំទេ ប៉ុន្តែខេត្តកំពង់ធំហ្នឹង គេហៅ ត្រពាំងវែងៗហ្នឹងគឺថា វាវាលណាស់ៗគ្រោះថ្នាក់ច្រើនណាស់។ មកដល់ហ្នឹង គឺដកកម្លាំងពីនោះមក គឺមកវ៉ៃ៧៣ហ្នឹង។ វ៉ៃ៧៣ហ្នឹង វ៉ៃចង់រំដោះ ថាចង់រំដោះទាំងស្រុងពេលនុ៎ង ព្រោះរោងចក្រតម្បាញហ្នឹងកាន់កាប់ទាំងអស់កាលហ្នឹង បានដឹកទាំងអស់។ ប៉ុន្តែចៃដន្យអី អាម៉ារីនមកដល់ទៅ បុកមកពីទន្លេមកទៀតទៅ ក៏យើងដកថយទៅ។

ខ្ញុំបានឆ្លងកាត់ អង្កាល់ហ្នឹងគឺថាខ្ញុំមកពីនោះមកឆ្លងកាត់ពេលហ្នឹង ហើយក្នុងហ្នឹងវ៉ៃសមរភូមិកំពង់ចាមហ្នឹង បងប្អូនគាត់ធ្វើទ័ពមកពីរតនគិរីស្លាប់ ៦០នាក់ៗ ហើយសុទ្ធតែជនជាតិតែម្តង ស្លាប់ ៦០នាក់ គេយកសពហ្នឹងទៅបញ្ចុះនៅស្ទឹងត្រង់។ ស្ទឹងត្រង់បានក្រោយមកគឺថា បានធ្វើវិមានសពយុទ្ធជននៅស្ទឹងត្រង់ នៅស្រុកស្ទឹងត្រង់ហ្នឹង។ ខ្ញុំបានដឹង ខ្ញុំបានឆ្លងកាត់ហ្នឹងដែរ។

[១១:២៥:៤៩]

**ស៖** សូមអរគុណចំណុចនេះ។ ខ្ញុំសួរបន្តក្នុងចំណុចនេះបន្តិច ចំណុចដែលខ្ញុំចង់ដឹងនោះ គឺចំណុចជនភៀសខ្លួនដែលវ៉ៃកំពង់ចាម ខ្លាំងហ្នឹងហើយ ចូលដល់ទីក្រុងកំពង់ចាម ហើយកៀរប្រជាជនចេញពីទីក្រុងកំពង់ចាម ហើយជុំវិញទីក្រុងកំពង់ចាមហ្នឹង អង្កាល់ហ្នឹងប្រជាជនទាំងអស់ហ្នឹងយកទៅណា?

**ឆ៖** នៅវ៉ៃ អង្កាល់វ៉ៃក្រុងកំពង់ចាមនេះ គឺប្រជាជនអង្កាល់ហ្នឹងដូចជាៗ អត់មានជម្លៀសអីទេ។ ពីព្រោះយើងអត់កាន់កាប់អត់បានយូរផង អត់បានជម្លៀសអីទេ អង្កាល់ហ្នឹងប្រជាជននៅដូចដើមវិញ។ ហើយដល់យើងដកថយទៅប្រជាជននៅដូចដើមវិញ អត់មានជម្លៀសទៅណាទេ ព្រោះវាពេលវេលាវាខ្លីណាស់ ខ្លីមែនទែន។

**ស៖** ពេលដែលវ៉ៃកំពង់ចាម តើពេលនុំងមេដឹកនាំធំៗដូចជា ប៉ុល ពត, នួន ជា, សុន សេន អីនៅឯណា?

**ឆ៖** អ៊ំ ប៉ុល ពត ហើយនិងអ៊ំ នួន ជា នៅមន្ទីរនោះ មន្ទីរជិតស-៧១ នោះ នៅខាងក្រោយនោះ ប៉ុន្តែមន្ទីរជាច្រើនទៀតមន្ទីរចល័តតាមហ្នឹងវាអត់ខ្វះទេ ខ្ញុំបានរៀបរាប់។ ហើយ សុន សេន គឺ សុន សេន គេហៅ នៅបុសខ្នុរ ទីបញ្ជាការគាត់គឺនៅបុសខ្នុរ។

[១១:២៨:២១]

**ស៖** បើអ៊ីចឹងពេលវ៉ៃកំពង់ចាមខ្លាំងហ្នឹង អ្នកបញ្ជាឲ្យវ៉ៃចូលកំពង់ចាមហ្នឹងគឺ លោក សុន សេនផ្ទាល់ អ៊ីចឹង?

**ឆ៖** ព្រោះទ័ពហ្នឹង គឺជាទ័ពរបស់មជ្ឈិម រួមជាមួយភូមិភាគ៣០៤ អ៊ីចឹងហើយ។

**ស៖** ខ្ញុំអរគុណ។ ខ្ញុំរំលងទៅសំណួរផ្សេងទៀត។ ចំនួនប៉ុន្មានថ្ងៃហើយដែលលោកធ្វើសក្ខីកម្មជូនតុលាការ លោកបានជម្រាបតុលាការហាក់ដូចជា លោកបានជិតដិតជាមួយនឹងលោក នួន ជា បានធ្វើការជាមួយលោកច្រើន ប្រហាក់ប្រហែលនឹងធ្វើជាការជាមួយ ប៉ុល ពត ដែរ ពីព្រោះអីពេលណាក៏

លោកនិយាយថា មាន ប៉ុល ពត, មាន នួន ជា, មាន ខៀវ សំផន នៅជាមួយគ្នា។ ខ្ញុំសូមសួរថា លោកស្គាល់លោក នួន ជា ច្បាស់លាស់ទេ? តាំងពីអាកប្បកិរិយារបស់លោក នួន ជា តាំងពីចរិត តាំងពីសព្វបែបយ៉ាង តើលោកស្គាល់ច្បាស់ទេ?

[១១:៣០:០៥]

**ឆ៖** ខ្ញុំស្គាល់គាត់ តាំងពីខ្ញុំស្គាល់គាត់ហ្នឹង គឺថាខ្ញុំចាត់ទុកថាគាត់ជាអ្នកដឹកនាំមួយរូប អ៊ីចឹង។ ខ្ញុំគោរព ខ្ញុំស្រឡាញ់ ហើយខ្ញុំបម្រើដោយអស់ពីចិត្ត ពីថ្លើម អ៊ីចឹង។ ហើយនិងអាកប្បកិរិយា ឫកពារបស់គាត់ ខ្ញុំៗ -- គាត់ជាអ្នកចេះដឹងដែលបានរៀនសូត្របានខ្ពស់អ៊ីចឹង។ កាលហ្នឹង គាត់មានអាកប្ប-កិរិយាសុភាពរាបសា។ គាត់ធម៌អាថ៌ ក៏គាត់ នែ៎ ដូចថា ធម៌អាថ៌ គាត់ជ្រៅជ្រះដែរ គាត់យល់ពីរឿងធម៌អាថ៌ជ្រៅជ្រះដែរ អ៊ីចឹង។ ខ្ញុំឃើញ ចំពោះគាត់ហ្នឹង អ៊ីចឹង។

**ស៖** មានអ្នកខ្លះចោទថា នួន ជា ជាមនុស្សឃោរឃៅ ជាមនុស្សចិត្តសាហាវ ទោះបីជារៀនសូត្របានចេះដឹង។ នួន ជា អ្នកបញ្ជាឱ្យអ្នកថ្នាក់ដឹកនាំខ្លះ យកមនុស្សទៅចោទប្រកាន់ ទៅសួរចម្លើយ និងទៅកម្ទេច។ រឿងនេះ បើតាមលោកដឹង តើរឿងនេះពិតឬអត់? បើលោកយល់ថា ចិត្តគំនិតគាត់ដូចមាន -- ដូចអំមិញអ៊ីចឹង ថាលោកជាមនុស្សល្អ មនុស្សគួរឱ្យស្រឡាញ់ គួរគោរព អ៊ីចឹង?

[១១:៣១:៥១]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ។ សាក្សីមិនមានភារកិច្ចក្នុងការធ្វើសេចក្តីសន្និដ្ឋានតបនឹងសំណួរ ដែលនាំឱ្យលោកសាក្សីបង្ហាញអំពីគំនិត និងការយល់ឃើញផ្ទាល់ខ្លួនទេ។ សាក្សីមិនមែនអ្នកជំនាញទេ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំបន្តទៅសំណួរមួយផ្សេងទៀត។ លោកបានជម្រាបតុលាការច្រើនមកហើយ ថាលោកបានចូលទៅធ្វើការសិក្សា អប់រំ ប្រជុំ ញឹកញាប់ជាមួយថ្នាក់ដឹកនាំធំៗ ហើយលោកដែលបានឮ ប៉ុល ពត ឬក៏ នួន ជា ឬក៏ ខៀវ សំផន ឬថ្នាក់ដឹកនាំធំៗផ្សេងទៀត ទៅឧទ្ទេសនាមនៅពេលប្រជុំម្តងៗ បាននិយាយអំពីការកម្ទេច ការចាប់ ការសួរចម្លើយ ទាំងអស់ហ្នឹងទេ មានដែលឮឧទ្ទេសនាមរបៀបអ៊ីចឹងទេ?

[១១:៣៣:៣៣]

**លោក វ៉ចាម តុន៖**

**ឆ៖** ចំពោះសំណួរនេះ គឺថាខ្ញុំបានរៀនសូត្រ ដូចខ្ញុំបានញ្ជាក់បន្តបន្ទាប់ហើយថា គាត់រៀនហ្នឹង គាត់ទៅឧទ្ទេសនាមអំពីទស្សនៈសិក្សាក្នុងប្រទេស និងក្រៅប្រទេស និងកសាងផ្ទៃក្នុង នយោបាយចាត់តាំងអីហ្នឹង។ ហ្នឹងគឺថា និយាយពិសោធន៍ពីរឿងដែលជោគជ័យជម្នះនៅសមរភូមិនេះ សមរភូមិនោះ ហើយតំបន់រំដោះយើងមានសហករណ៍ជឿនលឿនអីចឹង គឺមាន។ ប៉ុន្តែអារឿងៗ ឯកសារថា កម្ទេច ដូចមិនមែនទេ។ ឯកសារដែលថាកម្ទេចៗហ្នឹង គឺអត់មានទេ អត់មានបង្រៀនទេ ឯកសារ -- អត់មានឧទ្ទេសនាមទេ អត់មានទេ។ គេមានឧទ្ទេសនាមបំភ្លឺពីរឿង ដែលហៅថា យើងរកឮដ៏ផ្ទៃក្នុងខ្លួនយើង ចំណុចខ្លាំងអី ចំណុចខ្សោយអី ម្នាក់ៗហ្នឹង ហើយស្ម័យទិតៀនហើយ ឲ្យគេជួយមតិ។ ជួយមតិហើយ គេថាចំណុចណាដែលត្រូវរបស់យើង យើងកែលម្អភ្លាមទៅ។ បើចំណុចណាដែលមិនត្រូវទេ យើងទុកសម្រាប់ពិចារណា ដកពិសោធន៍ទៅ ថ្ងៃក្រោយទៅ។ ច្រើនតែណែនាំ គាត់ណែនាំអីចឹង។

[១១:៣៥:០៣]

**ស៖** អរគុណ។ នៅថ្ងៃទី១៨ ឬ១៩ ខែមេសា ឆ្នាំ១៩៧៥ គឺពេលដែលវ៉ៃចូលភ្នំពេញ។ ពេលនុ៎ង សុទ្ធតែទ័ពវ៉ៃចូលដំបូងបំផុត បើតាមលោកជម្រាបតុលាការរួចមកហើយ ពេលនោះលោកដឹងទេថា ទីតាំងរបស់លោក នួន ជា ហើយលោក នួន ជា ផ្ទាល់ហ្នឹង គាត់នៅឯណា? លោកបានចូលភ្នំពេញ លោក នួន ជា បានចូលភ្នំពេញជាមួយមេដឹកនាំធំៗ ជាមួយមេទ័ពហ្នឹងដែរ ឬក៏លោកនៅផ្សេងទេ?

**ឆ៖** ថ្ងៃមុនខ្ញុំបានបញ្ជាក់ ចំណុចនេះគឺថា អ៊ំ ប៉ុល ពត ក៏នៅមន្ទីរស្តុកគោលហ្នឹងៗ ហើយមុននឹងចូលភ្នំពេញ គឺចូលនៅមន្ទីរហ្នឹង។ ឯអ៊ំ នួន ជា គឺនៅត្រង់នោះ ខាងត្រើយទន្លេម្ខាងនោះ ព្រោះកន្លែងមន្ទីរកន្លែងហ្នឹងវាច្រើន។ នៅបាធាយក៏មាន ទៅថ្នល់បំបែកក៏មាន នៅយ-១ នោះក៏មានដែរ។ ខ្ញុំមិនដឹងពេលហ្នឹង គាត់នៅត្រង់ណាទេ ខ្ញុំមិនដឹងទេ។ នៅ៧៤ ហ្នឹង គាត់មានមន្ទីរមួយនៅនុ៎ងដែរ ប៉ុនខ្ញុំមិនដឹងថាគាត់នៅកន្លែងណា ខ្ញុំអត់ដឹងទេ ពេលនុ៎ង។ ប៉ុនមិនៗយូរប៉ុន្មានទេ គេថាជួបឃុំគ្នាភ្លាមៗដែរក្នុងរយៈមួយថ្ងៃពីរថ្ងៃហ្នឹង។

[១១:៣៧:០២]

**ស៖** ខ្ញុំៗគ្រាន់តែសូមបញ្ជាក់សាជាថ្មីថា ពេលដែលវ៉ៃចូលភ្នំពេញ ខ្លួនលោកសាក្សីហ្នឹង លោកមកជាមួយនឹង សុន សេន មកភ្នំពេញ វ៉ៃបានភ្នំពេញហើយ។ គ្រាន់ចង់បញ្ជាក់ថា លោកដឹងទេ ថា នួន

ជា នៅត្រង់ណា? គ្រាន់បញ្ជាក់ថា នួន ជា មកជាមួយគេ ប៉ុនទិសផ្សេង ឬក៏ថាលោកមិនមានព័ត៌មានអំពី នួន ជា ទេ?

**ឆ៖** ខ្ញុំមិនមានព័ត៌មានពីគាត់នៅត្រង់ណាទេ។ អត់មាន ព្រោះខ្ញុំនៅជាប់ជាមួយអ៊ំ ប៉ុល ពត នេះ។

**ស៖** សូមអរគុណ។ លោកសាក្សី លោកស្គាល់លោក សុន សេន ច្បាស់លាស់។ សុន សេន មុខងាររបស់លោកជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងសន្តិសុខក្នុងនិងក្រៅប្រទេស។ បន្ទាប់ពីលោក សុន សេន លោកជារដ្ឋមន្ត្រីហើយ ប៉ុនបន្ទាប់ពីលោក សុន សេន ដូចជាលោក អៀង សារី គាត់រដ្ឋមន្ត្រីក្រសួងការបរទេស ប៉ុនមនុស្សទីពីររបស់ សុន សេន គឺ សូរ ហុង។ ហ្នឹងបើតាមលោកខឡេសនាមពីព្រឹកមិញ ម្សិលមិញអ៊ីចេះ។ ប៉ុន្តែលោក សុន សេន បន្ទាប់លោក សុន សេន នោះ អនុលោក សុន សេន នោះ អ្នកណាគេ? លោកដឹងទេ?

[១១:៣៩:១០]

**ឆ៖** ក្រោមលោក សុន សេន គឺថាខ្ញុំច្រើនតែហៅ -- មានន៎ មានបង ម៉េត ច្រើនតើ មាន បង ទាញ, មាន បងណាត, មាន បងពីន, ហើយមាន បងសារឿន គេហៅបង សារឿន ១៤ នោះ, ហើយមាន បងសាន ច្រើនតើ ខាងយោធា ច្រើនតើ។

**ស៖** អរគុណ។ លោក សុន សេន មានអ្នកជំនួសការងារគាត់ពេលដែលគាត់មិននៅច្រើន ដូចលោកបានជម្រាបតុលាការអំមិញអ៊ីចឹង។ ចុះពេលដែលលោក សុន សេន ទៅបំពេញបេសកកម្មនៅទិសបូព៌ា ពេលដែលទិសបូព៌ាមានអាសន្នវ៉ៃតប់គ្នានៅខាងបូព៌ាទុំង លោក សុន សេន ទៅបូព៌ាទុំងលោកដឹងទេ?

**ឆ៖** គាត់ទៅបូព៌ាហ្នឹង ដឹងតើ គាត់ទៅនៅនឹងស្បូង នៅនឹងស្បូង។ បន្ទាប់មកក្រោយទៀត មកនៅកំពង់ចាម។

**ស៖** អរគុណ។ ពេលដែលលោក សុន សេន ទៅបូព៌ា តើលោកដឹងថាមានអ្នកណា -- លោក សុន សេន តែងតាំងអ្នកណាជំនួសលោកនៅភ្នំពេញនេះទេ ដើម្បីការងារ? ការងារការពារជាតិ និងសន្តិតសុខ។

[១១:៤១:១៩]

**ឆ៖** ចំណុចនេះ ខ្ញុំអត់ចូលជ្រៅទេ ព្រោះខ្ញុំភ្លាប់អត់បាន ក្រសួងខុសគ្នា ខ្ញុំភ្លាប់អត់បាន។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរប្លែកមួយទៀត ចង់សួរថា លោកបានជម្រាបតុលាការរួចមកហើយថា លោកធ្លាប់បានទៅបេសកកម្មជាមួយ ប៉ុល ពត ទៅប្រទេសចិន។ ពេលដែលលោកទៅបេសកកម្មនៅប្រទេសចិន ជាមួយ ប៉ុល ពត និងគណៈប្រតិភូមួយចំនួនទៀតនោះ ក្នុងឋានៈលោកជាអ្វីពេលនុ៎ង?

**ឆ៖** ខ្ញុំទៅពេលហ្នឹងក្នុងឋានៈខ្ញុំទៅរៀនសូត្រទេ ទៅឃើញប្រទេសគេទៅ ពិធីការគេយ៉ាងម៉េច គេរៀបចំផ្ទះសម្បែងហ្នឹងយ៉ាងម៉េច កន្លែងទទួលភ្ញៀវ ហើយកន្លែងទេសចរណ៍គេយ៉ាងម៉េច។ គេថាទៅរៀនសូត្រ នែ៎គឺខ្ញុំជា -- គឺមើល មើលរបៀបរបបគេទទួលភ្ញៀវនៅស្រុកចិនហ្នឹង មើលឃើញគេរៀបចំម៉េចៗហ្នឹង។ គេនែ៎ អ៊ំ អៀង សារី ប្រាប់ៗខ្ញុំអ៊ីចឹង។ អាកន្លែងទៅទស្សនកិច្ចកន្លែងណាខ្លះហ្នឹង គាត់ថាមើលការរៀបចំរបស់គេ ការទទួលភ្ញៀវរបស់គេ ការ -- តំបន់ទេសចរណ៍គេ គេរៀបចំម៉េច ឲ្យមាន -- ឲ្យខ្ញុំឃើញពន្លឺ ពន្លឺខាងក្រៅប្រទេសដែលគេបានរៀបចំអ៊ីចឹង បាទ។

[១១:៤៣:២១]

**ស៖** សូមអរគុណ។ ពេលដែលលោកទៅប្រទេសចិនធ្វើទស្សនកិច្ចជាមួយគណៈប្រតិភូ ប៉ុល ពត ហ្នឹង ពេលនុ៎ង ពេលដែលគណៈប្រតិភូបានចូលប្រជុំជាមួយនឹងអ្នកថ្នាក់ដឹកនាំចិន តើលោកបានចូលទៅរួមប្រជុំជាមួយទេ ជាមួយអស់លោកធំៗហ្នឹងទេ?

**ឆ៖** ខ្ញុំអត់បានចូលប្រជុំទេ គឺថាពួកខ្ញុំការពារប៉ុន្មានហ្នឹង អត់ៗមានចូលប្រជុំទេ។ គេបញ្ចាំងកុនឲ្យមើល ពួកខ្ញុំប៉ុន្មាននាក់ហ្នឹង បញ្ចាំងឲ្យមើល។

**ស៖** សំណួរមួយផ្សេងទៀត ខ្ញុំសួរថា ការប្រជុំមុនខែមេសា ឆ្នាំ១៩៧៥ ស្តីអំពីការជម្លៀសប្រជាជនចេញពីទីក្រុង ពេលនោះលោកសាក្សីបានជម្រាបតុលាការថា "មានការគាំទ្រពី នួន ជា មានការគាំទ្រពីលោក ខៀវ សំផន និងថ្នាក់ដឹកនាំដទៃផ្សេងទៀត។ រួចពីនោះទៅ ការប្រជុំនោះបានទះដៃទទួលយក ដើម្បីជម្លៀសប្រជាជនចេញពីភ្នំពេញ"។ ពេលដែលទះដៃអបអរសាទរនូវគំនិតហ្នឹងហើយ ពេលហ្នឹងការប្រជុំហ្នឹងឈប់ប្រជុំ ឬក៏បន្តទៅទៀត?

[១១:៤៥:២៨]

**ឆ៖** គ្រាន់តែអ៊ំប្រធានអង្គប្រជុំហ្នឹង គាត់សរុបមតិហើយ គឺចប់ដល់ម៉ោង ដល់ថ្ងៃត្រង់ហ្នឹងចប់ គឺបែកគ្នាបណ្តោយ។

**ស៖** លុះដល់ពេលក្រោយមកទៀតនោះ មានប្រជុំសាជាថ្មីទៀត និយាយអំពីរឿងជម្លៀសហ្នឹង

ទៀតទេ?

**ឆ៖** ប្រជុំក្រោយ ដូចអត់មានៗ និយាយពីរឿងជម្លៀសទៀតទេ។

**ស៖** លោកសាក្សី មានដែលឮថ្នាក់ដឹកនាំ ដូចជាលោក ប៉ុល ពត, នួន ជា, ដូចលោក ខៀវ សំផន ក្ដីនិយាយអំពីការបែងចែកប្រជាជន ពេលដែលជម្លៀសឲ្យទិសណា? ទៅតំបន់ណាប៉ុន្មានៗទេ? មានដែលឮ ក្រៅផ្លូវការ ឬផ្លូវការ?

[១១:៤៦:៥៨]

**ឆ៖** ខ្ញុំអត់ដែលឮគាត់ប្រជុំប្រកាសរឿងប្រជាជនហ្នឹងទេ អត់ដែលឮផង អត់ដែលឮគាត់និយាយទេ។

**ស៖** អរគុណ។ ខ្ញុំសូមដូរសំណួរ។ កាលលោកសាក្សី -- តើលោកសាក្សីអាចជម្រាបតុលាការបានទេថា ក្នុងក្រសួងនីមួយៗជាពិសេសក្រសួងការបរទេស ដែលលោកបានធ្វើការនៅក្នុងនុំង បើតាមខ្សែបណ្ដោយរបស់បក្សមាន៖ ទីមួយ លេខាបក្ស គឺលោក អៀង សារី ក្នុងក្រសួងការបរទេស។ បន្ទាប់មកមានអនុលេខាបក្ស គឺលោក សួរ ហុង និងសមាជិក។ ចុះចំពោះផ្នែកខាងរដ្ឋបាលវិញ ដូចជានៅក្រសួងការបរទេសនេះជាដើម ឬក្រសួងសន្តិសុខ ឬក្រសួងពាណិជ្ជកម្ម ឬក្រសួងដទៃទៀត តើមានរចនាសម្ព័ន្ធ ដូចបក្ស -- រចនាសម្ព័ន្ធដូចក្រសួងការបរទេសដែរឬទេ? ឬក៏ក្រសួងមួយៗធ្វើទៅតាមការយល់ឃើញរបស់ខ្លួន?

[១១:៤៨:៣៦]

**ឆ៖** តាមការសង្កេតឃើញគឺថា តាមមិត្តភក្តិដែលបាននៅក្រសួងផ្សេងៗ ការចាត់តាំងហ្នឹងគឺថា ដូចៗគ្នាទេ។

**ស៖** អរគុណ។ បើតាមការយល់ដឹង និងការមើលឃើញរបស់លោកនៅក្នុងក្រសួងការបរទេសផ្ទាល់ ក្នុងឋានៈលោកជាមន្ត្រីជាន់ខ្ពស់ម្នាក់នៅក្នុងក្រសួងនោះ លោកឃើញមន្ត្រីធំៗក្នុងក្រសួងនោះភាគច្រើនជាមនុស្សរៀនចេះដឹង មួយចំណែកធំ ប្រភពដើមមកពីហ្គ្រុង។ រឿងហ្នឹងពិតអ៊ីចឹងទេ?

**ឆ៖** រឿងហ្នឹងពិតប្រាកដអ៊ីចឹងហើយ បាទ។

**ស៖** អរគុណ។ ចុះក្រៅពីមន្ត្រីធំៗមកពីហ្គ្រុង ដែលបង្កើតដោយសម្ដេចនរោត្តម សីហនុ នុំងគឺមន្ត្រីដែលចាត់តាំងពីខាងខ្មែរក្រហមទៅនុំង ធ្វើការងារនៅក្នុងក្រសួងហ្នឹងស៊ីសង្វាក់គ្នាល្អត្រឹមត្រូវទេ ឬក៏យក -- ឬក៏យ៉ាងម៉េច?

[១១:៥០:៤២]

**ឆ៖** ធ្វើការងារជាអចិន្ត្រៃយ៍ គឺថាល្អតើ! គឺថាល្អកល្អិននឹងគ្នា សាមគ្គីគ្នា សហការគ្នា គឺអត់មានបញ្ហាអីទេ ល្អ។

**ស៖** ខ្ញុំនៅសល់ពីរសំណួរទៀតអស់ហើយ ប៉ុន្តែម៉ោងក៏ជិតដល់ដែរ។ ខ្ញុំសូមសួរលោកសំណួរមួយផ្សេងទៀត លោកសាក្សីបានបញ្ជាក់ជម្រាបទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកាលពីថ្ងៃទី៣០ មានន័យពីម្សិលថា “គ្រប់មូលដ្ឋានមានចំណាត់ការខុសៗគ្នា ខ្លះឲ្យស៊ីបបរលាយត្រកួន ខ្លះមានបាយហូបពេលឃើញនោះ -- ពេលនោះលោកបាននិយាយជំទាស់ទៅតំបន់ដែលលោកឃើញនោះ ឬរឿងបែបនេះបានរាយការណ៍ទៅលោក អៀង សារី និងជូនកាលជួបអ៊ំទី១ ម្តងម្បាម ហើយបានៗជម្រាបទៅបងទី១ -- អ៊ំទី១ ដែរ ហើយគាត់ឆ្លើយថា ចាំធ្វើការស្វ័យទិតៀនទៅ។ ក្នុងរឿងនេះ បក្សមានគោលការណ៍ឲ្យហូបឆ្អែត ដើម្បីមានកម្លាំងធ្វើការ”។ តើចំណាត់ការដែលបានធ្វើនៅសហករណ៍ខាងលើនោះ នេះជាការចាត់ការរបស់មេសហករណ៍ផ្ទាល់ និងមេបន្តបន្ទាប់ផ្ទាល់ខ្លួន ដែលខ្លួនយល់ឃើញ ឬក៏ថាជាបញ្ហាពីថ្នាក់លើមក?

[១១:៥៣:១៩]

**ឆ៖** ចំណុចនេះគឺថា ខាងលើអត់មានណែនាំទេអ៊ីចឹងទេ។ អត់មានៗទាល់តែសោះតែម្តង។ គឺណែនាំធ្វើគឺដើម្បីឆ្អែត។ ខ្ញុំលើកឧទាហរណ៍ ដូចពួកខ្ញុំនៅធ្វើស្រែនៅរតនគិរី អាហ្នឹងហើយគេថា ខ្លួនឧបត្ថម្ភខ្លួន ខ្លួនទីពឹងខ្លួន ខ្លួនឯករាជ្យម្ចាស់ការខ្លួនឯង ក្នុងរបស់ដែលយើងធ្វើបានហ្នឹង គឺថា យកឆ្អែតនេះជាទី១ ៗ។ ទី២ ចាំចែកទៅមន្ទីរផ្សេងៗ គឺខាងខ្ញុំ គឺក្តាប់បានគឺអ៊ីចឹង។ ដល់ឃើញគេធ្វើហ្នឹងវាខុសបើខុសនេះបានខ្ញុំប្រតិកម្ម ខ្ញុំថា បើខុសហ្នឹងបានខ្ញុំនិយាយថា បើតាមឯកសារណែនាំនេះ កម្មាភិបាលនេះអត់កើតជាការទេ កម្មាភិបាលបែបហ្នឹង បើមានតំបន់ដែលអ៊ីចឹងឲ្យប្រជាជនហូបបបរ។ ហូបបបរមានសាច់ជ្រូកទៅមិនថាទេ លេងៗជាមួយ -- ខ្ញុំទៅបើកមើលឃើញត្រកួនមែនៗតែម្តង។ ឃើញថាវាៗខុសណា៎។ បើខ្ញុំផ្ទាល់ខ្លួនខ្ញុំវិញ ខ្ញុំពួកនេះពួកក្បត់មែនទែនហើយ ធ្វើបាបប្រជាជន ពួកហ្នឹងមិនដឹងវាមានបំណងអីបានវាធ្វើបាបប្រជាជនម្ល៉ឹងៗម្ល៉េះ។ ជាមាគ៌ារបស់បក្ស គឺអត់មានអ៊ីចឹងទេ អត់មានទាល់តែសោះតែម្តង។ ប៉ុន្តែវាមានដុំអ៊ីចឹងណា៎។ គឺខ្ញុំសន្និដ្ឋានថា ពួកនេះមិនអនុវត្តមាគ៌ារបស់បក្សទេពួកនេះពួកកម្ទេចមាគ៌ារបស់បក្សហើយ អាហ្នឹង គឺជាខ្ញុំសន្និដ្ឋានខ្លួនឯងទេ។ បានខ្ញុំប្រតិកម្មអ៊ីចឹង។ ដូចថាខ្ញុំស្គាល់អ្នកដឹកនាំហ្នឹងផង ដូចថា ខ្ញុំចង់មានមតិ ខ្ញុំថាវាខុសពីមាគ៌ា បានខ្ញុំមានមតិអ៊ីចឹង។

[១១:៥៥:៣៤]

**ស៖** អរគុណ។ ពេលវេលាប្រែប្រួលពីឆ្នាំ១៩៧០ ដល់១៩៧៥ និងនៅឆ្នាំ១៩៧៥ មកដល់ឆ្នាំមួយពាន់ -- ដើមឆ្នាំ១៩៧៩ នៅខាងភ្លៀសានដែលតាមលោកដឹង លោកមានស្រុកកំណើតនៅនុ៎ង។ ពីរយៈពេលនេះ ៧០ មកដល់៧៥, ៧៥-៧៩ ពេលវេលាហ្នឹង ខ្ញុំថាប្រែប្រួល ពេលនុ៎ង ពីរយៈពេលហ្នឹង តើមានទ័ពវៀតណាមចូលមកវ៉ៃលុក ឬក៏ខាងខ្មែរហ្នឹងទៅវ៉ៃចូលទៅឈ្លានពានទៅវៀតណាមញីកញាប់គ្នាទៅវិញទៅមកទេ ឬក៏លោកអាចអត្ថាធិប្បាយយ៉ាងម៉េចបាន?

**ឆ៖** ចំណុចនេះ គឺថាន៎ែ នៅរតនគិរី ពីភូមិសាស្ត្រហ្នឹង គឺវាជាប់ព្រំដែនវៀតណាម ជាប់ព្រំដែនវៀតណាម។ ដល់ជាប់ព្រំដែនវៀតណាមអ៊ីចឹង ហើយរយៈហ្នឹង រយៈតាំងពីឆ្នាំ៧០ ដល់៧៨ មែនទែនខ្ញុំចន្លោះហ្នឹងគឺថា ខ្ញុំអត់បាន -- តាំងពីខ្ញុំចុះជាមួយគាត់មក ខ្ញុំអត់បានទៅទេរតនគិរី។ ប៉ុន្តែក្នុងរយៈបីឆ្នាំហ្នឹង បងថ្លៃខ្ញុំគាត់ធ្វើធំដែរ កាលនុ៎ងគាត់សមាជិកក្នុងភូមិភាគភ្លៀសានហ្នឹងដែរ គាត់ធ្វើធំដែរ។ គាត់មកភ្នំពេញទៅ ខ្ញុំទៅជួបគាត់ ខ្ញុំសាកសួរគាត់ទៅ គឺគាត់ថាន៎ែ ចំណុចអង្កាល់ដែលៗ អង្កាល់វៀតណាមមិនទាន់មានរឿងជាមួយយើងនោះ វៀតណាមបានសុំដីយើងរស់នៅ ដែលកន្លែង កន្លែងកន្ទុយនាគហ្នឹង។ ប៉ុន្តែដល់រំដោះហើយហ្នឹង គឺវៀតណាមយករហូត រហូតដល់សព្វថ្ងៃហ្នឹង កន្លែងហ្នឹង អត់មានឲ្យយើងវិញឯណា នៅរហូតរាល់ថ្ងៃហ្នឹង។ អាហ្នឹងកន្លែងដែល កន្លែងដែលខ្ញុំបានបញ្ជាក់ថា ខ្ញុំបានយកសំបុត្រទៅឲ្យគេនោះ កន្លែងបន្ទាយហ្នឹង។ ឥឡូវបន្ទាយហ្នឹងនៅតែជាដីវៀតណាមតើ វៀតណាមគេយកអស់ទៅហើយ។

[១១:៥៨:៤៣]

ហើយកាលដែលបីឆ្នាំ គាត់ថាកន្លែងហ្នឹងមានបញ្ហា។ មានបញ្ហាត្រង់ថា យើងថាសំណូមពរពីខាងលើថា កាលដែលសង្គ្រាម គេសុំយើងនៅ។ ឥឡូវសុំឲ្យគេត្រឡប់ទៅវិញទៅ ទៅនៅដីគេវិញទៅ។ ដីខ្មែរ ទុកឲ្យខ្មែរគ្រប់គ្រងទៅ ដីវៀតណាម វៀតណាមគ្រប់គ្រងខ្លួនឯងទៅ។ គេអត់ទៅទេ ចំណុចហ្នឹងមានការចម្បាំងគ្នាដែរ។ គាត់បញ្ជាក់អ៊ីចឹង។ ឯចំណុចអូរយ៉ាដាវនេះ បណ្ដោយទន្លេសេសាននេះក៏មានវ៉ៃគ្នាដែរ វ៉ៃហ្នឹង វ៉ៃក្នុងដីខ្មែរទេ។ វ៉ៃដោយសារវាមិនគោរពអារឿងព្រំដែនហ្នឹងហើយ វាវ៉ៃ។ វាចង់ដល់ហ្នឹង វានិយាយមក គឺថា “អ្ហឺះ! ន៎ែ ខាងនោះទន្លេសេសានរបស់វាទាំងអស់ហ្នឹង”។ វាចេញមកអ៊ីចឹង។ ដល់រំដោះហើយវាចេញមកអ៊ីចឹង។ នេះហើយ។ ហើយបងប្អូនខ្ញុំនៅវៀតណាមយ៉ាងច្រើនបងប្អូនខ្ញុំយ៉ាងច្រើន។ ច្រើនភូមិណាស់វៀតណាមហ្នឹង។

[១១:៥៩:៥១]

ឆ្នាំ២០១០ហ្នឹង ខ្ញុំទៅ ខ្ញុំទៅដល់នោះ ទៅដល់ព្រៃគូនោះ។ ក្រុងព្រៃគូ ខេត្តយ៉ាកឡាយ ខ្ញុំទៅដល់ហ្នឹង។ ខ្ញុំបានសាកសួររឿងហ្នឹង គាត់ថា គេអប់រំ គេថាឥឡូវហ្នឹង ខ្មែរហ្នឹងគឺថាអនាគតហ្នឹង គឺថាដីខ្មែរគឺរបស់វៀតណាមតែតាំងអស់ហ្នឹង បើវៀតណាមបានរំដោះ ៧៩ គេថា របស់គេទាំងអស់។ ថ្ងៃណាក៏គេយកបានដែរ គេគ្រាន់តែលើកកម្លាំងគេតែ ៥០លានមកនៅកម្ពុជា គេថានៅបានបាត់ហើយ។ អ្ហ៎ ខ្ញុំថា ខ្ញុំស្ដាប់ទៅនៅឯណេះទៅៗស្ដាប់អីណោះទៅ វាទៅជាអ៊ីចឹង។ អានេះខ្ញុំចង់រៀបរាប់ដែលខ្ញុំដឹងរឿងហ្នឹង ហ្នឹងរឿងដែលប្រយុទ្ធគ្នាវាមានហេតុការណ៍វាអ៊ីចឹង។ ហើយភស្តុតាងដែលខ្ញុំនេះ គឺថា បងប្អូនខ្ញុំនៅហ្នឹងគឺថា គេនិយាយអ៊ីចឹង។ គេនិយាយអ៊ីចឹង ខ្ញុំថា អានេះរឿងនយោបាយយើងមិនបាច់ឈឺក្បាលទេ យើងគិតតែធ្វើស្រែធ្វើចម្ការទៅយើងនោះ។

[១២:០០:៥៤]

**លោក សុន អរុណ៖**

សូមអរគុណលោកសាក្សី។ ខ្ញុំបញ្ចប់ ខ្ញុំអស់សំណួរខ្ញុំ ហើយម៉ោងក៏ដល់ដែរ។ ខ្ញុំសូមឲ្យ -- សុំលោកប្រធានអនុញ្ញាតឲ្យសហភាតារបស់ខ្ញុំនឹងបន្តពីខ្ញុំនៅពេលថ្ងៃរសៀល ប្រសិនជាអាចធ្វើបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណសាក្សី ឥឡូវនេះដល់ពេលសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់សម្រាកសម្រាប់សាក្សី នៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់ ហើយឲ្យអញ្ជើញគាត់ និងមេធាវីរបស់គាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។

សូមអញ្ជើញលោកមេធាវី!

[១២:០១:៥២]

**លោក អេនគ្រូ អ៊ីនូហ្ស៊ីុ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំឡើងមកនេះគឺដើម្បីស្នើថា កូនក្ដីរបស់ខ្ញុំមានឈឺឆ្អឹងខ្នង ហើយ

និងឈឺក្បាល ហើយនិងមិនអាចផ្តង់អារម្មណ៍បានទេ។ ដូច្នេះយើងនឹងអនុវត្តទៅតាមនីតិវិធី គាត់សូមអនុញ្ញាតទៅតាមដាននៅបន្ទប់ខាងក្រោម។ ចំណុចមួយទាក់ទងទៅនឹងការសន្ទនា ហើយនិងការពិភាក្សាវវាង -- នៅថ្ងៃព្រហស្បតិ៍នោះ រវាងសាក្សី។ ចៅក្រម ខាតវ៉ាយថ៍ បានលើកហើយថា ការទទួលខុសត្រូវគឺជារបស់មេធាវីក្នុងការលើកបញ្ហានេះ គឺបញ្ហា -- គឺកង្វះនៃការតាមដានដោយសកម្មហ្នឹងគឺថា ការទទួលខុសត្រូវគឺរបស់មេធាវី បើសិនជាកូនក្តីរបស់លោកមិនអាចចូលរួមនៅពេលណា -- មេធាវី សុន អរុណ បានលើកឡើងពីម្សិលមិញហើយ។ ខ្ញុំឲ្យកត់ត្រានៅក្នុងតុលាការ ក្នុងគោលបំណងថា នៅពេលអនាគតកាលណាមានសំណើ ឬបណ្តឹងអីគឺថា ខ្ញុំ -- នៅពេលដូចជាម្សិលមិញល្ងាចនោះ ហើយល្ងាចថ្ងៃព្រហស្បតិ៍កន្លងមកដែរ គឺកូនក្តីរបស់ខ្ញុំគឺមិនបានតាមដានដោយសកម្មទេ នៅក្នុងដំណើរការនីតិវិធីដូច្នេះ ខ្ញុំមិនរិះគន់ឧបករណ៍ដែលផ្តល់ឲ្យយើងខ្ញុំទេ។ ខ្ញុំគ្រាន់តែជម្រាបថា នេះជាការពិតហើយខ្ញុំទុកចិត្តថា អង្គជំនុំជម្រះទទួលស្គាល់ការលំបាកនេះ។ ហើយយើងខ្ញុំនឹងចូលរួមដោយសកម្មជាមួយកូនក្តីរបស់យើង ប៉ុន្តែ -- ហើយយើងនឹងពិនិត្យបញ្ហានេះ នៅពេលក្រោយទៀត។ សូមអរគុណ។

[១២:០៣:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៥:២៩]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា សូមលោកឡើងបង្ហាញសាជាថ្មីម្តងទៀតឲ្យច្បាស់លាស់ ថាតើនិយាយអម្បាញ់មិញនេះ មានគោលបំណងអ្វីច្បាស់លាស់ទៅ។ លោកនិយាយឲ្យច្បាស់ ហើយសាមញ្ញ ដើម្បីងាយយល់ ទាំងអង្គជំនុំជម្រះ ទាំងភាគី និងសាធារណជនចូលរួមផង។

លោកស្នើសុំអី អំមិញហ្នឹងច្បាស់លាស់? ព្រោះកន្លងមក គឺពីថ្ងៃមុន មិនមានភាពច្បាស់លាស់ហ្នឹងហើយ បានជាមានការស្រាយបញ្ជាក់ម្តងរួចមកហើយ ដោយអង្គជំនុំជម្រះសាលាដំបូង ដោយការប្រើពាក្យពេចន៍របស់លោក ហាក់ដូចជាកេងនៅក្នុងពេលដែលលោកធ្វើ ឡើងធ្វើសេចក្តីថ្លែងការណ៍នេះ។ សំណើក៏មិនមែន ឬក៏សង្កេតបញ្ហាអ្វីមួយក៏មិនច្បាស់លាស់ ពាក់ព័ន្ធជាមួយនឹងការលះបង់សិទ្ធិរបស់លោក នួន ជា នេះ។ លោកនិយាយឲ្យបានច្បាស់លាស់ ប្រសិនបើនៅក្រោមមានបញ្ហា យើងនឹងសម្រេចថា បដិសេធសំណើ ហើយឲ្យគាត់អង្គុយតាមដាននៅក្នុងកិច្ចដំណើរការសវនាការនេះ ដោយផ្ទាល់ជានិច្ចតែម្តង។ លោកនិយាយខ្លីទៅបានហើយ។

[១២:០៦:៥៨]

អង្គជំនុំជម្រះមិនត្រូវការស្ដាប់លោកថ្លែងការណ៍នូវបញ្ហាផ្សេងៗទៀត មកពាក់ព័ន្ធនឹងបញ្ហានេះទេ។ បញ្ហាការចូលរួម ឬក៏មិនចូលរួមដោយផ្ទាល់ ក្នុងពេលសវនាការនេះ របស់លោក នួន ជា។ ចំពោះកាតព្វកិច្ចក្នុងនាមមេធាវីរបស់លោក គឺលោកបំពេញកាតព្វកិច្ចឲ្យត្រឹមត្រូវតាមឋានៈ តាមតួនាទីរបស់លោកទៅ នៅក្នុងកិច្ចការពារនូវកូនក្ដីរបស់លោកគ្រប់បរិបទទាំងអស់ ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការសវនាការ។

**លោក អេនឌ្រូ អ៊ីអាន្ទ្រូហ្ស៊ីៈ**

សូមអរគុណលោកប្រធាន។ គឺសូមអភ័យទោសដែលខ្ញុំមិនច្បាស់ ប៉ុន្តែខ្ញុំជម្រាបឲ្យបានច្បាស់លោក នួន ជា ឥឡូវនេះ គាត់មានជំងឺឈឺខ្នង ឈឺក្បាល ហើយនិងមិនអាចផ្ចង់អារម្មណ៍បានទេ។ សំណើដែលយើងខ្ញុំស្នើនោះ គឺគាត់សុំទៅតាមដាននូវតាមនីតិវិធីនៅបន្ទប់ខាងក្រោម។ ហើយខ្ញុំនឹងជូនលិខិតប៉ះបង់សិទ្ធិទៅតុលាការ។

ចំណុចទីពីរ ដែលខ្ញុំចង់ជម្រាបហ្នឹង គឺថាជាចំណុចទូទៅ ក្នុងន័យនេះ ខ្ញុំព្យាយាមឲ្យមានកំណត់ត្រាតុលាការ និងជូនដំណឹងដល់តុលាការថា អ្វីដែលខ្ញុំយល់ ការណែនាំពីចៅក្រម ខាតវ៉ាយថ៍ ថាជាការទទួលខុសត្រូវរបស់ខ្ញុំដើម្បីកត់ត្រា។ ពីម្សិលមិញ នៅពេលល្ងាច ហើយនិងថ្ងៃព្រហស្បតិ៍ល្ងាចដែរ កូនក្ដីរបស់ខ្ញុំ គឺមិនបាន -- មានលទ្ធភាពតាមដានពីបន្ទប់ខាងក្រោមដោយមានប្រសិទ្ធភាពទេ។

[១២:០៨:២៧]

ខ្ញុំជម្រាបនេះ ដើម្បីកត់ត្រាបានត្រឹមត្រូវ ដើម្បីថាអនាគតទៅ យើងអាចនឹងដាក់សំណើ ឬក៏បណ្ដឹង ហើយខ្ញុំសង្ឃឹមថា ហើយអង្គជំនុំជម្រះយល់ឃើញថា មានការលំបាក ពេលខ្លះកូនក្ដីរបស់ខ្ញុំគឺមិនមានសមត្ថភាពតាមដានបានទេ។ ហើយថ្ងៃនេះ គឺគាត់ -- ថ្ងៃនេះ គាត់បោះបង់សិទ្ធិរបស់គាត់ នឹងចូលរួមនៅទីនេះ ហើយគាត់ទៅតាមដានពីខាងក្រោម។ ដូច្នេះ ខ្ញុំឲ្យមានកំណត់ត្រារបស់តុលាការច្បាស់ប៉ុណ្ណឹងទេ បាទ។ បាទ តើច្បាស់ទេ លោកប្រធាន? ចៅក្រម ខាតវ៉ាយថ៍ បានគ្រវីក្បាល តើលោកស្រីត្រូវការព័ត៌មានអ្វីបន្ថែមដែរឬទេ?

[១២:០៩:០៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៩:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ។ កត់សម្គាល់ថាលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដី នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចតាមដានកិច្ចដំណើការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយដែលស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃដំណើរការនៅរសៀលនេះ។

[១២:១០:៥៤]

ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ហើយនៅរសៀលនេះទុកលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក លោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកបន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១១ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៥៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តនេះ គឺក្រុមមេធាវី នួន

ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី វ៉ាចាម តុន។ លោក វ៉ាចាម តុន មុននឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា អង្គជំនុំជម្រះសូមរំឭកលោកសាក្សីថា សូមលោកសាក្សីស្តាប់សំណួរឲ្យបានច្បាស់លាស់ ហើយបើមិនច្បាស់ទេ លោកអាចសូមឲ្យអ្នកសួរហ្នឹងសួរសំណួរលោកសាជាថ្មីម្តងទៀត។ ហើយលោកគប្បីឆ្លើយតបទៅនឹងកម្រិត -- តបទៅនឹងសំណួរបានហើយ ចៀសវាងការអត្ថាធិប្បាយវែង អាចឆ្ងាយ ដែលចាកចេញពីសំណួរ ឬក៏មិនឆ្លើយតបទៅនឹងសំណួរ ដែលបានសួរ។

សូមអញ្ជើញ! អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។

[១៣:៣៣:១៤]

**លោក អេនឌ្រូ អ៊ីអ្នូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំសូមបំភ្លឺ គឺថាបញ្ហាបច្ចេកទេសដែលបានដោះស្រាយហើយ។ ប៉ុន្តែយើងឃើញថា មានបញ្ហាមួយចំនួនទាក់ទងទៅនឹងឯកសារដែលត្រូវបង្ហាញលើអេក្រង់ តើបញ្ហាដោះស្រាយរួចហើយនៅខាងបច្ចេកទេសលោកប្រធានបាទ?

**ប្រធានអង្គជំនុំ៖**

បាទ បញ្ហានេះត្រូវបានដោះស្រាយរួចហើយ ទៅជាប្រក្រតីភាពឡើងវិញហើយ។ សូមអញ្ជើញ!

**លោក អេនឌ្រូ អ៊ីអ្នូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។

[១៣:៣៣:៥៦]

**សួរដោយលោក អេនឌ្រូ អ៊ីអ្នូហ្ស៊ី៖**

**ស៖** លោកសាក្សី ខ្ញុំនឹងនិយាយដោយខ្លីៗ ដោយសង្ខេបទេ។ ប៉ុន្តែលោកបានបង្ហាញខ្លួន គឺថាលោកបាននិយាយបញ្ហាមួយចំនួន ហើយខ្ញុំនឹងៗសួរវែងជាងអ្វីដែលខ្ញុំចង់ ប្រសិនបើចាំបាច់។ ហើយខ្ញុំនឹងនិយាយយឺត ដើម្បីឲ្យៗ សហព្រះរាជអាជ្ញាបានជ្រាបថា ខ្ញុំប្រហែលជាមួយម៉ោងជាងបន្តិចបន្តួចតែប៉ុណ្ណឹងទេ។ ខ្ញុំចង់សួរសំណួរមួយចំនួនអំពីប-១។ មុននឹងខ្ញុំសួរ ខ្ញុំសូមអនុញ្ញាតដើម្បីចាប់ផ្តើមអំពីមុខងាររបស់លោកនៅក្រសួងការពារ -- អ៎ក្រសួង បរទេស ហៅថា ប-១។ ហើយខ្ញុំឲ្យលោកនិយាយពីបញ្ហាមួយចំនួន ទាក់ទងទៅនឹងអ្វីដែលលោកបានលើកឡើងពីខាងដើម។ ថាលោកជាប្រធានរដ្ឋបាលនៃ

ក្រសួងប-១ ហើយលោកគ្រប់គ្រងការងារខាងរដ្ឋបាលហ្នឹង។ តើអ៊ីចឹងដែរឬទេ?

[១៣:៣៥:០៣]

**លោក វ៉ាចាម គុន៖**

**ឆ៖** បាទ គឺអ៊ីចឹងហើយ។

**ស៖** សូមអរគុណលោកសាក្សី។ នេះមានន័យថា ចៅក្រម ឡាវែន៍ សួរលោកព្រឹកមិញនេះ ជាប្រធានរដ្ឋបាលនៅ ប-១ លោកទទួលបន្ទុកខាងស្មារតី ខាងផ្លូវចិត្ត ខាងនយោបាយ គ្រប់គ្រងមនុស្សនៅទីនោះ នៅ ប-១ តើត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោក។

**ស៖** សូមអរគុណ។ ហើយចំណុចមួយទៀត នៅចំណុចចាប់ផ្ដើមនេះ គឺថាលោកបានពាក់ព័ន្ធផ្ទាល់ក្នុងការជ្រើសរើសមនុស្សមួយចំនួនដែលគេចាត់តាំងឲ្យធ្វើការនៅៗប-១។ តើត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោក បាទ។

[១៣:៣៦:០៨]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំនឹងសួរសំណួរមួយចំនួនទៀតទាក់ទងទៅនឹងអតីតសមាជិកនៅប-១។ ខ្ញុំមិនចាំបាច់យោងទៅរកឯកសារនោះទេ ហើយខ្ញុំព្យាយាមនិយាយឲ្យច្បាស់។ ទីមួយ លោកសាក្សីថា តើមានអ្នកណាម្នាក់នៅប-១ នៅពេលដែលលោកធ្វើការនៅទីនោះ ដែលមានឈ្មោះថា មុត? បាទ ថាតើមានអ្នកណាម្នាក់ដែលឈ្មោះហៅៗកាត់ខ្លីថា មុត ហ្នឹងដែរឬទេ?

**ឆ៖** បាទ មានតើ! ឈ្មោះ មុត មាន។

**ស៖** សូមអរគុណលោកសាក្សី។ ថាតើឈ្មោះនាម និងនាមត្រកូលរបស់គាត់ហ្នឹងឈ្មោះអ្វីក្រៅពីឈ្មោះ មុត ហ្នឹងបាទ?

**ឆ៖** ឈ្មោះគាត់ហ្នឹង នៅកាលហ្នឹងនៅក្រសួងហ្នឹងគេហៅថាឈ្មោះ -- ក្នុងក្រសួងហ្នឹងគេហៅថាបង មុតៗ។ តែឈ្មោះខាង -- ឈ្មោះផ្លូវការ បើតាមផ្លូវការគឺ -- ឯកឧត្តម គាត ឈន់ រាល់ថ្ងៃហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។ តើមុខងារគាត់ធ្វើអ្វីដែលថា លោក គាត ឈន់ នោះ គាត់មានតំណែងជាអ្វីកាលនោះ?

**ឆ៖** គាត់កាលនោះ គឺគាត់ទទួលសរសេរសុន្ទរកថា មួយផ្នែកដែរ។ គាត់ទទួលមួយផ្នែកដែរ។

[១៣:៣៨:៣៥]

**ស៖** សូមអរគុណលោកសាក្សី។ ថាតើគាត់មានការទទួលខុសត្រូវអ្វីផ្សេងទៀតទេនៅក្នុងមន្ទីរ ឬក៏កន្លែងធ្វើការដែលលោកស្គាល់ លោកដឹងនោះ?

**ឆ៖** គាត់ទទួលពេលមានប្រតិភូអញ្ជើញមក គឺគាត់មានភារកិច្ច គឺថាក្នុងការចូលចរចា និង កំណត់ហេតុ គឺនៅលើគាត់ហ្នឹងហើយ។

**ស៖** សូមអរគុណលោកសាក្សី។ សូមលោកឲ្យឧទាហរណ៍អំពីការចរចាដែលគាត់បានចូល រួម។ ឧទាហរណ៍អ្វីដែលលោកដឹង ថាតើគាត់បានចូលរួមក្នុងការជជែកពីរឿងបញ្ហាព្រំដែនជាមួយ វៀតណាមដែរទេ ចរចានោះ?

[១៣:៣៩:៤៥]

**ឆ៖** អង្គាល់នោះ គឺថា មិនពាក់ព័ន្ធនឹងការចរចាព្រំដែនទេ គឺពាក់ព័ន្ធ ឧបមាថា ប្រតិភូមកពី ប្រទេសចិន ប្រតិភូមកពី -- ដូចជា ហៅថាស្ថានទូត ដែលមកៗជាឯកអគ្គរដ្ឋទូតនៅកម្ពុជានេះ គាត់ មានបញ្ចេញមុខ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោក គាត ឈន់ បានពាក់ព័ន្ធក្នុងការពិភាក្សារឿងគោល នយោបាយ អ្វីដែរឬទេតាមដែលលោកដឹងនោះ?

**ឆ៖** កិច្ចការងារទូតផង ដូចថា សុន្ទរកថា ត្រូវថ្លែងទៅនៅអង្គការសហប្រជាជាតិ ហើយ សុន្ទរកថាទៅថ្លែងទៅប្រទេសមិនចូលបក្សសម្ព័ន្ធ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ថាតើលោក គាត ឈន់ បានអមដំណើរសម្តេច សីហនុ ទៅទីក្រុងញូវយ៉ក ដើម្បីទៅជួបអគ្គលេធិការ ដែលអគ្គលេខាសម័យនោះ គឺលោក យឺង វើល ហេម។ តើលោកបានចាំទេកាលនោះបាទ?

**ឆ៖** ខ្ញុំមិនដឹងថាគាត់ទៅជួបអ្នកណាទេ ប៉ុន្តែឈ្មោះហ្នឹង ឈ្មោះអង្គការសហប្រជាជាតិ យឺង វើល ហេម ហ្នឹង ដូចជាមានឮដែរ វិទ្យុផ្សាយដែរ។

**ស៖** សូមអរគុណលោកសាក្សី។ សាក្សីម្នាក់ទៀតក្នុងរឿងក្តីនេះ បាននិយាយជូនតុលាការនេះ ថា ប្រសិនបើ -- បើសិនជាគេចង់ដកលោក គាត ឈន់ ចេញពីក្រសួងការបរទេសកាលនោះ គឺថាអាច ក្រសួងហ្នឹងគាំងដំណើរការ។ ថាតើលោកប្រធានរដ្ឋបាលនៅប-១ តើលោកយល់ដូចម្តេចអំពីការវាយ តម្លៃរបស់សាក្សីម្នាក់នោះនុះ?

[១៣:៤២:២៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! ចាំស្ដាប់អង្គជំនុំជម្រះសម្រេចលើសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំសូមជំទាស់ដែលថា មេធាវីដូចបានបញ្ជាក់អង្គហេតុខុស គឺថាមិនត្រូវប្រធានបទដែលថា គឺយកសាក្សីផ្សេងមកឲ្យសាក្សីរូបនេះបានឆ្លើយ គឺថាមិនបានបញ្ជាក់ពីអត្តសញ្ញាណ គឺអង្គហេតុកំណត់ឲ្យបានត្រឹមត្រូវ។ អ្វីដែលខ្ញុំចង់ចាំគឺថា សុំឲ្យសាក្សីឆ្លើយបែបនេះមិនសមស្របទេបាទ។

**លោក អេនគ្រូ អ៊ីន្ធូហ្ស៊ី៖**

សូមអរគុណ។ ខ្ញុំនឹងសួរឡើងវិញ។ ប្រសិនបើគេដក គាត ឈន់ ចេញពីក្រសួងការបរទេស ថាតើធ្វើឲ្យក្រសួងហ្នឹងគាំង ឬក៏វាអាចនឹងបិទក្រសួងហ្នឹងដែរឬទេ?

[១៣:៤៣:២៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីជាតិ -- សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការ សំណួរនេះ គឺជាសំណួរដែលធ្វើឲ្យសាក្សីធ្វើសេចក្ដីសន្និដ្ឋាន។ សូមជំទាស់ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានមូលដ្ឋានត្រឹមត្រូវ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ!

**លោក អេនគ្រូ អ៊ីន្ធូហ្ស៊ី៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតបទៅនឹងការជំទាស់បាទ។ ខ្ញុំមិនចង់ឆ្លើយទេ--

**ប្រធានអង្គជំនុំ៖**

យើងសម្រេចរួចហើយ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតជម្រាបថា ជាបឋមគឺថា ខ្ញុំមានប្រកាន់ជំហររហូតមកដល់ពេលនេះ គឺថាអ្វីដែលកើតឡើងនៅកម្ពុជាប្រជាធិបតេយ្យ ដែលថា ពីថ្នាក់ក្រោមទៅដល់ថ្នាក់ខ្ពស់ គឺថា វាមានពាក់ព័ន្ធទៅនឹងសំណួរបញ្ហាជាច្រើនដោយសារថា បុគ្គលម្នាក់ៗមានការពាក់ព័ន្ធ។ ដូច្នេះហើយមិន -- ខ្ញុំមិនយល់ថា សហព្រះរាជអាជ្ញា និងមេធាវីបានជំទាស់ហ្នឹង គឺថាសមស្រប ឬមិនស្រប ប៉ុន្តែខ្ញុំយល់ស្រប។ ដូច្នេះ ខ្ញុំសួរទៅសាក្សីតទៅទៀត។

[១៣:៤៤:៥១]

**ប្រធានអង្គជំនុំ៖**

លោកៗចំណាយពេលវេលាដើម្បីតាំងសំណួរទៅ! ព្រោះអង្គជំនុំជម្រះបានផ្តល់ពេលវេលាឲ្យសួរ មិនមែនឲ្យលោកធ្វើអត្ថាធិប្បាយទេ។ សូមលោករៀបចំសំណួរឲ្យពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលមានការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ នេះជាមូលដ្ឋាននៃដំណើរការនីតិវិធីតាមផ្លូវតុលាការ សំណួរឯណាមិនពាក់ព័ន្ធនឹងអង្គហេតុដែលមានការចោទប្រកាន់ទេ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសាក្សីនេះឆ្លើយទេ។ ចំណាយពេលវេលាឥតបានការ។

[១៣:៤៥:៤០]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណដែលលោកប្រធានបានបំភ្លឺ។

**សួរដោយលោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

**ស៖** ខ្ញុំនឹងយោងទៅរកដីកាដំណោះស្រាយ បាន -- គេបានរៀបរាប់ថា គាត់ជាមន្ត្រីជាន់ខ្ពស់នៅក្រសួងការបរទេស ហើយដោយសារលោកជាប្រធានរដ្ឋបាលនៅទីនោះ ថាតើលោកអាចធ្វើការសង្កេត ដូចដែលលោកឆ្លើយទៅចៅក្រម ឡាវែន៍ ព្រឹកមិញ តើលោកយល់ស្របដែរឬទេថា លោក គាត ឈន់ ជាកម្មាភិបាលជាន់ខ្ពស់មួយរូបនៅប-១នោះ?

**លោក រ៉ាចាម តុន៖**

**ឆ៖** គាត់ជាកម្មាភិបាលជាន់ខ្ពស់មួយរូបដែរនៅនុំង ក្នុងហ្នឹងក្នុងក្រសួងហ្នឹង ពិសេសគឺខាងកិច្ចការនយោបាយខាងក្រៅ គាត់មានពិសោធន៍ច្រើនលើការងារទូត ការទំនាក់ទំនងផ្សេងៗគាត់មានពិសោធន៍។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរមួយទៀតចុងក្រោយទាក់ទងនឹងប្រធានបទនេះ។ ដោយសារថា លោកជាប្រធានរដ្ឋបាល ហើយនិងផ្អែកទៅលើបទពិសោធន៍ខាងស្មារតីរបស់លោក ថាតើហេតុអ្វីបានលោក គាត ឈន់ មិនព្រមបង្ហាញខ្លួនចំពោះមុខអង្គជំនុំ -- ចៅក្រមស៊ើបអង្កេត ដើម្បីមកបំភ្លឺ។ ដូច្នេះថាតើគាត់មានការភ័យខ្លាច ឬយ៉ាងម៉េច? តើលោកដឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ! មិនមែនជាមុខងាររបស់សាក្សីទេ មិនមែនភារកិច្ចរបស់សាក្សីឆ្លើយលើ -- តបនឹងសំណួរហ្នឹងទេ។

[១៣:៤៧:២៧]

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំសូមកត់សម្គាល់ថា ការសំណួរទាក់ទងទៅនឹងបុគ្គលម្នាក់គឺថា ជួយឲ្យយើងខ្ញុំ និងអង្គជំនុំជម្រះ ដើម្បីឲ្យប្រាកដថា ហេតុអ្វីបានជាបុគ្គលនោះមិនព្រមមកបង្ហាញខ្លួន និងផ្តល់សក្ខីកម្មនោះ? ខ្ញុំសូមដកស្រង់បុគ្គលម្នាក់ ដែលនិយាយបានច្បាស់ជាងខ្ញុំនៅក្នុងរឿងក្តីនេះ។ "យើងមានទស្សនៈថា មិនមានទស្សនៈថា គឺមិនមានការជំនុំជម្រះអង្គហេតុណាដែលមិនបានពិចារណាគឺថា សមាជិកណាម្នាក់របស់រាជរដ្ឋាភិបាលកម្ពុជានេះ អាចនឹងដឹងដោយខ្លួនឯងថា--

**ប្រធានអង្គជំនុំ៖**

លោកតាំងសំណួរ ឬអស់សំណួរ? បើសិនជាអស់សំណួរហើយ យើងនឹងប្រគល់សំណួរ -- វេទិកាទៅឲ្យមេធាវីផ្សេងទៀត។ ព្រោះសំណួរ អត់មានសំណួរសារធាតុ ដើម្បីស្វែងរកការពិត ពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយទេ។ នីតិវិធីនៃការហៅនរណា មិនហៅនរណា មិនមានភារកិច្ចរបស់សាក្សីទេ។ ហើយបញ្ហានេះ យើងបានធ្វើការបដិសេធ មិនឲ្យសាក្សីឆ្លើយច្រើនអាក់ហើយ។

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើសេចក្តីសន្និដ្ឋានអ្វីទេ។ ប្រសិនបើលោកចង់ធ្វើសេចក្តីសន្និដ្ឋានលោកធ្វើលាយលក្ខណ៍អក្សរ ពីព្រោះនៅក្នុងវិធាន៩២ នៃវិធានផ្ទៃក្នុងចែងច្បាស់ណាស់ អំពីការធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ទៅតាមបរិបទនីមួយៗនៃដំណើរការនីតិវិធីបានគ្រប់ពេលទាំងអស់រហូតដល់ចប់។ ចុងក្រោយ ទើបធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល សរុបចុងក្រោយ។

[១៣:៤៩:៣៥]

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋាននៅពេលក្រោយ ប៉ុន្តែអ្វីដែលខ្ញុំបញ្ជាក់ពេលនេះ គឺដើម្បីកំណត់ត្រាតុលាការ ដោយថា សំណួរជាក់លាក់ដែលខ្ញុំសួរនោះគឺថា គឺដកស្រង់ចេញពីដីកាដំណោះស្រាយទាំងស្រុង ហើយខ្ញុំមិនយល់ថា ហេតុអ្វីបានជាអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យខ្ញុំឆ្លើយតបទៅនឹងការជំទាស់ ឬក៏ដើម្បីកត់ត្រាតុលាការ។ ថាតើនេះជាសេចក្ដីសម្រេច ឬគោលជំហររបស់អង្គជំនុំជម្រះមិនឲ្យខ្ញុំសួរ ហើយមិនឲ្យខ្ញុំបញ្ជាក់ដើម្បីកត់ត្រាតុលាការ មិនឲ្យខ្ញុំឆ្លើយតបទៅនឹងការជំទាស់ ឬយ៉ាងដូចម្ដេច?

[១៣:៥០:១៥]

**ប្រធានអង្គជំនុំ៖**

មិនមានការជំទាស់ទេ។ អំមិញយើងសម្រេច អង្គជំនុំជម្រះសម្រេចរួចហើយ។ មានខាងណាភាគីណាជំទាស់? អំមិញអត់មានភាគីណាជំទាស់ទេ។ អង្គជំនុំជម្រះប្រើឆន្ទានុសិទ្ធិក្នុងការសម្រេចតែម្ដង ដកចេញនូវអ្វីដែលមានការដេញដោលឥតប្រយោជន៍ ឥតនាំស្វែងទៅរកការពិតនៃរឿងក្ដី។

អង្គជំនុំជម្រះបានផ្ដល់វេទិកាឲ្យលោកតាំងសំណួរដេញដោលចំពោះសាក្សី ហើយពាក្យនេះយើងបានប្រើប្រាស់ច្រើនដងណាស់នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការ ពេលដែលចាប់ផ្ដើម ពេលដែលចប់ភាគីនីមួយៗ ភាគីមួយទៀត យើងអនុញ្ញាត យើងផ្ដល់ -- អម្បាញ់មិញនេះ យើងបានផ្ដល់វេទិកាទៅលោកមេធាវីអន្តរជាតិការពារក្ដី នួន ជា ឲ្យតាំងសំណួរដេញដោលចំពោះសាក្សី។

យើងមិនបានផ្ដល់វេទិកាឲ្យលោកធ្វើសេចក្ដីថ្លែងការណ៍នយោបាយ ឬក៏ថ្លែងការណ៍អ្វីផ្សេងនោះទេនៅក្នុងទីនេះ ពេលនេះ។

[១៣:៥១:២៣]

ហើយបើសិនបើលោកចង់ធ្វើសេចក្ដីសន្និដ្ឋាន សូមឲ្យលោកពិនិត្យមើលវិធាន៩២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។ យើងបានអានម្ដងហើយ។ សេចក្ដីសន្និដ្ឋានតាមបរិបទនីមួយៗ ឬសេចក្ដីសន្និដ្ឋានពាក់កណ្ដាលទី សូមឲ្យលោកធ្វើជាលាយលក្ខណ៍អក្សរបញ្ជូនមកក្រឡាបញ្ជីសវនាការ ដើម្បីចាត់ការបញ្ចូលទៅក្នុងសំណុំរឿងតាមនីតិវិធី។

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** ខ្ញុំនឹងចូលទៅដល់ប្រធានបទមួយទៀត។ លោកសាក្សី ពីព្រឹកម្សិលមិញ ប្រហែលជាមុនសម្រាកបាយថ្ងៃត្រង់ ហើយនិងមុនសម្រាកពេលល្ងាចដែរ គឺថាមានសំណួរទាក់ទងទៅនឹង ហោ ណាំហុង ទាក់ទងទៅនឹងបឹងត្របែក។ នៅក្នុងសេចក្តីយោងមួយទៀតនោះ លោក គឺថា “គាត់បានរត់ចេញពីក្រុងភ្នំពេញទៅជនបទ ហើយទៅប្រទេសបារាំង។ ហើយគាត់ត្រឡប់មកវិញ”។ ស្តាប់ឮថាលោកនិយាយថា “គាត់បានមកកាន់តំណែងខ្ពស់ ធំណាស់នៅទីនេះ”។ តើនេះជាសេចក្តីសង្ខេបត្រឹមត្រូវដែលលោកបានជម្រាបតុលាការទេ អំពីសំណួរខ្ញុំអំមិញនេះ?

[១៣:៥២:៥១]

**លោក វ៉ាចាម តុន៖**

**ឆ៖** កាលពីព្រឹកមិញខ្ញុំបានជម្រាបបញ្ហានេះ ដូចអ៊ីចឹងមែន។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរមួយទៀត ថាតើមុខងារ ឬក៏មុខតំណែងអ្វីខ្លះដែលលោក ហោ ណាំហុង ធ្វើការនៅក្រសួងការបរទេសនៅ ប-១ កាលណោះ?

**ឆ៖** កាលគាត់នៅក្នុងក្រសួងហ្នឹង គឺរយៈខ្លីដែរ គិតទៅវាចុង៧៨ទៅហើយ។ ធ្វើបានមួយនេះដែរ គឺថាមួយរយៈខ្លីដែរ កាលហ្នឹងគាត់នៅក្នុង ដូចជាក្រុមបង គាត ឈន់ ហ្នឹង បង ជួន ប្រាសិទ្ធិ ហ្នឹងគាត់នៅក្នុងក្រុមហ្នឹងហើយ។

**ស៖** សូមអរគុណលោកសាក្សី។ តើប-៣២ នោះគឺលោកស្គាល់ទេ? កន្លែងគេធ្វើអ្វី ប-៣២?

**ឆ៖** ប-៣២ ជាកន្លែងសម្រាប់ចលត័ក្នុងក្រុមដឹកនាំហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរមួយទៀត សាក្សីដែលខ្ញុំបានជម្រាបលោកព្រឹកមិញនេះ គឺថាបានមកផ្តល់សក្ខីកម្មពីមុន គឺគាត់ថា “តាមដែលខ្ញុំចាំ គាត់គឺ ហោ ណាំហុង គឺជាអគ្គរដ្ឋទូតប្រទេសគុយបា ហើយគាត់នៅ ប-១ រយៈពេលខ្លី ប៉ុន្តែគាត់នៅរយៈពេលយូរនៅ បឹងត្របែក”។ សាក្សីរូបនោះ បាននិយាយដូច្នេះ។ តើនេះជាចម្លើយត្រឹមត្រូវដែរឬទេ ដែលលោកនៅ ប-១ ដែលថាលោក ហោ ណាំហុង ហ្នឹងបានចំណាយពេលធ្វើការនៅបឹងត្របែកហ្នឹងយូរ?

[១៣:៥៥:៤០]

**ឆ៖** បាទ ពិតអ៊ីចឹងហើយ ព្រោះគាត់នៅហ្នឹងបឹងត្របែកហ្នឹងយូរ។ ដល់ខាង ប-១ ទៅទទួលហ្នឹងមួយរយៈខ្លី ហើយមុននឹងគាត់មកធ្វើការនៅក្រសួងពីមុន ខ្ញុំក៏ក្តាប់មិនបានទេ ប៉ុន្តែដូចខ្ញុំបញ្ជាក់

អំមិញអ៊ីចឹងថា គាត់នៅក្នុងរង្វង់ការងារទូតហ្នឹងហើយ។ ខ្ញុំបញ្ជាក់អ៊ីចឹងបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ថាតើគាត់ជាប្រធាន ឬអនុប្រធាននៅបឹងត្របែកនោះ ទាក់ទងនឹងលោក ហោ ណាំហុង នេះ?

**ឆ៖** ដែលខាងៗក្រសួងទៅទទួលគាត់ហ្នឹង អង្គាល់នុំងក្នុងគាត់ នាមគាត់គ្រប់គ្រងនៅបឹងត្របែកហ្នឹងដែរ។ គាត់គ្រប់គ្រង។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរមួយចុងក្រោយចំណុចនេះ គឺទាក់ទងនឹងកិច្ចការរដ្ឋបាលរបស់លោក ហើយនិងជំនាញខាងស្មារតីរបស់លោក។ លោកដឹងទេ ហេតុអ្វីបានជាលោក ហោ ណាំហុង មិនព្រមបង្ហាញខ្លួនមកសហចៅក្រមស៊ើបអង្កេត ដើម្បីបំភ្លឺសហចៅក្រមស៊ើបអង្កេត តើរដ្ឋាភិបាលមានការព្រួយបារម្ភមិនឲ្យគាត់មកឬ?

[១៣:៥៧:១១]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ! សំណួរនេះមិនមានភារកិច្ចរបស់សាក្សីត្រូវឆ្លើយតបទេ។

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** សូមអរគុណ។ ខ្ញុំសូមដកស្រង់អំពីឯកសារមួយគឺថា “ការស៊ើបអង្កេតបន្ថែមគឺត្រូវបានហាមឃាត់ គឺថាអង្គជំនុំជម្រះមានកាតព្វកិច្ចដើម្បីធានានូវសុចរិតភាព ភាពយុត្តិធម៌នៃអង្គជំនុំជម្រះ។ ការធ្វើសក្ខីកម្មរបស់សាក្សី គឺបង្ហាញពីការពិត ការរារាំងណាមួយអាចនឹងជាការបំពានដំណើរការយុត្តិធម៌”។--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជឿថា លោកមេធាវីការពារដូចជា លើកសេចក្តីសម្រេចចេញមកពីអង្គបុរេជំនុំជម្រះ ប៉ុន្តែមិនគប្បីលើកនៅកន្លែងនេះទេ។ គឺថាមេធាវីដឹងបាន -- ដឹងច្បាស់ហើយថាខ្លួនត្រូវមានសំណួរសមស្របសួរសាក្សី មិនគប្បីសួរឲ្យគាត់សន្និដ្ឋានអំពីមូលហេតុរបស់រដ្ឋាភិបាលដែលនៅក្រៅពីការធ្វើសក្ខីកម្មរបស់គាត់នេះទេ។ ដូច្នេះគឺថា អាចនឹងដែលលោកលើកតែសេចក្តីដក

ស្រង់គឺថា វាធ្វើឲ្យសាក្សីគាត់យល់ឆ្ងាយ អ៊ីចឹងគឺថាយើងត្រូវតែធ្វើការជំទាស់ក្នុងការជំនុំជម្រះ គឺថា នៅពេលដែលមេធាវីសួរសំណួរ គឺថាបើមិនទាក់ទងទៅនឹងអង្គហេតុ គឺថាអង្គជំនុំជម្រះអាចនឹងបញ្ឈប់លោកបាន ដូច្នេះ គឺថាយើងខ្ញុំសូមជំទាស់។

[១៣:៥៨:៥៥]

**លោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

ខ្ញុំសូមជំទាស់នឹងមតិរបស់សហព្រះរាជអាជ្ញា គឺថាយើងមានសិទ្ធិនៅក្នុងការឲ្យកត់ត្រាក្នុងតុលាការ គឺថាឯកសារនេះ គឺថាជាសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ គឺជាអតីតចៅក្រម ខាទីនខា ហើយនិងចៅក្រម រ៉ូវ៉ាន់ដោននីង គឺថា ជាសេចក្ដីដកស្រង់ចេញពីមតិជំទាស់របស់ចៅក្រម។ ហើយការសួរទៅនឹងសំណួរអតីតកាលរបស់បុគ្គលគឺថា ជួយដល់យើង ហើយនិងអង្គជំនុំជម្រះក្នុងការយល់ពីមូលហេតុថា ហេតុអ្វីបានជាអ្នកទាំងនោះមិនព្រមមកបង្ហាញខ្លួន អំពីមូលហេតុដែលរាជរដ្ឋាភិបាលកម្ពុជាបានឲ្យអនុសាសន៍កុំឲ្យពួកគាត់មក។ ហើយគឺថា យើងប្រកាន់ជំហរដូចដែលចៅក្រមអង្គបុរេជំនុំជម្រះបានខ្វែងមតិនោះឯង។

[១៣:៥៩:៤៧]

ឥឡូវនេះ ខ្ញុំចូលទៅដល់ឯកសារមួយទៀត។ ហើយខ្ញុំសូមការបំភ្លឺ ដូចលោក ឌេល លីសាក់ ដែលចង់និយាយ ថាតើលោកចង់និយាយថា ខ្ញុំលើកឡើងដោយដឹង ឬក៏ដោយចេតនា ថាមិនសមស្រប ហើយនៅតែសួរ ឬក៏យ៉ាងម៉េចបាទ?

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់លោកតំណាងសហព្រះរាជអាជ្ញា ត្រឹមត្រូវហើយ។ លោកមេធាវីប្រើឱកាសរបស់លោក ដើម្បីសួរដេញដោលសាក្សី។ ប្រសិនបើលោកមានបំណងធ្វើសន្និដ្ឋានណាមួយ សូមលោកអនុវត្តតាមវិធាន៩២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

[១៤:០០:៤៩]

**លោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

**ស៖** ហើយខ្ញុំចូលទៅរកឯកសារមួយទៀត លោកសាក្សី លោកនៅចាំទេ ផ្ដល់បទសម្ភាសន៍

មួយ ឬក៏មានអ្នកណាមកសម្ភាសលោក ដោយសហចៅក្រមស៊ើបអង្កេត ឬក៏ដោយអង្គការមួយ មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ កន្លងមក? តើលោកបានឆ្លើយទៅអ្នកណាម្នាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

**លោក វ៉ាចាម គុន៖**

**ឆ៖** មជ្ឈមណ្ឌលឯកសារ ខ្ញុំដូចអត់បានជួបទេ -- អ៎! អត់បានឆ្លើយទេ។

**ស៖** សូមអរគុណលោក។ លោក ឈ្មោះ ភី ភួន តើអ៊ីចឹងឬទេ?

**ឆ៖** បាទ។

**ស៖** សូមទោស ហើយលោកក៏គេហៅឈ្មោះ វ៉ាចាម គុន នោះដែរ តើអ៊ីចឹងដែរឬទេ? ហើយតុលាការក៏ហៅឈ្មោះលោកអ៊ីចឹង តើមានឈ្មោះអ៊ីចឹងទេ?

**ឆ៖** បាទ មានឈ្មោះអ៊ីចឹងមែន។

**ស៖** ថាតើលោកមានឈ្មោះ ជាម ដែរឬទេ? បាទ ជាម ហ្នឹង គឺថាបើអង់គ្លេសខ្ញុំប្រកបបែបនេះ តើមានឈ្មោះ ជាម ដែរឬទេ?

**ឆ៖** បាទ ខ្ញុំមានឈ្មោះអ៊ីចឹងដែរ។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារជូនសាក្សី ដើម្បីរំឭកការចងចាំ ដើម្បីឲ្យគាត់ដឹងថា តើគាត់បានផ្ដល់ចម្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរអត់? ហើយឯកសារនេះ គឺ E190.1.406 ហើយនេះ គឺជាឯកសារនៅក្នុង អ៊ីនធីហ្វេស យូរហើយ នៅក្នុងបីភាសាជាឯកសារដែលសហព្រះរាជអាជ្ញាបានស្នើឡើង។ ហើយនេះជាមូលហេតុដែលខ្ញុំសូមអនុញ្ញាតបង្ហាញទៅលោកសាក្សីផងដែរ និងបង្ហាញលើអេក្រង់ផងដែរ។ លោកប្រធាន បាទ។

[១៤:០៣:២៧]

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាត្រឹមត្រូវទេ ឯកសារនេះ មាននៅក្នុងបញ្ជីឯកសារតំណាងសហ-ព្រះរាជអាជ្ញាដែលស្នើឡើង?

**លោក ខេល លីសាក់៖**

បាទ ខ្ញុំ -- គឺជាឯកសារ -- យើងដាក់ជាឯកសារថ្មី ពីព្រោះការសម្ភាសហ្នឹង គឺធ្វើឡើងមុន

បញ្ចប់ការស៊ើបអង្កេត។ គឺថាយើងបានដាក់តាមសេចក្តីសម្រេចរបស់តុលាការ គឺE190 គឺថាកថាខណ្ឌ ៣៨, ៣៩។ គឺថាគប្បីតែដាក់ឯកសារនេះ ចូលក្នុងសំណុំរឿង។ យើងខ្ញុំមិនមានការជំទាស់ចំពោះការប្រើឯកសារនេះជូនសាក្សី ឬក៏បង្ហាញលើអេក្រង់ហ្នឹង ដាក់ជូនតុលាការដើម្បីដេញដោលទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គជំនុំជម្រះអនុញ្ញាត!

[១៤:០៤:២៦]

**លោក អេនឌ្រូ អ៊ីន្ទូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំនឹងសូមចូលដល់ខ្លឹមសារ ខ្ញុំសូមអាន ERN នៅលើឯកសារនេះ។ អង់គ្លេស ERN 00660621 រហូតដល់ 00660651 ខាងចុងបាទ។ ខ្មែរ ERN 006668 (ស៊ីក) រហូតទៅដល់ 006874, បារាំង ERN 00754243 រហូតដល់ 00754297។ ខ្ញុំគិតថាយើងបានជូនឯកសារលើក្រដាសទៅលោកសាក្សី ហើយខ្ញុំមានសំណួរបួនទាក់ទងទៅនឹងឯកសារនេះ។ ខ្ញុំសូមអនុញ្ញាតលោកសាក្សី តើលោកបានឃើញឯកសារនៅក្នុងដៃហើយឬនៅ? លោកមើលក្រប! តើលោកបានឃើញឈ្មោះលោកនៅលើទីនេះទេ? នៅ -- បាទ លោកបើកទៅខាងទំព័រមុខគេក្របបាទ។ ខ្ញុំសូមអនុញ្ញាតអានទៅលោកវិញជាភាសាអង់គ្លេស គឺសម្ភាសជាមួយ វ៉ាចាម តុន ហៅ ភីន ភួន ហៅ ជាម ភេទប្រុស អាយុ៦៣ឆ្នាំ។ សម្ភាសនៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ នៅឆ្នាំ២០១០ ខែតុលា។ សម្ភាសដោយ ឡុង ដានី បកប្រែទៅជាភាសាអង់គ្លេសដោយ ទិន សុខ បាទ។ នៅក្រោមទំព័រនោះ គឺមានលេខយោងគឺថាមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអង្គការមួយដែលខ្ញុំបានប្រាប់ពីខាងដើមនោះ។ តើអានប៉ុណ្ណេះ តើលោកនឹកឃើញឡើងវិញហើយនៅ អំពីបទសម្ភាសន៍ដែលលោកបានផ្តល់ទៅឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចដែលខ្ញុំបានជម្រាបពីខាងដើមនេះបាទ?

[១៤:០៦:៥៦]

**លោក វ៉ាចាម តុន៖**

**ឆ៖** ឯកសារៗហ្នឹង ដូចខ្ញុំអត់បានជួបគេទេ។ ខាងមជ្ឈមណ្ឌលឯកសារដូចអត់បានជួបខ្ញុំទេ។

**ស៖** បាទ លោកសាក្សី អ៊ីចឹងយើងមួយជំហានម្តង។ យើងត្រឡប់ទៅទំព័រ -- បាទ យើងខ្ញុំនឹងរកទំព័រនោះ ទៅទំព័រ១៤ជាភាសាអង់គ្លេស។ ERN អង់គ្លេស 00660634, ខ្មែរ ERN 00660845 សូមអភ័យទោសចៅក្រម ឡាវែន៍ ខ្ញុំអត់មានទេ សូមអភ័យទោស ស៊ីម៉ុនណូហ្វត ផងដែរ ហើយនិង

មេធាវីការពារក្តីនេះផងដែរ។ ទំព័រ១៤ ភាសាអង់គ្លេសនៅខាងក្រោម។

**លោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

សូមអនុញ្ញាតតុលាការដើម្បីបង្ហាញចំណុចនេះនៅលើអេក្រង់ផងដែរបាទ។

**សួរដោយលោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

**ស៖** លោកសាក្សី ហើយលោកបានការ -- ធ្វើការពិភាក្សាជាមួយអ្នកសម្ភាស គឺថាជាមួយការងារមួយអំពីការចាត់តាំង។ ចំណុចមួយដែលលោកនិយាយថា សួរថា៖ "តើហេតុអ្វីបានជាគេចាត់តាំងហ្នឹង?" ហើយចម្លើយរបស់លោក៖ "បាទ ខ្ញុំដឹង គឺថាយល់កម្មាភិបាល ដើម្បីគ្រប់គ្រង ដើម្បីឲ្យមានការកាប់សម្លាប់កាន់តែខ្លាំងឡើង គឺថាពួកគេភាគច្រើនគេមោទនភាពណាស់។ តាម៉ុក គឺជាកម្មាភិបាលអាក្រក់ ខ្ញុំមិនចូលចិត្ត។ នៅឆ្នាំ១៩៧៩ គឺថាមានការ -- ជាកម្មាភិបាលឃោរឃៅ តាម៉ុក ហ្នឹងគឺថាមានទំនោរ -- ទំនាស់ជាមួយនឹងនិរតីខ្លាំង"។ តើលោកនៅនឹកឃើញទេ ថាលោកបានឆ្លើយពាក្យបែបនេះទៅឲ្យមន្ត្រីម្នាក់ដែលមកពីមជ្ឈមណ្ឌលឯកសារហ្នឹងសម្ភាសនោះ?

[១៤:០៩:៣៣]

**ឆ៖** ខ្ញុំ -- អ្នកដែលមកជួបខ្ញុំៗ សុទ្ធតែកត់ត្រាទុក។ ខ្ញុំ -- ឯកសារដែលប៉ុន្មានថ្ងៃនេះ ខ្ញុំទទួលស្គាល់ថាខ្ញុំបានជួបគេ។ ឯកសារនេះគឺ ចម្លែកដែរ ខ្ញុំអត់ដែលៗបានជួបឈ្មោះហ្នឹងទេ ឈ្មោះ ដានី ហ្នឹងដូចអត់ទេ។ អត់ដែលបានជួបទេ។

**ស៖** សូម -- តើលោកធ្លាប់បាននិយាយថា តាម៉ុក ជាមនុស្សអាក្រក់ដែរទេ? តើលោកនឹកឃើញថា លោកធ្លាប់និយាយជាមួយអ្នកណាម្នាក់ ទាក់ទងទៅនឹងគំនិតនេះដែរឬទេ?

**ឆ៖** ខ្ញុំនិយាយហ្នឹងដូចជា នែ៎ ពេលដែល តាម៉ុក ដែលស្លាប់ ស្លាប់ហ្នឹង។ ពេលដែលគេហែសពពីភ្នំពេញទៅអន្លង់វែងហ្នឹង ប៉ុន្តែមិនដឹងពីណា ពីណាសួរហ្នឹង ខ្ញុំមិនដឹងថាឯកសារស្វែងរកការពិតទេ។ ប៉ុន្តែខ្ញុំៗមាននិយាយ។ ខ្ញុំនិយាយ គឺថានែ៎ តាម៉ុក នេះគឺក្នុងឆ្នាំ៧៧ ហើយនិង៧៨ គឺនិយាយៗពីពេលនុ៎ងគឺថា កន្លងមកនេះគឺថា អាហ្នឹងគឺភស្តុតាងដែលភូមិភាគរងគ្រោះនេះ គេនិយាយច្រើន។ គេថាក្នុងឆ្នាំហ្នឹង តាម៉ុកហ្នឹង គឺថាកម្មាភិបាលមកពីនិរតីនេះ គឺសម្លាប់គេគ្រប់ភូមិភាគ។ ភូមិភាគបូព៌ា ភូមិភាគពា្លសាន ភូមិភាគ៣០៤ ភូមិភាគឧត្តរ ភូមិភាគពាយ័ព្យ ភូមិភាគបស្ចិម គឺថាកម្មាភិបាលមកពីតាម៉ុកទាំងអស់មកសម្លាប់គេ។ អាហ្នឹងគេនិយាយ គេឃើញជាក់ស្តែង គេថាចាប់ពីហ្នឹងគឺយាប់មែនទែនតែម្តង។

[១៤:១២:២០]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកប្រកាន់យកសាក្សី ដែលថាលោកយល់ថា តាម៉ុក គឺជាមនុស្សអាក្រក់ ហើយលោកបានស្អប់គាត់ តើលោកប្រកាន់ចម្លើយនេះថានៅត្រូវដូចរបស់លោកដដែលទេ?

**ឆ៖** ខ្ញុំនៅជាមួយ តាម៉ុក គឺជាមនុស្សទំនាស់គ្នា។ ទំនាស់វាមិនមានស្អីទេ គាត់មើលងាយខ្ញុំជាជនជាតិ ខ្ញុំក៏មើលងាយ តាម៉ុក ឯងជាខ្មែរមួយរូបដែលចេះដឹងដែរ អាម៉េចក៏ចាប់កម្មាភិបាល ដើរសម្លាប់គេក៏ច្រើនម្ល៉េះ។ គឺទំនាស់គ្នាខ្លាំងណាស់កាលនៅនែ៎ នៅអន្លង់វែង កាលឆ្នាំ៨១, ៨២ ហ្នឹង កាលនោះ។ វិះនឹងបះបោរដែរពេលនុ៎ង គឺទំនាស់គ្នាខ្លាំងអ៊ីចឹង។ ហើយកាលនុ៎ងគាត់ថា “យី ជាម ឯងហ៊ានមាត់ខ្ញុំ?” ខ្ញុំថា “ចុះខ្លាចអី តាម៉ុក ឯងមនុស្សដូចតែគ្នាហ្នឹង” ហ្នឹង។ បើថា បើមាគ៌ាខ្ញុំគោរព ខ្ញុំថា ពេលហ្នឹង ខ្ញុំថា “មាគ៌ាខ្ញុំគោរព”។ ប៉ុន្តែធាតុបុគ្គល និយាយមកគ្មានគប្បីទេ គ្មានអ្នកណាគេគោរពទេ ធាតុបុគ្គលនោះ បើមាគ៌ាបានគេគោរព។

[១៤:១៣:៤១]

រឿងហ្នឹងហើយ ដែលៗវាហ្នឹង ហើយវាសមស្របនឹងដែលខ្ញុំជួបមនុស្សជាច្រើនឮគេថាហ្នឹង។ សូម្បីខាងស្រុកខ្ញុំក៏អ៊ីចឹងដែរ គេថាកម្មាភិបាលមកពីនិរតី គឺសាហាវណាស់ សម្លាប់គេសាហាវតែម្តង។ គេថាអ៊ីចឹង ប្រមាណបីបួនភូមិភាគហ្នឹង។ ហើយខ្ញុំបានសន្និដ្ឋាន ខ្ញុំថាក្នុងកម្ពុជាប្រជាធិបតេយ្យនេះ អាក្រក់ជាងនេះគឺ តាម៉ុក ហ្នឹងឯង។ តាម៉ុក ហ្នឹងហើយដែលកម្ចោចមាគ៌ា ប៉ុល ពត។ ខ្ញុំបាននិយាយមែន ខ្ញុំបាននិយាយ។ មានពីណាចង់ដឹង តាម៉ុក ខ្ញុំអត្ថាធិប្បាយរៀបហ្នឹងខ្ញុំអត់ខ្លាចអីបន្តិចបន្តួចទេ ព្រោះការពិតអ៊ីចឹងមែន។ ព្រោះនែ៎ ៧៩ មកខ្ញុំចេញពីភ្នំពេញនេះ ខ្ញុំទៅត្រពាំងជោរ ទៅឱរ៉ាល់ ទៅនែ៎ នេះលាជនេះ ហូរហែអ៊ីចឹងហ្នឹង ឃើញបណ្តោយផ្លូវហ្នឹង អ៊ូ យ៉ាប់ណាស់ក្រោមការគ្រប់គ្រងរបស់ តាម៉ុក មួយជួរហ្នឹង អាក្រក់ណាស់។ អ្នកដែលមកពីបូព៌ា គាត់កម្ទេចចោលតែទាំងអស់ហ្នឹង។ ឃើញអ៊ីចឹងមែន បើឃើញអ៊ីចឹង បើខ្លួនឯងក៏ឃើញដែរ។ ហើយកាលនុ៎ង ពួកខ្ញុំមកពីភ្នំពេញ វិះនឹងគេកម្ទេចទៀតក្រុមតាម៉ុកហ្នឹង វិះនឹងកម្ទេចដែរ។ ប៉ុន្តែខ្ញុំមានកម្លាំងទៅ ក៏មិនហ៊ានធ្វើអីខ្ញុំ។ នៅភូមិតាម៉ុកៗ នោះទៅដល់នុ៎ងលេងចាប់ពួកមកទៅពីភ្នំពេញនេះ ច្រើនតែជេរថាពួកអាដេកពួក ពួកអាផ្អែម ពួកអាឆ្អុក។ សុទ្ធតែអ៊ីចឹងជេរ។ កម្មា--

[១៤:១៥:២៤]

**ប្រធានអង្គជំនុំ៖**

បាទ បានហើយសាក្សី ចាំស្តាប់សំណួរ ហើយឆ្លើយតបនឹងសំណួរ។ ហើយធ្វើអារម្មណ៍ឲ្យបានត្រជាក់នឹងនរជាងនេះណា ដើម្បីឆ្លើយតបនឹងសំណួរ។ សូមអញ្ជើញតាំងសំណួរបន្តទៀត!

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោកសាក្សី។

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** សំណួរមួយចុងក្រោយអំពី តាម៉ុក ប្រហែលជាធ្វើឲ្យលោកលំបាកបន្តិច។ ថាតើលោកធ្លាប់ហៅថា តាម៉ុក គឺជាស្តេចត្រាញ់នៅក្នុងភូមិភាគរបស់គាត់ដែរឬទេ បាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់ របស់តំណាងសហព្រះរាជអាជ្ញាទៅនឹងសំណួរនេះជាមុនសិន។ សូមអញ្ជើញ!

[១៤:១៦:២១]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំជំទាស់ទៅនឹងសំណួរនេះ គឺថាមេធាវីគប្បីតែបញ្ជាក់ថាតើពាក្យថា *វ័រឡត* ជាភាសាអង់គ្លេសហ្នឹង ស្តេចត្រាញ់ ឬក៏ឈ្នួនសង្គ្រាមនេះគឺថាមានន័យថាម៉េច? ពីព្រោះថា កុំឲ្យលោកសាក្សី គាត់យល់ច្រឡំពាក្យថា ស្តេចត្រាញ់ ឬក៏អ្នកឈ្នួនសង្គ្រាមនេះមានន័យដូចម្តេច?

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សមស្របហើយ ខ្ញុំនឹងប្តូរទៅឯកសារមួយទៀត។ ឥឡូវនេះ ខ្ញុំនឹងត្រឡប់មកនៅពេលក្រោយ។ ឥឡូវនេះខ្ញុំបង្ហាញឯកសារមួយទៀត E3/24។ ពីមុនហ្នឹងហៅ D91/10។ នេះជាចម្លើយរបស់សាក្សីពីមុនដែលឆ្លើយទៅសហចៅក្រមស៊ើបអង្កេត។ តុលាការ នេះបានឃើញហើយ គឺថាដាក់ដេញដោលប៉ុន្មានថ្ងៃនេះ គឺថាខ្ញុំមិនចាំបាច់បញ្ជាក់លម្អិតទៀតទេ។

សូមអរគុណ។ ចៅក្រម ខាតវ៉ាយថ៍ បញ្ជាក់ថាអាចធ្វើទៅបាន។ ដូច្នេះ ខ្ញុំ -- E3/24 គឺថាកំណត់ហេតុស្តាប់ចម្លើយលោក ភី ភួន ជាសាក្សី។ អង់គ្លេស ERN 002223578 (ស៊ីក) រហូតដល់ 00223588, បារាំង ERN 00509397 រហូតដល់ 0050329 (ស៊ីក), ខ្មែរ ERN 0020466 (ស៊ីក)

រហូតដល់ 00204075។ សូមអភ័យទោសបាទ។ ឥឡូវនេះត្រឡប់ទៅចំណុចមួយលើឯកសារនៅលើ អេក្រង់ បាទ លោកបានឃើញពីខាងដើមហើយលោកសាក្សី ដោយសង្ខេប គឺថាទំព័រទី៩ លើភាសាខ្មែរ។ អង់គ្លេស ERN 00223586, ខ្មែរ ERN 00204075។ គឺសូមអភ័យទោសលោក លោកស្រីចៅក្រម និងភាគីក្នុងដែលអានភាសាបារាំង ខ្ញុំអត់មាន ERN បារាំងទេ។

[១៤:១៨:៤៣]

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** នៅក្នុងចំណុចកណ្ដាលនៃទំព័រនេះ លោកនិយាយអំពីភូមិភាគ គឺថាភាគមួយ បានន័យថាភូមិភាគមួយ មានមេមួយដូចជាស្ដេចត្រាញ់អ៊ីចឹង។ ថាតើពាក្យថា “ស្ដេចត្រាញ់” នេះលោកចង់សំដៅអត្ថន័យដូចម្ដេច?

**លោក វ៉ាចាម តុន៖**

**ឆ៖** ស្ដេចត្រាញ់នេះគឺចង់សំដៅ -- ដូចៗតា ម៉ុក ហ្នឹង។ យកកម្មាភិបាលពីនិរតីទៅគ្រប់គ្រងគេគ្រប់ភូមិភាគ ហើយរៃគេចោលអ៊ីចឹង។ ហ្នឹងឯងចង់ថាស្ដេចត្រាញ់ហ្នឹង។ គឺកម្មាភិបាលគេនៅកន្លែងមួយគំនរ។

**ស៖** សូមអរគុណលោកសាក្សី។ សូមអរគុណ ដែលលោកបានឆ្លើយ។ ខ្ញុំត្រឡប់មកចំណុចមួយទៀតអំពីបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារ គឺខ្ញុំមានសំណួរបីទៀតទេ សួរទៅលោកសាក្សី។

[១៤:១៩:៥៣]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអនុញ្ញាតដើម្បីបង្ហាញលើអេក្រង់ ហើយលោកសាក្សីពិនិត្យមើលកំណត់ហេតុមជ្ឈមណ្ឌលឯកសារហ្នឹងឡើងវិញ។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** តើលោកមាននៅក្នុងដៃហើយឬនៅបាទ? លោកសាក្សី តើលោកបានកំណត់ហេតុសួរ -- សម្ភាសសាក្សី -- សម្ភាសលោករបស់ ឌី.ស៊ី.ខេម របស់មជ្ឈមណ្ឌលឯកសារ? បាទអ៊ីចឹង សូមអភ័យមានការបកប្រែយឺតបន្តិចបាទ។

លោកសាក្សី ឥឡូវនេះយើងមើលចំណុចមួយ ទំព័រ២១ អង់គ្លេស ERN 00660844 ខ្មែរ 0066070 (ស៊ីក) នៅលើ -- លោកបាននិយាយថា នយោបាយឈ្មោះ-ឈ្មោះ របស់នាយករដ្ឋមន្ត្រី ហើយ

វាមានប្រសិទ្ធភាពណាស់។ តើលោកយល់ដូចម្តេច អំពីនយោបាយឈ្នះ-ឈ្នះ នេះ?

[១៤:២១:១២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបទៅនឹងសំណួរ! ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន ទៅនឹងសំណួរដែលតាំងសួរដោយមេធាវី។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន។ ខ្ញុំជំទាស់ថា សំណួរនេះ គឺថាក្រៅពីវិសាលភាព នៃដីកាដំណោះស្រាយ គឺថាបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារនោះគឺថា មុនឆ្នាំ១៩៧៩ ទាក់ទងទៅនឹងសំណួរដែលមេធាវីបានសួរនេះ គឺថា សូមជំទាស់ដោយសារសំណួរនេះ មិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវជំនុំជម្រះនៅពេលនេះទេបាទ។

[១៤:២១:៥៦]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមឆ្លើយទៅវិញដោយសង្ខេប នេះគឺចំណុចមួយទាក់ទងទៅនឹងបរិបទ ដែលមានថាមិនពាក់ព័ន្ធនោះ។ ខ្ញុំសួរសំណួរឡើងវិញ ដើម្បីឲ្យច្បាស់។

**សួរដោយលោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

**ស៖** លោកសាក្សីតាមដែលលោកដឹងគឺថា នយោបាយឈ្នះ-ឈ្នះ ដែលមានចំណុចសំខាន់ៗគឺថាការប្តេជ្ញា ដើម្បីកប់ចោលនូវអតីតកាល ទោះបីតែ ឌុច ហើយនិងអ្នកជំនុំជម្រះថ្ងៃនេះ គឺថាត្រូវបំភ្លេចចោល តើលោកនៅចាំគំនិតនេះទេ ដែលជាគំនិតរបស់រាជរដ្ឋាភិបាលកម្ពុជា បញ្ជាក់នៅកាលនោះនុះ?

**លោក វ៉ាចាម គុន៖**

**ឆ៖** ចំពោះចលនាផ្តាច់ខ្លួន គឺថា បានទទួល -- គេហៅថា នយោបាយឈ្នះ-ឈ្នះនេះគឺទទួលបានទាំងអស់គ្នា ពីព្រោះគ្មានអ្នកចាញ់ គ្មានអ្នកឈ្នះ គឺ ឈ្នះ-ឈ្នះ ទាំងអស់គ្នា។ ក្នុងឈ្នះទាំងអស់គ្នាហើយដែលវាមានសន្តិភាពរហូតដល់សព្វថ្ងៃនេះ។ ហ្នឹងហើយដែលពេញចិត្ត ពេញថ្លើម គឺត្រង់ៗពាក្យពេចន៍នេះវាសមស្របនឹងសភាពការណ៍ជាក់ស្តែងនៅពេលនោះ ហើយវាសម្រាប់ទៅអនាគតដែរ។

[១៤:២៣:៣១]

**ស៖** សូមអរគុណចំពោះចម្លើយ។ នេះមានន័យថា លោកយល់ស្របទៅអ្វីដែលខ្ញុំបានអានជូនលោក ហើយចំណុចសំខាន់នៃនយោបាយនេះគឺថា ដើម្បីកប់ចោលនូវតែអតីតកាលទាំងអស់របស់ខ្មែរក្រហមទាំងអស់ វាប់ទាំងមេដឹកនាំដែលរងការជំនុំជម្រះរាល់ថ្ងៃនេះផង។ តើលោកយល់ស្របអ៊ីចឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

សូមអភ័យទោស ដែលខ្ញុំនិយាយកាត់ឡើងវិញ។ សាក្សីគាត់បានឲ្យថាយល់ មិនយល់ ហើយបើសួរថាតើលោកសាក្សី យល់ស្រប ឬមិនយល់ស្របទៅនឹងនយោបាយនេះ គឺមិនពាក់ព័ន្ធទៅនឹងផ្នែកនៃសវនាការក្នុងនីតិវិធីនេះទេ។

**លោក អេនគ្រូ អ៊ីុន្ទហ្វ៊ី៖**

ខ្ញុំនឹងឆ្លើយតបដោយសង្ខេប បាទ ជំហររបស់ខ្ញុំ ដើម្បីឲ្យលោកនិយាយគឺថា គាត់បានចូលរួមនៅក្នុងការបណ្តុះបណ្តាលអំពីផ្លូវសតិអារម្មណ៍នយោបាយនោះ គឺថាគាត់អាចនឹងឆ្លើយបាន។ ហើយគាត់បានឆ្លើយកន្លងមកហើយ ហើយគាត់ស្ថិតនៅក្នុងឋានៈមួយដែលថា គាត់អាចសមស្របក្នុងការឆ្លើយ។ អ៊ីចឹងគឺថា យើងប្រកាន់ជំហរថា មូលហេតុរបស់នយោបាយហ្នឹងគឺថា ដើម្បីកំណត់នូវសក្តីកម្មហ្នឹង ក៏អាចនឹងធ្វើឲ្យការជំនុំជម្រះមានកម្រិតនោះដែរ។ អ៊ីចឹងហើយ ខ្ញុំនឹងពិនិត្យមើលកំណត់ហេតុស្តាប់សម្ភាសមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សីរូបនេះតទៅទៀតបាទ។

ដូច្នេះ យើងទៅទំព័រ២៦--

[១៤:២៥:១៤]

**ប្រធានអង្គជំនុំ៖**

ដោយសារសេចក្តីជំទាស់មានប្រសិទ្ធភាព សំណួរដែលសួរហ្នឹង គឺក្រៅអង្គហេតុ អត់មានពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់ទេ។ សាក្សីមិនបាច់ឆ្លើយតបទេ!

**លោក អេនគ្រូ អ៊ីនួហ្សី៖**

សូមអភ័យទោស ខ្ញុំយល់ឃើញដូច្នោះ។ បាទ សូមអភ័យទោស។

**សួរដោយលោក អេនគ្រូ អ៊ីនួហ្សី៖**

**ស៖** ហើយខ្ញុំចូលទៅរកចំណុចមួយទៀត គឺសំណួរបន្ទាប់ទំព័រ២៦ ដូចដែលខ្ញុំនិយាយ គឺថា ERN អង់គ្លេស 00666646, ខ្មែរ ERN 0066085។ លោកសាក្សីនេះជាឯកសារដដែល គឺបទសម្ភាសន៍ដែលលោកបានឆ្លើយដដែល ទំព័រនេះ លោកបាននិយាយ ក-៥ អំពីការរៀបចំ ក-៥ នៅតាមបណ្តោយ ព្រំដែនថៃ-ខ្មែរ ដែលថាមានមីន និងចម្រូងច្រើន។ ហើយចង់សួរលោកថា តើកំណែន ក-៥ ហ្នឹង តើជាកំណែនអ្វី ដែលដើម្បីឲ្យអង្គជំនុំជម្រះ និងភាគីទាំងអស់បានយល់ផងបាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយរបស់មេធាវីការពារក្តីទេ! សំណួរនេះមិនពាក់ព័ន្ធទាល់តែសោះទៅនឹងអង្គហេតុដែលចោទប្រកាន់។

[១៤:២៦:៤៤]

**លោក អេនគ្រូ អ៊ីនួហ្សី៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំយោងទៅរកឯកសារ E131/1/9 នោះ គឺថាម៉ោងមួយដែលថាយើងទទួលអំពីការជំទាស់របស់សំណួរមេធាវីការពារក្តី នួន ជា ដើម្បីយើងដាក់ឯកសារជូនឯកសារឆ្នាំ២០១១ គឺថា កថាខណ្ឌ៣ គឺថា ទាក់ទងទៅនឹងដីកាដំណោះស្រាយកែតម្រូវ ទាក់ទងទៅនឹងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនោះ។ ប្រព័ន្ធឧក្រិដ្ឋដែលអនុវត្តនៅក្នុងកម្ពុជាប្រជាធិបតេយ្យនាំឲ្យមានមនុស្សស្លាប់រាប់លាន។ ហើយយើងមានការពិភាក្សាទូលំទូលាយ គឺថាយ៉ាងហោចណាស់ គឺថាមាន ៥០ពាន់នាក់ ដែលថាអាចនឹងត្រូវស្លាប់នៅក្នុងផែនការ ក-៥ ដែលថា គឺថាបន្ទាប់ពីកម្ពុជាប្រជាធិប-តេយ្យមក។ ប៉ុន្តែការវាយតម្លៃអំពីរបបនោះ ដែលនាំឲ្យមានមនុស្សស្លាប់សរុបនោះ មិនទាន់បានវាយតម្លៃ។ មេធាវីការពារ គឺថាមិនមានការសួរចម្លើយតាមកោសល្យវិច័យទាក់ទងទៅនឹងពិនិត្យទៅលើគ្រោះថ្នាក់ដែលបង្កឡើងដោយ ក-៥នេះទេ។ ប៉ុន្តែមានឯកសារមួយចំនួនចង្អុលបង្ហាញថា លោក ហ៊ុន សែន ជាអ្នកអាចទទួលខុសត្រូវចំពោះការអនុវត្តផែនការ ក-៥ ដែលនាំឲ្យមានមនុស្សស្លាប់។ ហើយយ៉ាងហោចណាស់--

**ប្រធានអង្គជំនុំ៖**

បញ្ហាក្រៅអង្គហេតុ ហើយកាន់តែវែងឡើង។ បញ្ហាយើងប្រាប់ហើយ បញ្ហាហ្នឹងគឺក្រៅអង្គហេតុទេ។ អ្វីដែលលោកច្រៀងហ្នឹង លោកនិយាយហ្នឹង គឺលោកនិយាយនៅក្នុងសេចក្ដីសន្និដ្ឋានលាយលក្ខណ៍អក្សរដែលលោកមានបំណងធ្វើដូច្នេះ។ លោក -- យើងមិនបណ្ដោយឲ្យលោកធ្វើដូច្នេះទេ។

[១៤:២៨:៣៤]

**លោក អេនគ្រូ អ៊ីនូហ្វី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់លើកចំណុចមួយ គឺទាក់ទងទៅនឹងបញ្ហាពាក់ព័ន្ធ ទាក់ទងទៅនឹង គឺថាមានមនុស្សស្លាប់ ចំនួនមនុស្សស្លាប់ទាក់ទងក្នុងរឿងក្ដីរបស់យើងខ្ញុំនេះដែរ។ សូមអភ័យទោសគឺថា--

**ប្រធានអង្គជំនុំ៖**

អត់ឲ្យលោកនិយាយទេ បញ្ហាហ្នឹង។ បើលោកមានសំណួរសួរ អញ្ជើញសួរទៀតចុះ។ បើអស់ហើយ យើងឲ្យវេទិកាទៅអ្នកផ្សេងទៀត។

**លោក អេនគ្រូ អ៊ីនូហ្វី៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំជ្រាបច្បាស់ហើយ ខ្ញុំទាក់ទងនឹងការប្រើពេលនេះ ខ្ញុំថាខ្ញុំបានសន្យាជាមួយពួកគាត់ គឺថានឹងសល់ពេលខ្លះសម្រាប់គាត់។

[១៤:២៩:១៧]

**សួរដោយលោក អេនគ្រូ អ៊ីនូហ្វី៖**

**ស៖** សំណួរចុងក្រោយមួយទាក់ទងទៅនឹងឯកសារនេះ គឺបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ នេះជាសំណួរចុងក្រោយ។ សូមលោកមើលទំព័រទី២ ហើយអង់គ្លេស ERN 006606 (ស៊ីក) រហូតដល់ 22, ខ្មែរ ERN 006660821 (ស៊ីក)។ លោកសាក្សី ខ្ញុំចង់ដកស្រង់អ្វីដែលលោកបានឆ្លើយថា “តើលោកធ្វើការ -- តើលោកធ្វើការឲ្យបក្សដែរឬទេ? បាទ”។ “តើធ្វើការឲ្យបក្សប្រជាជនកម្ពុជាដែរឬទេ? បាទ ខ្ញុំជាសមាជិកអចិន្ត្រៃយ៍របស់គណបក្សស្រុក”។ តើនេះជាចម្លើយត្រឹមត្រូវរបស់លោកតាមការពិតដែរឬទេ? តើលោកលោកជាសមាជិកគណៈអចិន្ត្រៃយ៍របស់បក្សប្រជាជនកម្ពុជាដែរឬទេ?

**ឆ៖** បាទ ចំណុចនេះ ខ្ញុំឯកភាព។ ខ្ញុំបានបញ្ជាក់ជូនអ៊ីចឹងហើយ រាល់ថ្ងៃនេះអ៊ីចឹង។

**ស៖** សូមអរគុណលោកសាក្សី។ ហើយចំណុចចុងក្រោយបំផុតគឺទាក់ទងទៅនឹងចំណុចមួយ គឺថា ការសម្ភាសនោះ គឺថា លោកមិនមែនជាសមាជិក ប៉ុន្តែលោកគ្រាន់តែជាគាំទ្រទេ អ្នកពេញចិត្តទេ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ! សំណួរហ្នឹងមិនពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់លើជនជាប់ចោទទេ។

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

លោកសាក្សី សូមអរគុណដែលលោកបានឆ្លើយ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ លោក លោកស្រីចៅក្រម។ ខ្ញុំផ្តល់វេទិកាទៅឲ្យមេធាវីក្រុមការពារផ្សេងដើម្បីសួរបន្ត។ សូមអរគុណបាទ។

[១៤:៣១:២២]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ម៉ោង -- ដល់ពេលវេលាសមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សី នៅកន្លែងរង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់ និងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបានកំណត់អម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣១ នាទី ដល់ម៉ោង ១៤:៥១ នាទី)*

[១៤:៥១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី វ៉ាចាម តុន។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រី ទាំងអស់គ្នា ទាំងនៅក្នុង និងខាងក្រៅបន្ទប់សវនាការ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ជម្រាបសួរលោកសាក្សី។ បើលើកលែងតែមានការជំទាស់ អ៊ីចឹង ខ្ញុំសូមហៅឈ្មោះថាជាម១ តែម្តង បើមិនជាខុសទេ។ លោកសាក្សី ទីមួយ ខ្ញុំចង់ឱ្យលោកបញ្ជាក់បញ្ហាមួយចំនួន។ ទីមួយ លោកបានផ្តល់ចម្លើយពីរដង ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ ទីមួយ គឺថ្ងៃទី៥ ខែធ្នូ ២០០៥ និងលើកទីពីរ នៅថ្ងៃទី២៦ ខែកញ្ញា ២០០៨ តើត្រឹមត្រូវដែរទេ?

[១៤:៥៣:០២]

**លោក វ៉ាចាម តុន៖**

**ឆ៖** ២០០៥ ហ្នឹង ខ្ញុំអត់ច្បាស់ទេ បើថា២០០៧ ហ្នឹង ខ្ញុំច្បាស់ជាង។

**ស៖** ប្រហែលជាមានបកប្រែខុស។ ទីមួយ គឺលើកទីមួយ នៅ ២០០៧ លើកទីពីរ នៅ ២០០៨?

**ឆ៖** ២០០៧, ២០០៨ ហ្នឹង ខ្ញុំនៅចាំ។

**ស៖** ហើយនៅចុងបញ្ចប់នៃចម្លើយរបស់លោកនេះ គឺលោកបានផ្តល់នូវសេចក្តីសង្ខេប សន្និដ្ឋានសង្ខេបមួយ។ ត្រូវបានគេអានឱ្យស្តាប់ ហើយលោកបានផ្តិតមេដៃនៅលើឯកសារនេះ។ តើនេះត្រឹមត្រូវទេ?

**ឆ៖** អ្វីដែលបាន ខ្ញុំបានផ្តិតលើក្រដាសហ្នឹង អាហ្នឹង ការពិត។

**ស៖** ហើយជាការពិតណាស់ នៅមុនពេលឆ្លើយសំណួរ គឺគេចោទ -- គេបានឱ្យលោកធ្វើសម្បថ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ហើយពីមុននោះ គឺថាគេបានបង្ហាញចម្លើយទីបី ទៅលោក ចុះកាលបរិច្ឆេទថ្ងៃទី១៩ ខែធ្នូ ២០១០ នោះ គឺដែលជាកិច្ចសម្ភាសន៍ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E190.1.406 គឺខ្ញុំ

ចង់ងាកទៅឯកសារនេះ។ តើលោកនៅចាំបានថា ដែលលោកបានផ្ដល់បទសម្ភាសន៍នេះមែនទេ?

**ឆ៖** ត្រង់ចំណុចថា មជ្ឈមណ្ឌលឯកសារស្វែងរកការពិត អាហ្នឹងត្រង់ហ្នឹងខ្ញុំ វាអត់ៗមិនមានបញ្ហេញរបៀបអីចឹងទេ អង្កាល់ណោះ។ បើប្ដឹង -- បើថាខ្ញុំដឹងរបៀបហ្នឹង ខ្ញុំអត់ជួបទេ។ បែបគេធ្វើវិធីណាខ្ញុំក៏មិនដឹងដែរ ដល់គេធ្វើ -- ព្រោះអង្កាល់ហ្នឹងវាអត់មានឮពាក្យហ្នឹង ពាក្យដែលស្វែងរកការពិតមកៗសម្ភាសខ្ញុំៗវាអត់មាន។

**ស៖** ប្រហែលជាខ្ញុំសូមជូនឯកសារនេះមួយច្បាប់ទៅឲ្យលោក ឬក៏លោកមាននៅពីខាងមុខលោកហើយ? ពីព្រោះទីមួយ ខ្ញុំចង់បញ្ជាក់ចំណុចមួយចំនួន លោកសាក្សី តើលោកចង់និយាយថា កិច្ចសម្ភាសន៍បែបនេះគឺថា លោកមិនដែលធ្លាប់បានធ្វើជាមួយខាងៗមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងមែនទេ?

[១៤:៥៦:៣៣]

**ឆ៖** បាទ ខ្ញុំអត់បានធ្វើទេ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ លោកបានជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងថា ឡុង ដានី មិនដែលបានសម្ភាសលោកនៅខែធ្នូ ឆ្នាំ២០១០ នោះទេ។ គឺការសម្ភាសដែលសម្ភាសលោកនៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ នេះគឺជាកិច្ចសម្ភាសន៍របស់លោកដែលធ្វើឡើងដោយមានសម្បថ។

**អ្នកបកប្រែ៖**

អ្នកបកប្រែសូមកែតម្រូវ “តើលោកធ្វើសម្ភាសនេះ តើលោកមានធ្វើសម្បថដែរឬទេ?”

**លោក វ៉ាចាម តុន៖**

**ឆ៖** សម្ភាសពីរដង ខ្ញុំធ្វើពាក្យសម្បថពីរដង។ ហើយក្រៅហ្នឹង ដូចអត់ទេ។

**ស៖** នេះជាសំណួររបស់ខ្ញុំ។ តើលោកមានបានផ្ដល់កិច្ចសម្ភាសន៍ជាមួយ ឡុង ដានី ដែលមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ? បើលោកថាអត់ លោកឆ្លើយថាអត់ លោកឆ្លើយថាបានធ្វើឆ្លើយថាបានធ្វើ បើលោកមិនចាំ លោកឆ្លើយថាមិនចាំទេ។

[១៤:៥៨:១០]

**ឆ៖** ទេ អំមិញ ខ្ញុំបានបញ្ជាក់ម្ដងហើយថា ចំពោះស្វែងរកការពិតនេះ ខ្ញុំដូចជាអត់បានសម្ភាសជាមួយទេ ឬមួយខ្ញុំភ្លេចម៉េច ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំគឺមិនចាំទេចំណុចនេះ។

**ស៖** ខ្ញុំសូមឲ្យលោកពិនិត្យមើលនៅទំព័រមួយ ERN ជាភាសាខ្មែរ 00660835, ERN អង់គ្លេស

00660629, ERN បារាំង 00754259។ សូមលោកមើលទៅលើទំព័រដែលបង្ហាញនៅចំពោះមុខលោក។

នៅពេលដែលលោកកំពុងតែរកមើលនេះ គឺខ្ញុំសូមតាំងសំណួរទៅលោក។ នៅពេលដែលសួរថា តើអ្នកណាតែងតាំងលោក ឬអ្នកណាចាត់តាំងលោក បញ្ជាឲ្យលោកទៅធ្វើការនៅក្រសួងការបរទេស? នេះគឺជាសំណួរដែល ដានី នេះបានសួរទៅលោក។ តើ អៀង សារី សុំឲ្យមកជាមួយគាត់វិញ ឬក៏លោកចង់ទៅយ៉ាងម៉េច? លោក ជាម ឆ្លើយថា “អត់ទេ។ យើងអត់មានសិទ្ធិអីទៅសុំទេ អ៊ំ ប៉ុល ពត គាត់ចាត់តាំងឲ្យទៅនៅជាមួយ អៀង សារី។ ខ្ញុំក៏មកនៅជាមួយគាត់ធ្វើការងារជុំវិញការទទួលភ្ញៀវណា។ ការងារហ្នឹងវាធូន់ធ្ងរដែរ រៀបចំផ្ទះសម្បែង រៀបចំទទួលភ្ញៀវ។” លោក សាក្សី លោកឃើញត្រង់ឃ្លានេះទេ?

[១៥:០០:៤២]

**ឆ៖** ខ្ញុំឃើញក្នុងនេះគឺថា ខ្ញុំដូចជាអត់ -- ដូចខ្ញុំៗទៅ ថាដូចខ្ញុំឈ្មោះ ដានី ហ្នឹងខ្ញុំមិនដែលបានជួបសោះ ស្រាប់តែវាចេញមកអ៊ីចឹង។

**សៈ** ខ្ញុំសូមតាំងសំណួរងាយៗទេទៅលោក ដើម្បីឲ្យលោកក៏ឆ្លើយមកក៏ស្រួលដែរ។ ឧបមាថាឯកសារនេះមិនមានយថាភាព ដែល ឌី.ស៊ី.ខេម មជ្ឈមណ្ឌលឯកសារកម្ពុជា គាត់មិនបានក្លែងឯកសារអីយ៉ាងដូច្នេះទេ។ យើងឧបមាថា ដូច្នេះ។ នៅទំព័រដែលខ្ញុំបង្ហាញជូនលោកនេះ “លោកថាអ៊ំ ប៉ុល ពត គាត់ចាត់តាំងឲ្យខ្ញុំទៅនៅជាមួយ អៀង សារី នៅក្រសួងការបរទេស”។ លោកឃើញឃ្លានេះទេលោក?

**ឆ៖** ឃើញហើយឃ្លាហ្នឹង។

**សៈ** តើលោកដែលមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនោះ លោកធ្វើសម្បថដែរឬទេ? លោកឆ្លើយជាមួយអ្នកសម្ភាសនៅមកពីមជ្ឈមណ្ឌលថា “ប៉ុល ពត ចាត់តាំងឲ្យលោកនៅជាមួយ អៀង សារី នៅក្រសួងការបរទេស”។

[១៥:០២:៤៦]

**ឆ៖** ខ្ញុំវាឆ្ងល់ត្រង់ថា ស្វែងរកការពិតហ្នឹង វាៗអត់ដែលបានជួបគ្នាសោះ ស្រាប់វាចេញមកអ៊ីចឹង។ បើថៅក្រមស៊ើបអង្កេត អាហ្នឹងខ្ញុំទទួលស្គាល់។

**សៈ** ដូច្នេះដើម្បីឲ្យបានច្បាស់ គឺអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ បានយល់ច្បាស់ហើយនៅពេលដែលសហព្រះរាជអាជ្ញា សួរលោកនៅព្រឹត្តិការណ៍៣០ឆ្នាំជាងហើយ គឺលោកអាចឆ្លើយបានដោយមានភាពជាក់លាក់ ដូចជាកិច្ចប្រជុំនៅទីណា អ្នកណាចូលរួមនៅក្នុងអង្គប្រជុំ ប៉ុន្តែការសម្ភាសនេះ

ដែលទើបតែមិនដល់ពីរឆ្នាំផង។ តើនេះគឺអ្វីដែលលោកចង់ឲ្យអង្គជំនុំជម្រះនាពេលនេះ ចង់ជឿលោកឬយ៉ាងម៉េច បើមិនដល់ពីរឆ្នាំផង លោកភ្លេច?

[១៤:០៤:០៧]

**ឆ៖** ខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀត ចំពោះ ដានី នេះសម្ភាសជាមួយខ្ញុំនេះ ខ្ញុំវាអត់បាន១ដឹងរបៀបអីចឹង។ ថាវាចេញមកអីចឹង បានវាក៏ឆ្ងល់ណាស់ដែរ។ ខ្ញុំបើស្អីរឿងពិត ខ្ញុំនិយាយតាមខ្ញុំពិត បើថារឿងដែលខ្ញុំមិនបាននៅក្នុងអារម្មណ៍ខ្ញុំថាវាមិនបានទទួល ខ្ញុំប្រាប់វាថាអត់បានទទួលទេ។ ហើយស្វែងរកការពិតវាមិនដែលបានជួបគ្នាសោះតែម្តង។ វាចេញឯកសារអីចឹង។ ថាចំពោះឯកសារនេះ បើថា វាជាសម្ភាសរបស់ខ្ញុំ ក៏ទៅតាមហ្នឹងទៅ បើថាតុលាការថាមានឯកសារហ្នឹងអីចឹង។

**ស៖** ការដែលយើងយកឯកសារនេះមកសាកសួរលោក ដោយសារថាតុលាការបានទទួលយកឯកសារនេះ ដោយមានឃ្លាមួយលោកនិយាយថា "អ៊ំ ប៉ុល ពត គាត់ចាត់តាំងឲ្យខ្ញុំទៅនៅជាមួយនឹង អៀង សារី នៅក្រសួងការបរទេស"។ សំណួរខ្ញុំសួរថា តើលោកបាននិយាយដូច្នេះមែនទេ? តើ ប៉ុល ពត ពិតជាបានចាត់តាំងឲ្យលោកទៅនៅជាមួយ អៀង សារី នៅការបរទេសអីចឹងមែនទេ?

**ឆ៖** បើថា នែ៎ខាងតុលាការមានឯកសារអីចឹង ខ្ញុំក៏ឆ្លើយអីចឹងទៅ។

[១៥:០៦:០៩]

**ប្រធានអង្គជំនុំ៖**

សាក្សីដើម្បីឲ្យយល់ច្បាស់ ទំនងអាចមានការភ័ន្តច្រឡំ ពីព្រោះខាងមេធាវីក៏មិនបានសួរបញ្ជាក់ឲ្យបានច្បាស់លាស់ដែរ។ ឯកសារនេះគឺបានប្រើសរសេរនៅខាងក្រោម គេដាក់ថា ចម្លងចេញពី *អូឌីយ៉ូ* ដោយ ឡុង ដានី។ ទំនងបទសម្ភាសន៍នេះ មិនមែនសម្ភាសរួចសរសេរជាកំណត់ហេតុលាយលក្ខណ៍អក្សរ ហើយឲ្យលោកផ្តិតមេដៃនៅលើឯកសារគ្រប់ទំព័រ ដូចដែលលោកបានធ្វើនៅចំពោះមុខអ្នកស៊ើបអង្កេតនៃសហ -- ការិយាល័យសហចៅក្រមស៊ើបអង្កេតពីរដង ដែលលោកបានឆ្លើយមុននេះទេ។ ថាលោកបានធ្វើនៅឆ្នាំ២០០៧, ២០០៨។ បញ្ហាឯកសារនេះ ទំនងជាសម្ភាស ហើយគេថតសំឡេងលោក។ សំណួរសួរថា តើកន្លងមកនៅក្នុងអំឡុងពេលខែ១០ ប្រហែលជាខែ១០ ឆ្នាំ២០១០ នោះតើលោកមានបានធ្វើការសន្ទនា ជួបសន្ទនាជាមួយអ្នកណាទេ? ដែលមានការពាក់ព័ន្ធដើមដំបូងអម្បាញ់មិញនេះគឺលោកបាននិយាយដល់ថា មរណភាពរបស់លោក តាម៉ុក ដែលនាំឲ្យមានការសន្ទនា ដែលលោកបានគិតថា មានការសន្ទនាជាមួយនឹងបុគ្គលណាមួយ។

[១៥:០៧:២៩]

អ៊ីចឹងឯកសារនេះ របៀបធ្វើខុសពីឯកសារដែលរៀបចំលើកមុន នេះជាបញ្ហាមួយដើម្បីឲ្យលោករំឭកការចងចាំ ថាលោកៗមានការសន្ទនាជាមួយបុគ្គលណាទេ អំពីបញ្ហាពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យនេះ? នេះជាបញ្ហាមួយ បញ្ហាទីពីរ សំណួរដែលលោកមេធាវីសួរគឺក្នុងន័យថា ប្រសិនបើលោកមិនចាំបាច់ចាំនៅក្នុងខ្លឹមសារនៃឯកសារដែលបានដាក់ចំពោះមុខលោកនេះក៏ដោយ ប្រសិនបើលោកគិតថា វាមានហេតុការណ៍អីកើតឡើងដែលលោកចងចាំ អាចតបទៅនឹងសំណួរដែលសួរ គឺលោកអាចឆ្លើយតបទៅនឹងសំណួរដែលសួរនោះបាន ពីព្រោះគ្រាន់ ឯកសារនេះគ្រាន់តែជាមូលដ្ឋាន ដាក់ឲ្យភាគីសួរដេញដោលលោក ពីព្រោះអង្គជំនុំជម្រះបានសម្រេចទទួលរួចហើយ ដោយសារឯកសារនេះនៅក្នុងសំណុំរឿង ហើយភាគីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ លោកយល់ទេ លោក វ៉ាចាម គុន?

[១៥:០៨:៣២]

**លោក វ៉ាចាម គុន៖**

បាទ ខ្ញុំយល់ការអត្ថាធិប្បាយរបស់លោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធានប្រហែលជាមានការប៉ះពាល់ -- ខុសគ្នារវាងកាលបរិច្ឆេទ។ នៅក្នុងអត្ថបទជាភាសាខ្មែរ គឺការខុសគ្នាពីអង់គ្លេស។ អង់គ្លេសដាក់ថា ខែធ្នូ។ ដូច្នេះប្រហែលជាអង្គជំនុំជម្រះគួរតែជួយបញ្ជាក់។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំទើបតែកត់ត្រាដែរ គឺនិយាយថ្ងៃ១៩ ខែតុលា។ ការសម្ភាសហ្នឹងគឺ ថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០១០។

[១៥:០៩:៤៦]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** បើមើលទៅលើកាលបរិច្ឆេទជាភាសាខ្មែរ នេះតើអាចជួយរំឭកទៅដល់ការចងចាំរបស់លោកទេ លោកសាក្សី?

**លោក វ៉ាចាម តុន៖**

**ឆ៖** អាចរំឭកការចងចាំបានដែរ។

**ស៖** ដើម្បីបញ្ជាក់ឲ្យថា យើងប្រាកដថាមានមនុស្សឈ្មោះ ជាម ត្រឹមត្រូវមែន។ តើលោកពិតជាមកពីភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យមែនទេ?

**ឆ៖** បាទ ដូចបានបញ្ជាក់អ៊ីចឹង។

**ស៖** ហើយបើយើងមើលទៅលើទំព័រទី១ ជាភាសាខ្មែរ 00660820 គឺទំព័រទី១ នៃកិច្ចសម្ភាសន៍នេះ។ ហើយជាភាសាបារាំង 0075012 (ស៊ីក) ដែលនិយាយថា លោកបានទទួលស្គាល់ថាលោកជាអភិបាលរងស្រុកពីឆ្នាំ១៩៨៧ រហូតដល់ឆ្នាំ២០០៥។ តើនេះត្រឹមត្រូវទេ? តើលោកពិតជាមានមុខងារជាអភិបាលរងពីចន្លោះឆ្នាំហ្នឹង ទៅដល់ឆ្នាំនុ៎ងមែនទេ?

**ឆ៖** ពិតហើយ ព្រោះចាំ។

[១៥:១១:២៧]

**ស៖** តើនេះជាអង្គហេតុមួយដែលលោកបានឆ្លើយថា ប៉ុល ពត បានចាត់តាំងឲ្យលោកទៅបំពេញការងារនៅក្រសួងការបរទេស?

**ឆ៖** បាទ លើកនេះ ខ្ញុំឯកភាពហើយតាម។

**ស៖** តើនេះមានន័យថាលោកយល់ស្របថា ប៉ុល ពត បានចាត់តាំងឲ្យលោកទៅធ្វើការនៅក្រសួងការបរទេស តើលោកយល់ស្របថា អ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំយល់ស្របអ៊ីចឹងហើយ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះលោកបានស្គាល់ -- តើលោកស្គាល់ សួរ ហុង ដែរឬក៏អត់។

**ឆ៖** ស្គាល់លោក សួរ ហុង ហ្នឹងបាទ។

**ស៖** តាមដែលខ្ញុំដឹងគឺ -- តើលោកបានតាមដាននីតិវិធីនៅពេលដែលតុលាការសាកសួរចម្លើយគាត់ដែរឬទេ?

**ឆ៖** អត់បានតាមដានអីផង។

[១៥:១៣:០២]

**ស៖** អ៊ីចឹងនៅពេលដែលសហព្រះរាជអាជ្ញា គាត់ធ្វើការ ផ្ដើមការសាកសួរនោះ តើលោកមាន

វត្តមាននៅក្នុងសាលសវនាការសាធារណៈនៅខាងក្រោយខ្នងលោកនេះទេ? អង្កាល់ហ្នឹងគឺថ្ងៃទី២១ ខែវិច្ឆិកា ២០១១ តើលោកមានវត្តមាននៅក្នុងបន្ទប់សវនាការនេះទេ?

**ឆ៖** ពីឆ្នាំ២០១១ ខែ១១ហ្នឹង ខ្ញុំនៅខាងក្រៅនោះទេ។ ហើយស្តាប់សវនាការ នៅបន្ទប់ខាងក្រៅហ្នឹង អត់បានចូលខាងក្នុងនេះទេ។ ខ្ញុំស្តាប់ពេលនុ៎ង ខ្ញុំស្តាប់បានតែមួយថ្ងៃទេ ខ្ញុំត្រឡប់ទៅវិញ។

**ស៖** តើលោកមានឱកាសណាមួយដែលលោកបាននិយាយជាមួយ សួរ ហុង ដែលនិយាយពាក់ព័ន្ធគ្នាទៅនឹងចម្លើយរបស់គាត់ សក្ខីកម្មរបស់គាត់នោះដែរឬទេ?

**ឆ៖** មាន។

**ស៖** នៅពេលដែលលោកឆ្លើយថា "មាន" មានន័យថា លោកពិតជាបាននិយាយជាមួយលោក សួរ ហុង អំពីសក្ខីកម្មរបស់គាត់ ដែលគាត់បានផ្តល់ជូនទៅតុលាការ -- នេះគឺគាត់ក៏បានផ្តល់ចម្លើយផ្សេងៗមកដល់លោកដែរ អ៊ីចឹងមែនទេ?

[១៥:១៤:៥៥]

**ឆ៖** គាត់បានផ្តល់នែ៎--

**ស៖** តើលោកបានបញ្ចប់ចម្លើយរបស់លោកហើយឬនៅ?

**ឆ៖** ខ្ញុំបានបញ្ចប់ហើយ។

**ស៖** សូមអរគុណច្រើនលោក។ តើនៅពេលដែលខ្ញុំនិយាយថា សួរ ហុង បានមកផ្តល់សក្ខីកម្មជូនតុលាការ គាត់បានបញ្ជាក់ថា នៅពេលដែលលោកធ្វើការនៅក្រសួងការបរទេស ពេលពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខ គឺលោកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ង់?

**ឆ៖** ទេ ចំណុចនេះគឺថា ជាក់ស្តែង គឺថាខ្ញុំនៅក្នុងក្រសួងការបរទេសហ្នឹង ក្រោមអ៊ំ អៀង សារី ហើយក្រោមបង សួរ ហុង ទេ។ អត់មានក្រោម ប៉ង់ ទេ មកនៅហ្នឹងហើយហ្នឹង។ អត់មានទេនៅក្រោម ប៉ង់ ទេ។ នៅក្រោម ប៉ង់នោះ។

[១៥:១៦:៣៨]

**ស៖** ខ្ញុំសូមអានទៅចម្លើយដែលគាត់បានផ្តល់ជូនតុលាការ។ យើងអាចរកបាននៅលើឯកសារ ERN ជាភាសាខ្មែរ 0080450(ស៊ីក), អង់គ្លេស 00806504, ERN ជាភាសាបារាំង 00806388 ដល់ 89។ នេះ គឺជាចម្លើយដែលគាត់បានផ្តល់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២។ នៅត្រង់បន្ទាត់១៨។ សំណួរ គឺសួរនៅខាងលើហើយ តែខ្ញុំសូមយកចម្លើយតែម្តង។ នៅពេលនេះសំណួររបស់ខ្ញុំថា "នៅពេល

ដែលសមមិត្ត ជាម ធ្វើការនៅក្រសួងការបរទេស ដែលគាត់ជាកូនចៅរបស់លោកផ្ទាល់នោះ តើពេលដែល ជាម ក្លាយជាកូនចៅរបស់លោកៗ -- នៅតែជារបស់មេ ជាម។ ជាម នៅតែ -- ប៉ង់ ដដែលក្នុងពេលនោះ ជាមួយគ្នា ឬក៏យ៉ាងណា?” នេះគឺជាចម្លើយរបស់ សួរ ហុង ដែលគាត់បានឆ្លើយដោយបានធ្វើសម្បថរួចហើយ។ តើនៅពេលនុំងគាត់ឆ្លើយច្រឡំ ឬក៏គាត់កុហកភូតភរ?

[១៥:១៨:១៧]

**ឆ៖** គាត់ឆ្លើយច្រឡំទេដឹង។ ដូចខ្ញុំបានបញ្ជាក់អំមិញ ខ្ញុំនៅក្រោមការដឹកនាំរបស់គាត់ទេ។

**ស៖** ទោះជាយ៉ាងណាក៏ដោយ -- ទោះជាលោកស្ថិតនៅក្រោមការ -- តើលោកនៅក្រោមការគ្រប់គ្រងរបស់ សួរ ហុង ឬក៏មិនមែនទេ? អ្នកណាជាមេផ្ទាល់របស់លោក?

**ឆ៖** មេផ្ទាល់របស់ខ្ញុំហ្នឹងមានតែ សួរ ហុង ហ្នឹងហើយដែលផ្ទាល់។

**ស៖** ប្រហែលជាយើងចូលដល់ចំណុចនេះ ឲ្យវាកាន់តែលម្អិតនៅថ្ងៃស្អែក។ ប៉ុន្តែសម្រាប់ពេលនេះ ខ្ញុំសូមសួរសំណួរមួយផ្សេង គឺនៅក្នុងចម្លើយដែលលោកបានផ្តល់ជូនពីមុនមកនោះ មិនមែនតែម្តងទេ ដែលលោកបានឆ្លើយថា លោកធ្វើការនៅក្នុងផ្នែកសន្តិសុខនៅក្នុងក្រសួងការបរទេស លោកទទួលបន្ទុកខាងផ្នែកសន្តិសុខ។ តើនេះជាចម្លើយត្រឹមត្រូវដែរឬទេ?

[១៥:១៩:៤៦]

**ឆ៖** អត់ទេ ចម្លើយហ្នឹងខ្ញុំអត់បានធ្វើការខាងសន្តិសុខទេ អត់ទេ។

**ស៖** បើសិនជា សួរ ហុង និយាយថា តាមការពិតលោកធ្វើការនៅសន្តិសុខហើយមែននោះហើយលោកថាលោកធ្វើការនៅក្រសួងការបរទេស? តើចម្លើយទាំងពីរនេះ ជាការយល់ច្រឡំ ឬឆ្លើយខុស ឬក៏លោកក៏កំពុងតែផ្តល់ចម្លើយកុហកជូនតុលាការដែរ? ទាំងពីរហ្នឹង មួយណា? លោក សួរ ហុង ផ្តល់ចម្លើយមិនត្រឹមត្រូវកុហក ឬក៏លោកផ្តល់ចម្លើយមិនត្រឹមត្រូវ កុហក?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបទៅនឹងសំណួរ សួរឡើងដោយមេធាវីនេះ។ នេះរង់ចាំ អង្គជំនុំជម្រះសម្រេចលើបណ្តឹង -- លើសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុន។ អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ជាការត្រឹមត្រូវហើយ ខ្ញុំសូមជំទាស់ចំពោះទម្រង់នៃការសួរសំណួរបែបនេះ ដែលសួរឲ្យសាក្សី

ស្នាន។ ថាតើសាក្សីផ្សេងនោះ ឆ្លើយមកដោយច្រឡំ ឬក៏ឆ្លើយមកដោយបន្លំ ដោយក្លែងក្លាយនោះ? គួរសួរតែសំណួរទៅផ្សេងវិញ មិនគួរសួរសំណួរបែបនេះ ឲ្យគាត់ផ្តល់ជាគំនិតយោបល់ ថាតើសាក្សីផ្សេងទៀតនោះ បានប្រាប់ការពិតដល់តុលាការដែរឬអត់នោះ។ សូមជំទាស់។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបទៅវិញសង្ខេបទេ។ សាក្សីទាំងអស់នេះ គឺទោះបីកុហក ឬក៏ឆ្លើយដោយច្រឡំ វារឿងមួយផ្សេង។ ប៉ុន្តែចំពោះសាក្សីរូបនេះ គឺគាត់កំពុងតែកុហកថា គាត់មិនធ្វើការនៅផ្នែកសន្តិសុខនោះទេ។ នេះ វាជាបញ្ហាពីរ។ អ៊ីចឹងហើយ បានជាខ្ញុំជជីកសួរគាត់ ព្រោះគាត់ផ្តល់សក្ខីកម្មពេលនេះ គឺបានស្បថរួចហើយ។

[១៥:២១:៥១]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងមូលហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាធ្វើឡើងមានមូលដ្ឋានត្រឹមត្រូវ។ ដូច្នេះ សេចក្តីជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរដោយមេធាវីការពារក្តីលោក នួន ជា ចុងក្រោយអម្បាញ់មិញនេះទេ អ៎! លោក អៀង សារី ចុងក្រោយអម្បាញ់មិញនេះទេ។ ទីពីរ សូមលោកមេធាវីមានការប្រុងប្រយ័ត្នទៅលើការប្រើពាក្យពេលដែលសួរសាក្សី មិនគប្បីប្រើពាក្យបំភិតបំភ័យសាក្សី ដោយធ្វើសេចក្តីសន្និដ្ឋានអត្តនោម័តិ ថាសាក្សីកុហកនោះឡើយ។ សូមរៀបចំសំណួរឲ្យបានស្រួលបួល ចៀសវាងមានការប៉ះពាល់ទៅលើកិត្តិយសរបស់សាក្សី។

[១៥:២៣:០០]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះខ្ញុំសូមបញ្ជាក់ឲ្យច្បាស់។ លោកបានស្បថហើយ ដែលថាលោកមិនដែលមានពេលណាមួយធ្វើការនៅក្រសួងការបរទេសនោះ អឺ...ពាក់ព័ន្ធទៅនឹងផ្នែកសន្តិសុខនោះទេ។ លោកបានឆ្លើយថាអ៊ីចឹង។ ថាលោកមិនធ្វើការផ្នែកសន្តិសុខទេ ហើយលោកបានស្បថមុននឹងផ្តល់សក្ខីកម្ម?

**លោក វ៉ាចាម តុន៖**

**ឆ៖** ផ្នែកសន្តិសុខបានជម្រាបហើយថា ខ្ញុំអត់បានធ្វើទេ ការងារសន្តិសុខហ្នឹង។ គឺការងារខ្ញុំ គឺជាការងារខាងរដ្ឋបាល។ អារឿងអ្នកដទៃគេឆ្លើយដាក់ខ្ញុំ ខ្ញុំមិនដឹងទេ ខ្ញុំទៅតាមការស្មោះត្រង់របស់ខ្ញុំអ៊ីចឹង។

**ស៖** ខ្ញុំសូមសួរបែបនេះ នៅពេលដែលលោកធ្វើការនៅក្រសួងការបរទេស លោកធ្វើខាងផ្នែករដ្ឋបាល។ តើលោកអាចជម្រាបតាមត្រង់បានទេ ថាតើលោកមានធ្វើការងារផ្នែកសន្តិសុខដែរឬទេ នៅឯក្រសួងការបរទេសនោះ? អ្នកណាជាអ្នកកាន់ខាងផ្នែកសន្តិសុខនៅក្រសួងការបរទេស?

[១៥:២៤:៤៥]

**ឆ៖** ខ្ញុំបញ្ជាក់ហើយថា ការងារសន្តិសុខហ្នឹង គឺមានតែ អ៊ំ អៀង សារី ទេ គាត់អ្នកក្តាប់រួមទេ បានគាត់ដឹងការងារសន្តិសុខហ្នឹង។ ខ្ញុំអត់បាន -- អត់មានអ្នកណាប្រគល់ភារកិច្ចឲ្យខ្ញុំធ្វើការងារសន្តិសុខផង វាអត់មាន។ ហើយខ្ញុំអត់មានភារកិច្ចគេធ្វើ ប្រគល់ឲ្យធ្វើ ខ្ញុំក៏អត់បានធ្វើទេ ព្រោះខ្ញុំដឹងថាគេប្រគល់ការងាររដ្ឋបាល ខ្ញុំដឹងតែការងាររដ្ឋបាលទេអ៊ីចឹង។

**ស៖** ដូច្នេះ សួរ ហុង មិនដែលគ្រប់គ្រង ឬផ្តល់ការងារឲ្យលោកធ្វើការខាងផ្នែកសន្តិសុខមែនទេ ឬយ៉ាងណា?

**ឆ៖** ដូចគាត់អត់មានផ្តល់បញ្ហាការងារសន្តិសុខអីទេ ថាអត់ៗទេ។

**ស៖** មានន័យថា សួរ ហុង មិនដែលបាន -- មិនដែលចាត់តាំងការងារផ្នែកខាងសន្តិសុខនេះឲ្យលោកធ្វើទេ។ ខ្ញុំចង់សង្កត់ធ្ងន់ឡើងវិញ ដើម្បីឲ្យខ្ញុំយល់ច្បាប់អំពីចម្លើយនិងជំហររបស់លោក តើអ៊ីចឹងមែនទេ?

[១៥:២៦:១៧]

**ឆ៖** បាទ ដូចខ្ញុំបានបញ្ជាក់អំមិញអ៊ីចឹងបាទ។

**ស៖** យើងនឹងត្រឡប់មកចំណុចនេះវិញនៅពេលថ្ងៃក្រោយមកទៀត។ ឥឡូវលោកបានទទួលស្គាល់ថា លោកត្រូវបាន ប៉ុល ពត ចាត់តាំងឲ្យទៅធ្វើការនៅក្រសួងការបរទេស។ តាមចម្លើយលើកទីមួយរបស់លោក ក៏លោកមានទំនាក់ទំនងពិសេសជាមួយ ប៉ុល ពត នៅពេលដែលលោកមកធ្វើការនៅក្រសួងការបរទេស តើលោកអ៊ីចឹងមែនទេ មានទំនាក់ទំនងពិសេសជាមួយ ប៉ុល ពត អ៊ីចឹងទេ?

**ឆ៖** ចំណុចនេះ ដូចខ្ញុំបានបញ្ជាក់ហើយថា បើៗគាត់ហៅខ្ញុំទៅជួបគាត់ ខ្ញុំទៅៗ អ៊ីចឹង។ ជាមូលដ្ឋានគឺថាជាមួយអ៊ំ អៀង សារី ជាមួយបង សួរ ហុង ទេ ជាមួយជាអចិន្ត្រៃយ៍ គឺគាត់ម្តងម្កាលទេ។

**ស៖** យើងមើលចំណុចដែលលោកបាននិយាយហើយនិងពិភាក្សាគ្នា ខ្ញុំយោងទៅរកចម្លើយទីមួយគឺនៅក្នុង E3/24 ខ្មែរ ERN 00204070 រហូតដល់ 71, អង់គ្លេស ERN 00223583, បារាំង ERN 00503922 រហូតដល់ 24។ យើងពិនិត្យមើលអត្ថបទជាភាសាអង់គ្លេស ហើយប្រហែលជាផ្នែកមួយនៅទំព័រទី៦ "នៅពេលដែល ប៉ុល ពត ចង់ដឹងពីសភាពការណ៍នៅប-១ គាត់បានហៅខ្ញុំ ហើយសួរខ្ញុំ។ គាត់ទុកចិត្តខ្ញុំ។ ហើយគាត់ណែនាំអ្វី ខ្ញុំធ្វើការងារទាក់ទងទៅនឹងការទទួលភ្ញៀវ និងការរៀបចំផ្ទះ ហើយនិងការ -- ហើយគាត់ចាត់តាំងឲ្យខ្ញុំរៀបចំឲ្យបានល្អ"។ ខ្ញុំសូមសួរលោកថា តើ ប៉ុល ពត ហៅលោក តើគាត់ឲ្យនីរសារមកហៅលោក ឬក៏គាត់បញ្ជូនសំបុត្រមកលោក ឬក៏គាត់ហៅតាមទូរស័ព្ទ?

[១៥:២៩:០៨]

**ឆ៖** ចំណុចនេះគឺថា បើគាត់ថាចង់ជួបខ្ញុំគឺថា អត់មានតាមទូរស័ព្ទទេ ហើយអត់មានតាមសំបុត្រទេ។ ពេលដែលខ្ញុំមកជួបអ៊ំ អៀង សារី គឺថានៅជិតគ្នាហ្នឹង ដល់អ៊ីចឹងគាត់ឲ្យអ្នកដែលនៅជាមួយគាត់ហ្នឹងមកហៅខ្ញុំទៅ។ ហើយអ្នកដែលមកហៅថា អ៊ំចង់ជួបមិត្ត ជាម ឯងបន្តិច ខ្ញុំក៏ទៅៗអ៊ីចឹងទេ។

**ស៖** ហើយសូមឲ្យលោកមើលចំណុចនេះ ខ្ញុំមិនឃើញថាលោក អៀង សារី មានការពាក់ព័ន្ធទេនៅទីនេះ។ លោកបាននិយាយថា នៅពេលដែល ប៉ុល ពត ចង់ដឹងអំពីសភាពការណ៍នៅក្នុង ប-១ គាត់ហៅខ្ញុំទៅសួរ។ សំណួររបស់ខ្ញុំគឺថាផ្អែកលើពាក្យរបស់លោក ថាតើ ប៉ុល ពត ហៅលោកទៅសួរហ្នឹងគឺថាពីរឿង ប-១ ហ្នឹង គាត់ហៅដោយរបៀបណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៥:៣០:៣៨]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់សំណួរនេះ គឺសំណួរនេះបានសួរហើយ ហើយសាក្សីបានឆ្លើយរួចហើយ។ ប្រហែលជាលោកមេធាវីស្តាប់មិនទាន់ ឬក៏ថាលោកសាក្សីគាត់ឆ្លើយថា ពេលដែលគាត់ជួបលោក អៀង សារី ពេលបានជួបបែបនោះ គាត់បានទៅជួប ហើយទទួល។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមឆ្លើយ។ គឺថាមិនមានចំណុចណាមួយនៅក្នុងចម្លើយនេះទេ ឬក៏មួយទៀតដែលបានកត់ត្រានោះទេ ដែលថា ប៉ុល ពត នៅជាមួយ អៀង សារី ដែលនៅជាមួយគ្នា ជួបគាត់នោះទេ។ ខ្ញុំប្រើពាក្យផ្ទាល់របស់សាក្សីនេះ ហើយខ្ញុំសួរសាក្សីរូបនេះដើម្បីឆ្លើយឲ្យបានជាក់ស្តែង ថាតើ ប៉ុល ពត ហៅគាត់នោះដោយវិធីណា? គាត់ហៅតាមទូរស័ព្ទ ឬក៏បញ្ជូននីវសារឲ្យមកហៅ? ពីព្រោះម្សិលមិញ លោកសាក្សីនិយាយក្រោមសម្បថថា លោក អៀង សារី តែងតាំងគាត់។ ប៉ុន្តែថ្ងៃនេះក្រោមសម្បថ ក្រោមពាក្យសម្បថដដែល គាត់ថា ប៉ុល ពត ទេ អ្នកចាត់តាំងគាត់ឲ្យធ្វើការ។ នេះហើយដែលខ្ញុំចង់សួរឲ្យដឹងថាតើគាត់មានទំនាក់ទំនងពិសេសដូចម្តេច? ហើយខ្ញុំមានសិទ្ធិចង់ដឹងថាតើ ប៉ុល ពត ហ្នឹង ហៅគាត់ហ្នឹង ហៅដោយរបៀបណា? តាមរយៈអ្វី?

[១៥:៣១:៥១]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ ព្រោះសំណួរនេះពិតជាសំណួរច្រំដែល។ សំណួរច្រំដែល កាលណាឲ្យសាក្សីឆ្លើយ អាចឆ្លើយខុសគ្នា នាំឲ្យពិបាកពិចារណា។ បញ្ហាទីពីរ សំណួរច្រំដែលនាំឲ្យបាត់បង់ពេលវេលា ការប្រើប្រាស់ពេលវេលាក្នុងការដេញដោលគ្មានប្រសិទ្ធភាព។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ដោយសារថាមានការខ្វែងទស្សនៈនៅក្នុងចម្លើយ ការថ្លឹងថ្លែងនៃតម្លៃភស្តុតាងគឺត្រូវយកសម្តីចុងក្រោយរបស់សាក្សី។ នេះហើយជាគោលបំណងដែលខ្ញុំចង់ឲ្យសាក្សីបញ្ជាក់។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី នៅពេលដែលលោកបានជួបលោក ប៉ុល ពត តើលោកអាចប្រាប់ខ្ញុំបានទេ តើការជួបហ្នឹង ជួបរយៈពេលប៉ុនណា? យូរប៉ុនណាដែរ?

**លោក រ៉ោម តុន៖**

**ឆ៖** ជួបហ្នឹងមិនបានយូរអីប៉ុន្មានទេ តែ៥នាទីទៅ២០នាទីហ្នឹងអស់ហើយ។

[១៥:៣៣:០០]

**ស៖** តើលោកបានជួបគាត់នៅក្នុងការិយាល័យរបស់គាត់ ឬក៏នៅក្នុងកន្លែងណាផ្សេង? បាទ ខ្ញុំ

ឮថាមិនទាន់បានបកប្រែទៅជាភាសាបារាំងទេ។ អ៊ីចឹងយើងនិយាយយឺតៗ។ តើលោកបានជួបគាត់នៅកន្លែងគាត់ធ្វើការ ឬក៏នៅកន្លែងផ្សេង?

**ឆ៖** ខ្ញុំភាគច្រើន ខ្ញុំជួបគាត់ គឺថាពេលល្ងាច ពេលហូបបាយហើយ គឺពេលល្ងាច។ ជួបនៅកន្លែងហូបបាយហ្នឹង។ កន្លែង -- ព្រោះកន្លែងហ្នឹងគេហូបបាយរួម ដឹកនាំទាំងអស់។ កន្លែងហ្នឹងគេហូបបាយរួម។

**ស៖** នេះហើយជាកន្លែងដែលលោកតែងតែបានជួប ប៉ុល ពត នៅកន្លែងហូបបាយរួម។ តើអ៊ីចឹងឬ?

**ឆ៖** ហ្នឹងហើយ កន្លែងហ្នឹង។

[១៥:៣៤:១៥]

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើផ្ទះបាយរួមហ្នឹងនៅកន្លែងណា? ថាតើលោកធ្វើដំណើរទៅកន្លែងហ្នឹងដោយរបៀបណា ទៅហូបបាយហ្នឹង?

**ឆ៖** កន្លែងហូបរួមនៅផ្ទះក-១ វានៅក្រោមផ្ទះ ក្រោមផ្ទះវែងហ្នឹង។ ហើយខ្ញុំៗទៅ បើខ្ញុំទៅពីក្រសួងទៅ ខ្ញុំជិះម៉ូតូ។ ជិះម៉ូតូទៅជួប អ៊ំ អៀង សារី។ ជួបអ៊ំ អៀង សារី ហើយ គាត់ចាត់ឲ្យនីរសារគាត់មកហៅខ្ញុំ ឲ្យខ្ញុំទៅជួបគាត់ ខ្ញុំក៏ចេញកន្លែងអ៊ំ អៀង សារី ហ្នឹងបានទៅជួបគាត់។

**ស៖** តើលោកបានជួប ប៉ុល ពត ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** អត់បានញឹកញាប់ទេ យូរៗម្តងៗ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅដល់ប្រធានបទមួយផ្សេងទៀត ដោយហេតុថា ខ្ញុំមិនសល់ពេលច្រើនប៉ុន្មានទេល្ងាចនេះនោះ។ លោកបានឆ្លើយថា លោកមិនដឹងថា ស-២១ នៅកន្លែងណាទេ។ តើអ៊ីចឹងដែរឬទេ? តើនេះជាចម្លើយរបស់លោកអ៊ីចឹងឬ?

**ឆ៖** បាទ ខ្ញុំអត់ដឹងស-២១ នៅត្រង់ណាទេ អត់ដឹងទេបាទ។

[១៥:៣៦:១២]

**ស៖** តាមពិតម្សិលមិញ ភាគីបានសួរលោកអំពីយោបល់របស់ ឌុច។ ហើយលោកបានឆ្លើយថា លោកមិនដែលបានដឹងពីស-២១ទេ បើ ឌុច គាត់ចង់និយាយថាម៉េច អាហ្នឹងជារឿងរបស់គាត់។ នៅក្នុងចម្លើយទីពីររបស់លោកទៅសហចៅក្រមស៊ើបអង្កេត E3/63 និងលេខឯកសារជាអត្ថបទភាសាខ្មែរ 00228845, អង់គ្លេស 00231410, បារាំង 00376055-56។ ឥឡូវនេះ យើងចង់យល់គឺថា លោក

មិនដែលបានជួប ឌុច ទាល់តែសោះ តើអ៊ីចឹងឬ?

**ឆ៖** បាទ ខ្ញុំអត់ដែលបានជួប ឌុច ទាល់តែសោះ។

**ស៖** បាទ អ៊ីចឹងលោកនិយាយថា អ៊ីចឹងលោកអះអាងថា ឌុច មិនមែនឆ្លើយត្រឹមត្រូវទេ ហើយមិនឆ្លើយដោយស្មោះត្រង់ទេ នៅពេលដែលគាត់និយាយថា គាត់បានជួបលោកនោះ។ តើអ៊ីចឹង លោកយល់ -- លោកអាចឆ្លើយបានដូចម្ដេច?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប ចាំស្ដាប់អង្គជំនុំជម្រះសម្រេចលើសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាទៅនឹងការតាំងសំណួរចុងក្រោយ ដោយមេធាវីជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៥:៣៨:០១]

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន។ ខ្ញុំសូមជំទាស់ដោយថា ការបញ្ជាក់ខុសទៅលើចម្លើយ ហើយខ្ញុំមិនប្រាកដថា ឌុច ថាបានឃើញសាក្សីទេ ប៉ុន្តែមេធាវីការពារក្ដី បានយោងទៅចំណុចមួយនៃសក្ខីកម្មនោះគឺ មិនសមស្របទេ តាមដែលខ្ញុំចាំសក្ខីកម្មរបស់ ឌុច នោះគឺមិនច្បាស់ជាអ៊ីចឹងទេបាទ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំនឹងរៀបសំណួរឡើងវិញ លោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** យើងមើល E3/60 ខ្មែរ 00195598, អង់គ្លេស 00195606, បារាំង ERN 00195616។ នេះកំណត់ហេតុស្ដាប់ចម្លើយរបស់ ឌុច បាទ។ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៨ នៅកន្លែងនេះ គាត់និយាយថា "ចំពោះក្រសួងការបរទេស មាននីរសារដែលនាំអ្នកទោសមកឲ្យស-១ អ្នកនោះឈ្មោះ ជាម ដែលគាត់មានអាយុប្រហាក់ប្រហែលខ្ញុំ"។ ឌុច គាត់ឆ្លើយថាអ៊ីចឹង។ នេះហើយជាផ្នែកមួយដែលលោកៗជំទាស់ ដែលលោកនិយាយថា ឌុច អាចនិយាយភ័ន្តច្រឡំ ឬក៏អាចផ្ដល់សក្ខីកម្មមិនពិត។ តើនេះជាជំហររបស់លោកសាក្សីអ៊ីចឹងទេ លោក?

**លោក វ៉ាចាម តុន៖**

**ឆ៖** ចំណុចនេះ គឺថា ខ្ញុំបានបញ្ជាក់ថា ខ្ញុំមិនបានជួប ឌុច ហ្នឹងផ្ទាល់ទេ។ បើនៃ អ៊ំ អៀង សារី

គាត់ស្គាល់ ឌុច មិនដឹង ហើយគាត់ឧទ្ទេសនាមប្រាប់ថា អ្នកដែលនាំមនុស្សទៅហ្នឹង គឺឈ្មោះខ្ញុំហ្នឹង។ ម្សិលមិញ ខ្ញុំបានបញ្ជាក់ហើយថា ខ្ញុំបាននាំមនុស្សមួយចំនួន គឺឲ្យទៅខាងក្រុម៨៧០ ហើយ៨៧០ គេយកទៅណាទៀត ខ្ញុំអត់ដឹងទេ។ ខ្ញុំថា ខ្ញុំបានឆ្លើយអ៊ីចឹងម្សិលមិញនោះ។

**ស៖** បាទ ប៉ុន្តែ ឌុច និយាយអ៊ីចឹង ដែលថាលោក ជាម ហ្នឹងជានីរសាររបស់ក្រសួងការបរទេស បានយកអ្នកទោសទៅឲ្យស-២១ មិនមែនទៅមន្ទីរ៨៧០ មិនមែនទៅកន្លែងផ្ទះណាមួយទេ មិនទៅសណ្ឋាគារណាមួយទេ ប៉ុន្តែយកទៅឲ្យស-២១ នេះ។ ឌុច និយាយអ៊ីចឹង។ តើ ឌុច ផ្តល់សក្ខីកម្មឬព័ត៌មានមិនពិតទៅឲ្យសហចៅក្រមស៊ើបអង្កេត នៅពេលដែលគាត់និយាយបែបនេះ? តើលោកអាចឆ្លើយបានដូចម្តេច?

[១៥:៤១:២៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

ជាថ្មីម្តងទៀតនេះ យើងមិនមានជំទាស់ទៅនឹងការសួររបស់មេធាវីថា ត្រូវ ឬមិនត្រូវនោះទេ។ ប៉ុន្តែមិនសមស្របទេ ដែលមេធាវីការពារផ្តល់យោបល់អំពីចិត្ត ឬក៏ថា ឌុច និយាយកុហក ឬក៏និយាយមិនពិតនោះគឺថា បើសួរសាក្សីនេះឲ្យឆ្លើយថា ត្រូវ ឬមិនត្រូវ ហើយឲ្យសាក្សីនេះផ្តល់យោបល់ទៅលើចម្លើយរបស់ ឌុច ហ្នឹង អាហ្នឹងគឺមិនអាចទៅរួចទេ។

[១៥:៤២:០៦]

**លោក ម៉ៃខល កាណាវាស៖**

នេះ ហើយគឺ ឌុច បានផ្តល់ចម្លើយនេះ គាត់ធ្វើសម្បថ ហើយគាត់បានដេញដោលក្នុងតុលាការនេះ គាត់ប្រកាន់ជំហរថា គាត់ឆ្លើយទៅត្រង់តាមការសម្បថ។ អ៊ីចឹងខ្ញុំសួរសាក្សីឲ្យដឹងថា តើសាក្សីនេះពេលដែលបានស្បថហើយ ថាតើ ឌុច និយាយអ៊ីចឹង ពិត ឬមិនហ្នឹង? ថាតើៗនេះជាលទ្ធភាពដែលថា ឌុច ជាអ្នកឆ្លើយមិនពិត ឬក៏សាក្សីរូបនេះឆ្លើយមិនពិត។ ខ្ញុំមានសិទ្ធិការពារកូនក្តីរបស់សាក្សីរបស់ខ្ញុំ ដើម្បីសួរសាក្សីនេះឲ្យឆ្លើយពីរឿងនេះបាទ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

[១៥:៤២:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៤:០៤]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា និងមូលហេតុនៃសេចក្តីជំទាស់ធ្វើឡើងមានមូលដ្ឋានត្រឹមត្រូវសមស្រប។ សេចក្តីជំទាស់មានប្រសិទ្ធភាព។ ហើយសំណួរប្រភេទនាំឲ្យ បំណងឲ្យសាក្សីឆ្លើយដែលផ្តល់ជាសេចក្តីសន្និដ្ឋាន ឬការយល់ឃើញអត្តនោម័តិរបស់ខ្លួន គឺមិនត្រឹមត្រូវទេ។

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរអម្បាញ់មិញនេះទេ!

**លោក ម៉ៃខល កាណាវាស៖**

យើងមានចម្លើយសារភាព IS51.0។ ខ្មែរ 00022816, អង់គ្លេស 00662311។ យើងមិនមានអត្ថបទជាភាសាបារាំងទេ។ នេះជា -- នៅក្នុងឧបសម្ព័ន្ធលេខ១០ នៃចម្លើយសារភាពពី ស-២១ នៃឯកសាររបស់សហព្រះរាជអាជ្ញា គឺថាឯកសារនៅក្នុងបញ្ជីឯកសារអក្សរ D83 ត្រង់លេខរៀង។ នៅក្នុងចម្លើយសារភាពនេះ នៅទំព័រទី២ ខ្មែរ ERN 0002285--

**ប្រធានអង្គជំនុំ៖**

ឈប់សិនតំណាង -- អ៊ំ! មេធាវីឈប់! មេធាវីផ្អាកបន្តិចសិន ចាំស្តាប់មតិយោបល់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។ សូមអញ្ជើញ!

[១៥:៤៥:៥៣]

**លោក ឌេល លីសាក់៖**

ខ្ញុំស្តាប់ទៅ ខ្ញុំយល់ថា លោក កាណាវាស ចង់នឹងប្រើខ្លឹមសារនៃចម្លើយសារភាពដែលថាមេធាវីការពារហ្នឹងចំណាយពេលច្រើនណាស់ ការពារកុំឲ្យប្រើខ្លឹមសារនៃចម្លើយសារភាពនេះ។ ហើយខ្ញុំមានការភ្ញាក់ផ្អើលណាស់ដែលថា លោក កាណាវាស គឺចង់ប្រើខ្លឹមសារចម្លើយសារភាពនេះមកសួរសាក្សី។ ដូច្នេះ មុននឹងបន្តសូមឲ្យជម្រាបទៅតុលាការ ថាតើគាត់ចង់ប្រើខ្លឹមសារ ឬក៏ប្រើផ្នែកណាទៅ តើគាត់មានមូលដ្ឋានច្បាប់អ្វីគាំទ្រទេ?

**លោក ម៉ៃខល កាណាវាស៖**

ហើយតាមគំនិតនេះ សហព្រះរាជអាជ្ញាចង់ប្រើផ្លូវពីរ នៅពេលដែលចង់គាត់សួរសាក្សីគាត់ប្រើ ប៉ុន្តែនៅពេលយើងចង់ប្រើគាត់បែរជាជំទាស់។ ព័ត៌មានដែលខ្ញុំចង់ប្រើសម្រាប់ដាក់ជាភស្តុតាងហ្នឹងមិនមែនជា -- មិនមែនចេញមកពី សេ.អ៊ី.អា, កា.ហ្សេ.បេ ពីអ្នករងទារុណកម្មទេ។

[១៥:៤៦:៥២]

ខ្ញុំប្រើឯកសារទាក់ទងទៅនឹងដែលថា សាក្សីនេះឯងដែលនាំពួកគេទៅស-២១។ នេះ ហើយខ្ញុំប្រើតែខ្លឹមសារ។ អានេះវាផ្ទុយទៅនឹងអ្វីដែលសាក្សីនេះបានឆ្លើយ ហើយឯកសារហ្នឹងគាំទ្រនូវអ្វីដែលឌុច បាននិយាយ។ ខ្ញុំថា ខ្លឹមសារនេះត្រឹមត្រូវ ហើយយើងអាចនឹងមានវិធានដ៏ត្រឹមត្រូវ គឺថាតើមិនអាចប្រើចម្លើយសារភាពអ្វីទាំងអស់ ឬក៏អាចប្រើព័ត៌មានមូលដ្ឋានទាក់ទងនឹងកាលបរិច្ឆេទ ឬក៏ទាក់ទងថាតើ ប៉ង់ ក្រោយមក មកដល់ស-២១? អ៊ីចឹងហើយ ហើយយើងមិនប្រើទាល់តែសោះ។ ភាគីទាំងអស់មិនអាចប្រើ ហើយចៅក្រមក៏មិនអាចប្រើដែរ ឬក៏អាចមានវិធានដែលថាវាមានអត្ថន័យអាចប្រើ ហើយឲ្យយុត្តិធម៌សម្រាប់ភាគីទាំងអស់។ ដូច្នេះ ខ្ញុំអាចនឹងសួរសាក្សីរូបនេះ ថាតើគាត់បានយកអ្នកទោសហ្នឹងទៅស-២១ ដូចដែលចម្លើយសារភាពហ្នឹងគេឆ្លើយដែរឬទេ? ជនរងគ្រោះគេឆ្លើយថា អ៊ីចឹងបាទ។

[១៥:៤៨:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោក កាណាវាស គឺថាកំណត់ការប្រើពាក្យ គឺថាការប្រើហ្នឹងគឺថា គាត់លើកឡើងបែបនេះមិនត្រឹមត្រូវតាមឆន្ទៈរបស់យើងទេ។ យើងៗប្រើតែចំណារ គឺយើងមិនប្រើខ្លឹមសារទេ យើងប្រើៗចំណុចមួយចំនួនទៅតាមអនុសញ្ញាដែលអនុញ្ញាតឲ្យយើងប្រើ គឺបង្ហាញពីអង្គហេតុទាក់ទងទៅនឹងស-២១ និងកាលបរិច្ឆេទ។ ប៉ុន្តែយើងមិនប៉ុនប៉ងប្រើខ្លឹមសារចម្លើយសារភាព ចម្លើយដែលធ្វើឡើងដោយជនរងគ្រោះដែលត្រូវគេសួរចម្លើយទេ។ ហើយទឡ្ហីករណ៍របស់លោក កាណាវាស ហ្នឹងគឺថា មិនអាចប្រើបានទាំងអស់ គ្រប់ករណីហ្នឹង គឺថាខ្ញុំមិនយល់ស្របទៅនឹងជំហររបស់គាត់ទេ។ ហើយសូមតែយើងបានហើយ ព័ត៌មានទាំងអស់ហ្នឹងគឺថា ទាក់ទងទៅនឹងចំណុចនេះ ហើយគឺថាអ្វីដែលៗមានចែងកំណត់ច្បាស់ហ្នឹងគឺថា លោកទំនងជាលើកយកខ្លឹមសារ។

[១៥:៤៩:១៥]

**លោក ម៉ៃខល កាណាវាស៖**

ចម្លើយសារភាពហ្នឹង គឺថានៅថ្ងៃទី១២ ធ្នូ ឆ្នាំ១៩៧៨ អ្នកដែលផ្តល់ចម្លើយសារភាពនេះ គឺគាត់ពន្យល់ថា គេយកគាត់មកដល់ស-២១ អ្នកណាយកគាត់មក? ហើយវាផ្ទុយពីចម្លើយរបស់សាក្សីរូបនេះដែលថា--

[១៥:៤៩:៣៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥១:២២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីសួរបញ្ជាក់ទៅនឹងមេធាវី ម៉ៃខល កាណាវាស ហើយនិងសម្រេចទៅលើសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវី ដែលមានការពាក់ព័ន្ធទៅនឹងកំណត់ហេតុនៃការ -- បានមកពីការធ្វើទារុណកម្មនេះ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមមានសំណើសុំបំភ្លឺចំពោះមេធាវី កាណាវាស។ ពីព្រោះថាវាជារឿងកម្រណាស់នៅក្នុងការលើកឡើងពីបញ្ហានេះ។ ដូច្នេះ ខ្ញុំគិតថា វាជាការសំខាន់ណាស់ ដែលត្រូវមានការបំភ្លឺឱ្យបានច្បាស់លាស់ ចំពោះបញ្ហានេះ។ លោកបានបញ្ជាក់ថា ខ្ញុំបានប្រើប្រាស់នូវខ្លឹមសារចម្លើយសារភាពពាក់ព័ន្ធទៅនឹងចាប់ខ្លួន ប៉ង់។ អ៊ីចឹង ខ្ញុំចង់ដឹង ថាតើលោក កាណាវាស មានឯកសារយោងអីច្បាស់លាស់បញ្ជាក់ទេ ថាខ្ញុំធ្លាប់ប្រើនោះ? ខ្ញុំដូចជាចាំថា ខ្ញុំមិនបានប្រើទៅលើខ្លឹមសារចម្លើយភាពទេ។ អ៊ីចឹង លោកអ្វីបញ្ជាក់ទេពីចំណុចនេះ?

[១៥:៥២:៥២]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំមិនមានលេខយោងទេ គឺថាបើមានពេលតែពីរបីសីហ្គុង ខ្ញុំអាចមាន។ ខ្ញុំដឹង គឺថាដឹងពីវិធីដែលបានប្រើ ហើយខ្ញុំជំទាស់កាលណោះ។ គឺទាក់ទងទៅនឹងលោកបានជួយឱ្យសាក្សីទាក់ទងទៅនឹងកាលបរិច្ឆេទ នៅពេលដែល ប៉ង់ ចូលមកដល់ស-២១។ ហើយលោកបានធ្វើអន្តរាគមន៍ នៅពេលដែលសាក្សី

កំពុងតែចង្អុលបង្ហាញ ហើយផ្អែកទៅលើកំណត់ហេតុ -- កំណត់ចម្លើយព័ត៌មាននៅស-២១ ប៉ង់ចូលមកដល់នេះ ខ្ញុំនឹងរកឯកសារយោង។ ខ្ញុំអាចធានាលោកចៅក្រមច្បាស់ ខ្ញុំមិនធ្វើការចោទប្រកាន់មិនពិតប្រឆាំងលោកទេ។ តាមពិត ខ្ញុំមាននៅក្នុងឯកសាររបស់ខ្ញុំ។ ខ្ញុំនឹងរកមើល ប្រហែលជាឃើញក្នុងរយៈពេលខ្លី។

[១៥:៥៣:៤៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោក កាណាវាស ខ្ញុំចង់ដឹងច្បាស់ ថាលោកនិយាយនេះ លោកយោងទៅលើបញ្ជីស-២១ ឬក៏ចម្លើយសារភាព? បើយើងយោងទៅលើបញ្ជីស-២១ ដែលបញ្ជាក់អំពីថ្ងៃចេញ ថ្ងៃចូល អ្នកទោសនោះគឺជារឿងផ្សេង ហើយប្រសិនជាយកចម្លើយសារភាពនោះ វាជារឿងផ្សេង។ ដូច្នេះ សូមឱ្យលោកឱ្យប្រុងប្រយ័ត្នឱ្យច្បាស់ កុំឱ្យច្រឡំគ្នារវាងបញ្ជីមន្ទីរស-២១ គឺយើងអាចយកមកប្រើបាន។ វាមានព័ត៌-មានចង្អុលបង្ហាញច្បាស់លាស់អំពីកាលបរិច្ឆេទចូល ជាពិសេស គឺថ្ងៃសម្លាប់ចោលនោះ។ នេះជារឿងមួយផ្សេង។ ក៏ប៉ុន្តែនៅពេលដែលនិយាយថា យកខ្លឹមសារមក -- ខ្លឹមសារនៃចម្លើយសារភាពនោះ វាជារឿងមួយផ្សេងមួយទៀត។ ដូច្នេះ សូមឱ្យលោកឱ្យច្បាស់ ថាយើងនិយាយពីរឿងណាមួយឱ្យច្បាស់។ ចំពោះខ្ញុំផ្ទាល់នោះ ខ្ញុំដូចជាមិនដែលនិយាយអំពីចម្លើយសារភាពទេ គឺខ្ញុំនិយាយអំពីបញ្ជីអ្នកទោស។

[១៥:៥៤:៣៧]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំពិនិត្យរក គឺថាយើងមានការយោងទៅរកឯកសារស-២១ ដែលលោកយោងថា នៅពេលថាតើបុគ្គលបញ្ជូនមក គឺថាអាចនឹងមើលចម្លើយសារភាព ដើម្បីយកកាលបរិច្ឆេទ ដែលថាអាចនឹងមានករណីបែបនេះ យើងទទួចថា កាលណាមាន -- កាលណាជនរងគ្រោះថាគេទៅដល់កន្លែងហ្នឹងដោយវិធីណា គប្បីតែទទួលស្គាល់។ ជាពិសេសក្នុងករណីដ៏ចង្អៀតនេះដែលថា វាផ្ទុយទៅនឹងសក្ខីកម្មរបស់សាក្សីដែលសាក្សីគាត់ស្បថហើយ គាត់មកឆ្លើយ ហើយវាផ្ទុយទៅនឹងព័ត៌មាននោះ។ ហើយបើថាមិនអាចប្រើបានទេ ក៏មិនជាចោទបញ្ហាទេ ហើយយើងនឹងប្រើតែបញ្ជី ហើយនិងតួលេខនៅលើបញ្ជីអ្នកទោសតែប៉ុណ្ណោះ។ ហើយយើងត្រូវចង់បានចម្លើយឱ្យបានច្បាស់ បើថានៅពេលដែលមេធាវីចង់ប្រើត្រូវបានហាមឃាត់ ប៉ុន្តែសហព្រះរាជអាជ្ញាចង់ប្រើ គឺតុលាការអនុញ្ញាត។ ដូច្នេះហើយយើងចង់ឱ្យបានស្មើភាពគ្នា។ ហើយសាក្សីរូបនេះក៏មកឆ្លើយក្រោមសម្បថ។ ហើយនេះជាភស្តុតាង វាបង្ហាញអំពី

គុណភាព អំពីសក្ខីកម្មរបស់គាត់បាទ។

[១៥:៥៦:០៨]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាមានបញ្ហាអីដដែលទេ? រឿងដូចជាសាចុះសាឡើង ដដែលដូចខុសគោលការណ៍ណែនាំអនុវត្តស្ដីពីការជំទាស់។

**លោក ម៉ៃខល កាណាវាស៖**

ឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម ឡាវែន័។បាទ យើងចង់ឲ្យច្បាស់ថាយើងមិនចោទប្រកាន់ដោយមិនពិតនោះទេ គឺឯកសារ E1/7.1 គឺអត្ថបទជាភាសាអង់គ្លេស ERN លេខ 00806528 កាលបរិច្ឆេទនោះគឺ ៣០ ខែមេសា ឆ្នាំ២០១២។ នៅកន្លែងនេះចៅក្រម ឡាវែន័ បន្ទាត់ទី១៥ "សូមអរគុណលោកប្រធាន ហើយសូមអភ័យទោសដែលខ្ញុំកាត់ ហើយជាសំណួររបស់លោក កាណាវាស ប៉ុន្តែខ្ញុំចង់ឲ្យភាគីចាប់អារម្មណ៍ថា អង្គហេតុនៅថ្ងៃទី២៤ ខែមេសា សហព្រះរាជអាជ្ញាបានដាក់ឯកសារមួយជូនចៅក្រម IS.5.14 ឯកសារហ្នឹងដាក់ថា ជាចម្លើយៗសារភាពរបស់ ប៉ង់។ ហើយបើយើងមើលកាលបរិច្ឆេទដែលខ្ញុំបានបញ្ជាក់នោះ គឺយើងដឹងថា ថ្ងៃ -- កាលបរិច្ឆេទដំបូងដែល ប៉ង់ ដាក់ក្នុងចម្លើយសារភាព គឺថ្ងៃទី២៨ ឧសភា ឆ្នាំ១៩៧៨។ ហើយចំណុចខាងក្រោយ គឺថាកាលបរិច្ឆេទចុងក្រោយមាននៅក្នុងឯកសារដែលមានបារាំងនិងអង់គ្លេសនៅថ្ងៃទី២២ កក្កដា ឆ្នាំ១៩៧៨។ ហើយខ្ញុំគិតថានេះជាចំណុចសំខាន់ដូចថា សាក្សីនិយាយញឹកញាប់ហ្នឹង គឺថាការចាប់ខ្លួន ប៉ង់ គឺថាអាចធ្វើឡើងនៅមួយថ្ងៃមុនពេលដែលវៀតណាមចូលមកដល់ភ្នំពេញ។ ម៉្យាងទៀត នៅចុងឆ្នាំ១៩៧៨ ដូច្នេះខ្ញុំជឿថា មានៗការខ្វែងគ្នា ហើយយើងមានភស្តុតាងមួយចំនួនដែលយើងអាចយកមកជាបង្អែក។ សូមអរគុណ។" នេះជាសម្ដីរបស់លោកចៅក្រម។

[១៥:៥៨:២៥]

ហើយខ្ញុំសូមអភ័យទោស ប្រសិនខ្ញុំកត់ត្រាខុស នេះអ្វីដែលខ្ញុំមានលោកចៅក្រម ឡាវែន័។ ហើយខ្ញុំសូមជម្រាបដោយគោរពថា ខ្ញុំត្រូវតែយោងទៅលើឯកសារមួយនេះដែលលោកបាននិយាយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន័៖**

ខ្ញុំគិតថា យើងអាចឯកភាពគ្នាបានទៅលើចំណារដែលបញ្ជាក់អំពីការបរិច្ឆេទនៃចម្លើយសារភាព ក៏ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើយើងនិយាយអំពីខ្លឹមសារនៃចម្លើយសារភាពនោះគឺថា ដូចជាគ្មានទេ។

ដូចវាមានភាពខុសគ្នារវាងចំណារដែលបញ្ជាក់អំពីកាលបរិច្ឆេទនៃការសួរចម្លើយដោយការធ្វើទារុណកម្ម ហើយនិងខ្លឹមសារនៃចម្លើយសារភាព។

**លោក ម៉ៃខល កាណាវាស៖**

យើងយល់ស្របទាំងស្រុងសំណួរនេះ ខ្ញុំមិនជំទាស់ទេ ហើយខ្ញុំគ្រាន់តែអានអ្វីដែលកត់ត្រានៅក្នុងឯកសារតុលាការ។ លោកចៅក្រមបានជ្រាបហើយ ខ្ញុំបានប្រើជាមូលដ្ឋានដើម្បីឆ្លើយទៅនឹងសំណួររបស់លោក គឺអាស្រ័យទៅលើឆន្ទានុសិទ្ធិ។

[១៥:៥៩:៤៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើលោកមានមើលឃើញភាពខុសគ្នាទេ នៅពេលដែលថាចៅក្រមគាត់យោងទៅលើខ្លឹមសារនៃចម្លើយសារភាព ហើយនិងចៅក្រមគាត់ត្រូវយោងនៅត្រឹមតែចំណារនៅក្នុងចម្លើយសារភាពនោះ គឺចំណុចពីរនេះវាខុសគ្នាដាច់ស្រឡះហើយលោកមេធាវី។

**លោក ម៉ៃខល កាណាវាស៖**

គឺវាមានភាពខុសគ្នា។ អ្វីដែលខ្ញុំអាននៅក្នុងប្រតិចារឹកនេះ ហើយប្រហែលជាខ្ញុំត្រូវដឹកបន្ទាត់ គឺថាអ្វីដែលយោង គឺថាមិនមានអ្វីនៅក្នុងអត្ថបទនេះទេ ដែលថាទាក់ទងទៅនឹងចំណារនោះទេ។ ដោយជាក់ស្តែង បើសិនជាដូច្នោះជាកំហុសមួយរបស់ខ្ញុំ គឺថាលោកបានមើលឯកសារហើយ លោកមើលចំណារ ប៉ុន្តែនៅក្នុងកំណត់ត្រាមិនបានបញ្ជាក់ថាលោកបានមើលចំណារនោះទេ។ ហើយបែឲ្យជាយើងយល់ថាលោកបានប្រើចម្លើយសារភាព។ បើសិនជាអាចប្រើបានត្រឹមតែចំណារ សូមតែមានសេចក្តីសម្រេចរឿងនោះ គឺថាឲ្យភាគីទាំងអស់អាចប្រើបានដូចគ្នា តុលាការអាចទទួល។ ហើយខ្ញុំយល់ពីអត្ថន័យដែលលោកបានបញ្ជាក់នេះបាទ។

[១៦:០០:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០២:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដើម្បីដោះស្រាយបញ្ហានេះឲ្យបានច្បាស់លាស់ ពីព្រោះយើងនៅចងចាំទាំងអស់គ្នានៅក្នុងកិច្ចដំណើរការសវនាការតាំងពីដើមទីរហូតមក គឺយើងគោរពនិងអនុវត្តនៅអនុញ្ញាអន្តរជាតិស្តីពី

ការប្រឆាំងទៅនឹងការប្រើប្រាស់នូវការចម្លើយសារភាពដែលបានមកពីការទារុណកម្មនេះ។ ហើយអង្គជំនុំជម្រះប្រកាន់ខ្ជាប់ខ្ជួន ហើយប្រកាន់ជំហរដាច់ខាត គឺក្នុងការប្រើប្រាស់អនុវត្តបានជានិច្ចនូវអនុសញ្ញាអន្តរជាតិនេះ។ ដូច្នេះនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ គឺអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគីលើកយកខ្លឹមសារដែលបានមកពីចម្លើយសារភាពមកដេញដោលសាក្សី ឬក៏អ្នកជំនាញ ឬក៏បុគ្គលណាមួយដែលពាក់ព័ន្ធតាមផ្លូវតុលាការទេ ពីព្រោះវាលទ្ធផលនៃ -- ដែលបានមកពីការធ្វើទារុណកម្ម។ ក្រៅពីនេះពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀត គឺអាចលើកមកដេញដោលបាន ដូចជាយើងធ្លាប់អនុវត្តកន្លងមកហើយ ដូចជាចំណារ ដូចជាកាលបរិច្ឆេទជាដើម។

**លោក ម៉ៃខល កាណាវាស៖**

ឥឡូវនេះគឺថាយើងម៉ោងបួនជាងហើយលោកប្រធាន។ តើអនុញ្ញាតឲ្យខ្ញុំបន្តទៀត ឬដូចម្តេច?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០១ ខែសីហា ហើយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ថ្ងៃស្អែកហ្នឹង គឺដំណើរការនីតិវិធីនឹងបន្តការតាំងសំណួរដេញដោលចំពោះសាក្សីដោយក្រុមមេធាវីការពារក្តីលោក អៀង សារី ជាបន្ត។

ហើយលោក វ៉ាចាម តុន អង្គជំនុំជម្រះនៅត្រូវការស្តាប់សក្ខីកម្មរបស់លោកទៀត ហើយដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ សូមលោកអញ្ជើញឲ្យបានមកដល់ទីនេះ ហើយមេធាវីគឺដូចគ្នា។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ក្នុងការបញ្ជូនសាក្សីទៅកាន់កន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយឲ្យនាំពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*